**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University Of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងសម័យ ឧស្សាហកម្ម៤.0

## (ករណីសិក្សា៖ប្រទេសកម្ពុជា)

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ  លោក **ហ៊ីន់ សីហា**

កញ្ញា **ញឹម សោភា**

ណែនាំដោយ

សាស្ត្រាចារ្យរងបណ្ឌិត **ឈុន ពហុ**


ថ្នាក់បរិញ្ញាបត្រ **សេដ្ឋកិច្ចអភិវឌ្ឍន៍**

ជំនាន់ទី ០៧

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីររូបឈ្មោះ **ហ៊ាន់ សីហា** និង **ញឹម សោភា** ជានិស្សិតឆ្នាំទី៤ ថ្នាក់ D4C01 ផ្នែកសេដ្ឋកិច្ចអភិវឌ្ឍន៍ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំ ២០១៩-២០២៣។

**ខ្ញុំបាទទាំងពីររូបសូមសម្តែងគារវកិច្ច និងកតញ្ញូតាធម៌ជូនចំពោះ៖**

**លោកឪពុក យូ ផល្លា** **លោកឪពុក ញឹម ប៊ុណ្ណា**

**អ្នកម្តាយ មាស សុខុម** **អ្នកម្តាយ ឯក សុខជា**

ដែលជាអ្នកមានគុណយ៉ាងធំធេងចំពោះកូន ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ទំនុកបម្រុងដល់រូបកូនទាំងកម្លាំងកាយ កម្លាំងចិត្ត និងថវិកា តាំងពីតូចរហូតដល់ធំដឹងក្តីប្រកបដោយព្រហ្មវិហារធម៌ទាំងបួនគឺ មេត្តា ករុណា មុទិតា និងឧបេក្ខា ក៏ដូចជាបានផ្តល់ឱកាសឱ្យកូនបានសិក្សាចូលរៀនពីតាំងថ្នាក់មត្តេយ្យរហូតបានបន្តការសិក្សាដល់ថ្នាក់បរិញ្ញាបត្រដូចបច្ចុប្បន្ននេះ។ បើសិនជាគ្មានការលើកទឹកចិត្ត និងការយកចិត្តទុកដាក់ ពីសំណាក់អ្នកមានគុណទេ ម្ល៉េះសមពេលនេះ រូបកូនមិនអាចក្លាយខ្លួនជា កូនល្អ សិស្សល្អ មិត្តល្អ និងពលរដ្ឋល្អនៅក្នុងសង្គមបានឡើយ។ ទាំងអស់នេះហើយជាគុណូបការៈដ៏វិសេសវិសាល និងមិនអាចកាត់ថ្លៃបានចំពោះកូន។ ទន្ទឹមនឹងនេះ យើងខ្ញុំសូមថ្លែអំណរគុណចំពោះ **ឯកឧត្តមបណ្ឌិត សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង** និង **លោក លោកស្រីសាស្ត្រាចារ្យ** ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលខិតខំបំពេញភារកិច្ចក្នុងការគ្រប់គ្រង ដឹកនាំ និងជួយតម្រង់ទិសដល់រូបយើងខ្ញុំ ដើម្បីចូលរួមចំណែកក្នុងការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់ប្រទេសជាតិ ប្រកបដោយគុណភាព និងសមត្ថភាពពិតប្រាកដ។

ជាពិសេស យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ សាស្ត្រាចារ្យរង បណ្ឌិត **ឈុន ពហុ** ជាសាស្ត្រាចារ្យណែនាំ ដែលបានលះបង់កម្លាំងកាយ កម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃក្នុងការផ្តល់យោបល់ កែតម្រូវនូវកិច្ចការសរសេរសារណារហូតទទួលបានជោគជ័យ។

ជាចុងបញ្ចប់នេះ យើងខ្ញុំទាំងពីររូប សូមសម្តែងនូវការដឹងគុណអស់ពីដួងចិត្ត និងសូមគោរពជូនពរអ្នកមានគុណ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក លោកស្រីសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងមិត្តអ្នកអានទាំងអស់ឱ្យជួបតែនឹងសេចក្តីសុខ សេចក្តីចម្រើននៅក្នុងជីវិត ព្រមទាំងជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សារណាដែលយើងខ្ញុំបានតាក់តែងឡើងមកនេះ គឺជាអ្វីដែលយើងខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងជាទីបំផុត នៅពេលសិក្សាក្នុងថ្នាក់បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ចអភិវឌ្ឍន៍រយៈពេលបួនឆ្នាំងកន្លងមកនេះ។ ដោយសង្កេតឃើញថាប្រទេសកម្ពុជាសព្វថ្ងៃនេះកំពុងអភិវឌ្ឍន៍តាមបច្ចេកវិទ្យាជឿនលឿន និងអភិវឌ្ឍន៍តាមសម័យឧស្សាហកម្ម៤.០ជាអាទិ៍។ កត្តាទាំងអស់នេះទាមទារឱ្យប្រជាជនទូទាំងសកលធ្វើការសិក្សាស្រាវជ្រាវដើម្បីអោយមានការយល់ដឹង ចំណេះដឹងអោយកាន់តែទូលំទូលាយពីការអភិឌ្ឍន៍តាមសម័យកាល និងរដ្ឋគឺជាអ្នកដែររៀបចំ និងអនុម័តនូវផែនការអភិវឌ្ឍន៍នានា ស្វែងរកនូវមធ្យាបាយដើម្បីធ្វើអោយសេដ្ឋកិច្ចអោយកាន់តែមានការរីកច្រើន ដាក់ចេញនូវយន្តការផ្នែកច្បាប់ផ្សេងៗ ដើម្បីធ្វើអោយសេដ្ឋកិច្ចកាន់តែរីកលូតលាស់ ព្រមជាមួយនិងការដោះស្រាយ និងទប់ស្កាត់នូវវិបត្តសេដ្ឋកិច្ចនានាដែរ ដែលបាននឹងកំពុងកើតមានឡើង។ ចំពោះប្រធានបទមួយនេះដែរ វាគឺជាកត្តាលីកមួយយ៉ាងសំខាន់ដែរធ្វើ យើងខ្ញុំមានការចាប់អារម្មណ៍ចំពោះ ស្ថានភាពសេដ្ឋកិច្ចនៅក្នុងប្រទេសដែរកំពុងអភិវឌ្ឍន៏ ថាតើប្រទេសកំពុងអភិវឌ្ឍន៍ត្រូវយល់ដឹង និងអនុវត្តទៅលើការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ខ្លួនទៅតាមសម័យកាលបែបណាខ្លះ? ដើម្បីធ្វើអោយសេដ្ឋកិច្ចរបស់ខ្លួនកាន់តែមានការរីកចម្រើនកាន់តែខ្លាំង។ គោលបំណងចម្បងនៃការស្រាវជ្រាវចំពោះប្រធានបទ "ការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងសម័យឧស្សាហកម្ម៤.០ ករណីសិក្សា ប្រទេសកម្ពុជា" គឺដើម្បីចង់សិក្សាស្វែងយល់អំពីបរិបទសង្គមនីមួយៗដែលកំពុងអភិវឌ្ឍន៍តាមប្រធាបបទខាងលើ យ៉ាងណាមិញបើទោះបីជា ការស្រាវជ្រាវលើប្រធានបទនេះ យើងខ្ញុំបានសរសេរឡើងយ៉ាងសម្រិតសម្រាំង និងយកចិត្តទុកដាក់យ៉ាងណាក្តី ក៏គង់តែនៅមានចំណុចខ្វះខាតលើខ្លឹមសារ និងពាក្យពេចន៍ដែលកើតមានឡើងដោយអចេតនា ដោយហេតុសមត្ថភាពនៃការចងក្រង និងការប្រមូលផ្តុំនូវឯកសាររបស់យើងខ្ញុំនៅមានកម្រិតនៅឡើយ។

អាស្រ័យហេតុនេះ យើងខ្ញុំសូមការអធ្យាស្រ័យទុកជាមុនពីសំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ សិស្ស និស្សិត និងមិត្តអ្នកអានទាំងឡាយ ប្រសិនបើមានកំហុសឆ្គងកើតមានត្រង់កន្លែងណាមួយក្នុងខ្លឹមសារទាំងស្រុងនៃស្នាដៃសារណានេះ។ យើងខ្ញុំពិតជាមានសេចក្តីសោមនស្សន្តរីករាយយ៉ាងក្រៃលែង ក្នុងការទទួលយកនូវមតិរិះគន់ក្នុងន័យកែលម្អ ដើម្បីជាប្រយោជន៍ដល់រូបយើងខ្ញុំក្នុងការអភិវឌ្ឍសមត្ថភាពលើការស្រាវជ្រាវ និងតាក់តែងអត្ថបទអោយកាន់តែមាននូវគុណភាពស្នាដៃទៅលើការចងក្រងអត្ថបទបន្ថែមទៀត និងដើម្បីអោយមិត្តអ្នកអានទាំងអស់ ទទួលបាននូវចំណេះដឹងអោយកាន់តែទូលំទូលាយ ដើម្បីជាប្រយោជន៍យកទៅអភិវឌ្ឍន៍ខ្លួនឯង ព្រមទាំងសង្គមជាតិទាំងមូលផងដែរ។

# មាតិកា


បញ្ជីអក្សរកាត់ ........ iiv

បញ្ជីក្រាហ្វ ........ iv

បញ្ជីតារាង ........ v


## សេចក្តីផ្តើម


១. លំនាំបញ្ហា ........ ១

២. ចំណោទបញ្ហា ........ ១

៣. គោលបំណងនៃការស្រាវជ្រាវ ........ ១

៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២

ក. ដែនកំណត់នៃការស្រាវជ្រាវ: ........ ២

ខ. វិសាលភាពនៃការស្រាវជ្រាវ : ........ ២

៥. វិធីសាស្រ្តស្រាវជ្រាវ ........ ៣

៦. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៤

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤


## ជំពូកទី១

## ការរំលឹកទ្រឹស្តី


១. សេចក្តីផ្តើម ........ ៨

១.១. និយមន័យ និងទ្រឹស្តីសំខាន់ៗ ........ ១១

១.២. ទ្រឹស្តីការអភិវឌ្ឍសេដ្ឋកិច្ច ........ ១៣

១.២.១ និយមន័យអំពីការអភិវឌ្ឍសេដ្ឋកិច្ច(Economic Development) ........ ១៤

១.៣ ទ្រឹស្តីការវិនិយោគផ្ទាល់ពីបរទេស ........ ១៧

១.៣.១ ទ្រឹស្តីការប្រកួតប្រជែង ........ ១៨

១.៣.១.១ បដិវត្តឧស្សាហកម្មទី១.០ ........ ២២

១.៣.១.២ បដិវត្តឧស្សាហកម្មទី២.០ ........ ២២

១.៣.១.៣ បដិវត្តឧស្សាហកម្មទី៣.០ ........ ២៣

១.៤. បដិវត្តឧស្សាហកម្ម៤.0 ........ ២៤
១.៤.១ សម្ទិផលនៃ បដិវត្តឧស្សាហកម្ម ៤.0 ........ ២៥
១.៤.២ ឧស្សាហកម្ម៤.0សម្រួលដល់រាជរដ្ឋាភិបាលកម្ពុជា ........ ២៥
១.៤.៣ ការវិវត្តនៃបច្ចេកវិទ្យាឌីជីថល ........ ២៦
១.៤.៣.១ បដិវត្តឧស្សាហកម្មជំរុញដល់កំណើនសេដ្ឋកិច្ច ........ ២៧
១.៥.ផលិតផលក្នុងស្រុកសរុប ........ ២៩
១.៥.១ ការប្រើប្រាស់បច្ចេកវិទ្យា(ICT) ........ ៤៦
១.៥.២ កំណើនការនាំចេញបច្ចេកវិទ្យាខ្ពស់ ........ ៤៧

## ជំពូកទី២

## ស្ថានភាពទូទៅ នៃគោលនយោបាយអភិវឌ្ឍន៍ប្រទេសកម្ពុជា

២.១ គោលនយោបាយអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ........ ៤៩
២.១.១ គោលនយោបាយរបស់ប្រទេសកម្ពុជា ........ ៤៩
២.១.២ ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ........ ៤៩
២.២យុទ្ធសាស្រ្តជាតិឆ្នាំ២00៦-២0១0 ........ ៥១
២.២.១ រាជរដ្ឋាភិបាលក្នុងនីតិកាលទី៦ ........ ៥៣
២.២.២.ចំណូល-ចំណាយរបស់រដ្ឋាភិបាល ........ ៥៥
២.៣.ការប្រើប្រាស់បច្ចេកវិទ្យារបស់សហគ្រាសតាមកម្រិតនៃភាពចាស់ទុំ ........ ៦១
២.៣.១ បដិវត្តឧស្សាហកម្មទី៤.0 នៅកម្ពុជា ........ ៦១
២.៣.២ វិស័យកម្មន្តសាល ........ ៦២
២.៣.៣ វិស័យកាត់ដេរកម្ពុជា ........ ៦៣
២.៣.៤ ឧស្សាហកម្មសំណង់ ........ ៦៥
២.៣.៥ វិស័យពាណិជ្ជកម្ម និងសេវាកម្ម ........ ៦៦
២.៣.៦ ដីជួល ដីសម្បទាន ឬដីឯកជន ........ ៦៧

## ជំពូកទី៣
## ការពិភាក្សារលើ អភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងសម័យឧស្សាហកម្ម៤.0

៣.១ ទំនាក់ទំនងរវាងឧស្សាហកម្ម និងផលិតផលក្នុងស្រុកសរុប ........................................ ៧០

៣.២ ទំនាក់ទំនងនៃពាណិជ្ជកម្ម និងផលិតផលក្នុងស្រុកសរុប ........................................ ៧១

៣.៣ ការវិភាទំនាក់ទំនងនៃកំណើន GDP ក្នុងការនាំចេញប្រទេសកម្ពុជា........................................ ៧២

៣.៤ ការវិភាគ Regression នៃកំណើន GDP ក្នុងការនាំចូលប្រទេសកម្ពុជា........................................ ៧៣

៣.៥ ការវិភាគទំនាក់ទំនងនៃកំណើនGDP ផលិតផលក្នុងស្រុកសរុប ........................................ ៧៤

៣.៦ ការវិភាគ Regression នៃកំណើន GDP វិស័យបច្ចេកវិទ្យាខ្ពស់ប្រទេសកម្ពុជា........................................ ៧៦

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១.សេចក្តីសន្និដ្ឋាន ........................................ ៧៨

២ អនុសាសន៍........................................ ៧៨

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

| | |
|---|---|
| SMEs | : Small and Medium Enterprises |
| MOC | : Ministry of Commerce |
| MIME | : Ministry of Industry Mines and Energy |
| IMF | : International Monetary Fund |
| UNDP | : United Nations Development Program |
| WTO | : World Trade Organization |
| WASME | : World Association for Small and Medium Enterprises |
| ICT | : Information and Communications Technology |
| FDI | : Foreign Direct Investment |
| TCP | : Transmission Control Protocol |
| AI | : Artificial Intelligence |
| GDP | : Gross Domestic Product |
| GDP per Capita | : Gross Domestic Product per capita |
| OIC | : Organization of Islamic Cooperation |
| CPI | : Consumer Price Inflation |
| LE | : Large Enterprise |
| GNI | : Gross National Income |
| GNP | : Gross National Product |
| GATT | : General Agreement on Tariffs and Trade |
| GEM | : Gender Empowerment Measure |
| GDI | : Gender Development Index |
| MNE | : Multinational Enterprise |
| OPEC | : Organization of the Petroleum Exporting Countries |
| ODA | : Official Development Assistanc |
| CEPT | : Common Effective Preferential Tariff |
| TR | : Technology Revolution |

# បញ្ជីតារាង

តារាងទី៣.២. ការបែងចែកក្រុមហ៊ុន ឬសហគ្រាស........................................................................ ៥៩
តារាងទី២.៣.១៖ ការប្រើប្រាស់បច្ចេកវិទ្យាធៀបនឹងសហគ្រាសដែលដំណើរការក្នុងវិស័យកម្មន្តសាល........ ៦៣
តារាងទី២.៣.២៖ ការប្រើប្រាស់បច្ចេកវិទ្យាធៀបនឹងសហគ្រាសដែលដំណើរការក្នុងវិស័យពាណិជ្ជកម្មនិងសេវាកម្ម ........................................................................................................................ ៦៧
តារាងទី ៣.១ ការវិភាគ Simple Linear Regression នៃវិស័យពាណិជ្ជកម្ម ដោយផ្អែកលើកំណើន GDP ៧១
តារាងទី ៤.២ ការវិភាគ Simple Linear Regressionនៃវិស័យឧស្សាកម្មដោយផ្អែកលើកំណើន (GDP) ...៧០
តារាងទី ៤.៣ ការវិភាគ Linear Regression តម្លៃការនាំចេញសរុបនៃប្រទេសកម្ពុជា ទៅកាន់ប្រទេសផ្សេងៗ ៧២
តារាងទី ៤.៤ ការវិភាគ Linear Regression តម្លៃការនាំចូលសរុបនៃប្រទេសកម្ពុជា ទៅកាន់ទេសផ្សេងៗ..៧៤

# បញ្ជីក្រាហ្វ

ក្រាហ្វិកទី ២.៣.២ យោងតាមអគ្គនាយកដ្ឋានគយ និងរដ្ឋាករក្រោមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបាន ថាព្រះរាជាណាចក្រកម្ពុជា ........ ៦៥
ក្រាហ្វិក ទី ៤.៤ តម្លៃនៃការនាំចេញសរុបនៃប្រទេសកម្ពុជា ទៅកាន់ប្រទេសផ្សេងៗ ........ ៧២
ក្រាហ្វិកទី ៤.៥ តម្លៃនៃការនាំចូលសរុបនៃប្រទេសកម្ពុជា ទៅកាន់ប្រទេសផ្សេង ........ ៧៣

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ព្រះរាជាណាចក្រកម្ពុជា ធ្លាប់ជាអាណាចក្រដ៏ធំ និងមានអំណាចនយោបាយ សេដ្ឋកិច្ចខ្លាំងក្លាមួយនៅភូមិភាគអាស៊ីអាគ្នេយ៍កាលពីប្រមាណជាង៧០០ឆ្នាំមុន បានរក្សាភាពគង់វង្សរបស់ខ្លួនក្នុងស្ថានភាពបច្ចុប្បន្ន ដែលមានផ្ទៃក្រឡា ១៨១.០៣៥គីឡូម៉ែត្រក្រឡា ប្រជាជន១៥ ២៨៨ ៤៨៩នាក់ នៅក្នុងឆ្នាំ ២០១៩ និងផលិតផលក្នុងស្រុកសរុបប្រមាណចំនួន ៣០.៥៤៤ លានដុល្លារអាមេរិកខណៈដែល ផ.ស.ស សម្រាប់មនុស្សម្នាក់ៗ(GDP Per Capita) ត្រូវបានប៉ាន់ប្រមាណថាមាន ១ ៨៤២ ដុល្លារអាមេរិក(បើតាមខ្លឹមសារសង្ខេបប្រតិបត្តិស្តីអំពីសេចក្តីព្រាងច្បាប់ថវិកាឆ្នាំ២០២២)។

ការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងសម័យឧស្សាហកម្ម៤.0 ករណីសិក្សាប្រទេសកម្ពុជាដោយគេអាចមើលឃើញថា មានគុណសម្បត្តិជាក់លាក់ ដូចជា ជម្រុញដំណើរការនៃកំណើនសេដ្ឋកិច្ច ការអភិវឌ្ឍបច្ចេកវិទ្យា ឥទ្ធិពលនយោបាយ ប្រព័ន្ធសុខាភិបាល កត្តាសង្គម បរិស្ថាន និងធម្មជាតិ។ សាកលូបនីយកម្មបានបង្កើត ឱកាសសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ដូចជា ការផ្ទេរបច្ចេកវិទ្យាមានឱកាសកាន់តែច្រើនក្នុងការចូលទៅកាន់ ទីផ្សារសម្រាប់ប្រទេសអភិវឌ្ឍន៍ ជំរុញកំណើន និងការបង្កើនផលិតភាពនិងកម្រិតជីវភាពប្រជាពលរដ្ឋ។

សាកលូបនីយកម្មមានឥទ្ធិពលលើកំណើនសេដ្ឋកិច្ចរបស់បណ្តាប្រទេសអាស៊ាន អំឡុងឆ្នាំ១៩៧០-២០១៥ និងក៏មានឥទ្ធិពលផងដែរលើនយោបាយ សង្គម និងសេដ្ឋកិច្ច។ សាកលូបនីយកម្មជារួមវាបានផ្តល់នូវឥទ្ធិពលខ្លាំងចំពោះកំណើនសេដ្ឋកិច្ចរបស់បណ្តាប្រទេសសមាជិកអាស៊ាន ជាលទ្ធផលបញ្ជាក់ថា សាកលូបនីយកម្មសេដ្ឋកិច្ច និងសង្គម មានទំនាក់ទំនងដល់កំណើនសេដ្ឋកិច្ច ចំណែកសាកលូបនីយកម្មនយោបាយ មានទំនាក់ទំនងតិចតួចជាមួយនឹងកំណើនសេដ្ឋកិច្ច។

យើងមិនអាចកាត់ផ្តាច់ពីឥទ្ធិពលនៃសាកលូបនីយកម្ម និងសមាហរណកម្មសេដ្ឋកិច្ចតំបន់ និងពិភពលោកបាននោះទេ ដែលចង់ ឬមិនចង់ កម្លាំងនិន្នាការសាកលនៃបដិវត្តឧស្សាហកម្មទី៤.0នឹងមានឥទ្ធិពលទៅលើស្ទើរគ្រប់ទិដ្ឋភាពសង្គម សេដ្ឋកិច្ចកម្ពុជា ជាពិសេសវិស័យកម្មន្តសាល វិស័យដឹកជញ្ជូន និងការតភ្ជាប់វិស័យទូរគមនាគមន៍ និងការប្រាស្រ័យទាក់ទងវិស័យពាណិជ្ជកម្ម និងការធ្វើជំនួញតាមប្រព័ន្ធអ៊ិនធឺណេត ខ្សែច្រវ៉ាក់ផលិតកម្ម និងការផ្គត់ផ្គង់ឱ្យគ្នាទៅវិញទៅមកក្នុងតំបន់ក៏ដូចជាវិស័យអប់រំ និងការកសាងហេដ្ឋារចនាសម្ព័ន្ធ និងថ្នាលសម្រាប់ប្រពន្ធ័អប់រំ ឌីជីថល ដែលនឹងឈានទៅដល់ការផ្លាស់។

## ២. ចំណោទបញ្ហា

នៅក្នុងបរិបទកំណើនសេដ្ឋកិច្ចពិភពលោក សតវត្សរ៍ទី២១នេះ មានអត្ថបទស្រាវជ្រាវមួយចំនួនស្តីអំពីការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងសម័យឧស្សាហកម្ម៤.0 ករណីសិក្សាប្រទេសកម្ពុជា ប៉ុន្តែភាគច្រើនផ្តោតទៅលើបច្ចេក

វិទ្យាជឿនលឿន តាមសម័យឌីជីថល ហើយប្រទេសនៅក្នុងតំបន់អឺរ៉ុប និងអាស៊ីខាងត្បូង មិនទាន់បានឃើញនូវការសិក្សាស្រាវជ្រាវជាក់លាក់នៅឡើយ លើការអភិវឌ្ឍសេដ្ឋកិច្ចក្នុងយុគសាកលូបនីយកម្ម នៅក្នុងប្រទេសអភិវឌ្ឍន៍ ដែលអ្នកស្រាវជ្រាវមានគោលដៅជាក់លាក់នៅកម្ពុជា។ អាស្រ័យដូច្នេះ ទើបប្រធានបទ " អភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងសម័យឧស្សាហកម្ម ៤.០ ករណីសិក្សាការ ប្រទេសកម្ពុជា " នេះត្រូវបានលើកយកមកសិក្សាអោយកាន់តែស៊ីជម្រៅនាពេលនេះ ទៅលើបច្ចេកវិទ្យា ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន(ICT) និងបដិវត្តឧស្សាហកម្មមានឥទ្ធិពលអ្វីខ្លះ ចំពោះ ប្រទេសអភិវឌ្ឍន៍ និងនៅប្រទេសកម្ពុជា ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

នៅគោលបំណងរួមនៃការសិក្សានេះគឺផ្តោតសំខាន់លើអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងសម័យឧស្សាហកម្ម ៤.០ ករណីសិក្សាប្រទេសកម្ពុជា " គោលបំណងជាក់លាក់នៃការសិក្សាស្រាវជ្រាវនេះ មានដូចខាងក្រោម៖ កំណត់អំពីស្ថានភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច នៅក្នុងសម័យឧស្សាហកម្ម៤.០ ករណីសិក្សាការប្រទេសកម្ពុជា ដោយសិក្សាអំពីកត្តាបច្ចេកវិទ្យាមានឥទ្ធិពលលើការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍ និងប្រទេសកម្ពុជា សិក្សាអំពីកត្តាការវិនិយោគផ្ទាល់ពីបរទេសមានឥទ្ធិពលលើការអភិវឌ្ឍសេដ្ឋកិច្ចទាំងនៅក្នុងប្រទេសអភិវឌ្ឍន៍ ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសកម្ពុជាសិក្សាអំពីកត្តាពាណិជ្ជកម្មមានឥទ្ធិពលលើការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងប្រទេសអភិវឌ្ឍន៍ ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសកម្ពុជា។បន្ថែមចំណេះដឹងដល់មិត្តអ្នកអាន អោយមានការយល់ដឹងកាន់តែទូលំទូលាយអំពីបដិវត្តន៍ឧស្សាហកម្ម៤.០។

## ៤.ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ក. ដែនកំណត់នៃការស្រាវជ្រាវ:

ការសិក្សានេះគឺផ្តោតទៅលើ ការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងសម័យឧស្សាហកម្ម៤.0ករណីសិក្សា ប្រទេសកម្ពុជា ។ ចំណែកប្រទេសកំពុងអភិវឌ្ឍន៍ចំនួន៣ គឺប្រទេសកម្ពុជា វៀតណាម និងថៃឡង់។ទិន្នន័យឧស្សាហកម្ម ពាណិជ្ជកម្ម ការវិនិយោគផ្ទាល់ពីបរទេស បច្ចេកវិទ្យា និងផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ៗរបស់ប្រទេសទាំង៨ ខាងលើគឺបានមកពីប្រភពធនាគារពិភពលោក(World Bank) ចន្លោះឆ្នាំ២០១១ ដល់ឆ្នាំ២០២០ នៅក្នុងប្រទេសដែលមានដូចជា ប្រទេស អាល្លឺម៉ង់ កម្ពុជា ចិន កូរ៉េខាងត្បូង ជប៉ុន សិង្ហបុរី ថៃឡង់ និងវៀតណាម។

### ខ. វិសាលភាពនៃការស្រាវជ្រាវ :

ការសិក្សាបានផ្តោតទៅលើកត្តាដែលមានឥទ្ធិពលទៅលើការអភិវឌ្ឍសេដ្ឋកិច្ច មានដូចជា កត្តា បច្ចេកវិទ្យា ឧស្សាហកម្ម ពាណិជ្ជកម្ម ការវិនិយោគផ្ទាល់ពីបរទេស(FDI)។ ការសិក្សានេះ ក៏បានផ្តោតទៅលើទស្សនៈ និងការយល់ឃើញរបស់សហគមន៍ចំពោះគុណសម្បត្តិ និងគុណវិបត្តិនៃការអភិវឌ្ឍសេដ្ឋកិច្ចក្នុងយុគសាកលូបនីយ

កម្មនៅប្រទេសកម្ពុជា។ ការអភិវឌ្ឍសេដ្ឋកិច្ចក្នុងយុគសាកលូបនីយកម្មសម្រាប់ប្រទេសកំពុងអភិវឌ្ឍ ជាពិសេសនៅប្រទេសកម្ពុជា ដែលត្រូវបានយកមកសិក្សាស្រាវជ្រាវ។

## ៥. វិធីសាស្ត្រស្រាវជ្រាវ

ដើម្បីសិក្សាពីប្រធានបទ **ការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងសម័យឧស្សាហកម្ម៤.0ករណីសិក្សា ប្រទេសកម្ពុជា** បានប្រើវិធីសាស្ត្របរិមាវិស័យ ក្នុងការស្រាវជ្រាវជា និន្នន័យទី២ ដើម្បីផ្ទៀង ពីទំនាក់ទំនងក្នុងសម័យឧស្សាហកម្ម៤.0 នៅប្រទេសកម្ពុជា និងបច្ចេកវិទ្យាឌីជីថល មួយចំនួន៖

- តម្រូវទិន្នន័យ ៖ ប្រើទិន្នន័យទី២ Secondary Date មកធ្វើការវិភាគ
- ទីកន្លែងដែលអាចប្រមូលទិន្នន័យមានដូចជា
  - Website មួយចំនួនដែលព័តមានមួយចំនួនដែលនៅក្នុងអ៊ីធឺណែត
  - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  - ឯកសារនិក្ខេបបទថ្នាក់បណ្ឌិត ផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច
  - ឯកសារមជ្ឈមណ្ឌលអភិវឌ្ឍកម្ពុជា(២០២១) ស្វែងយល់អំពីបដិវត្តឧស្សាហកម្មទី៤
  - កូរីឡេសិន (Correlation): ដើម្បីវិភាគអំពីទំនាក់ទំនងនៃអថេរសូចនាករកំណើនសេដ្ឋកិច្ច និង
  - ម៉ូដែលរីហ្គ្រេសិន (Regression) ដើម្បីវិភាគអំពីឥទ្ធិពលនៃសកលូបនីកម្ម ទៅលើកំណើននៃ ការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា (ទិន្នន័យវិភាគជាទិន្នន័យសេរីឆ្នាំក្នុងរយៈពេល១0ឆ្នាំ ចុងក្រោយពីឆ្នាំ២០០៨ ដល់ ២០១៧)។

៣. ការសសេរសមីការកំណើន (Regression) ទី៣

- GDP (it) = a1(Trade) (it) + b1(Industry) + c1(Technology) + d1(FDI) + e1CV (it) + u(i)+ v(it) (៣)
- ដែល GDP ជាសន្ទស្សន៍ផលិតផលក្នុងស្រុកសរុប(GDP) សម្រាប់ប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍ និងនៅប្រទេសកម្ពុជា
- ដែលអថេរឯកជ្ឈ (Independent Variables) មានដូចជា អថេរពាណិជ្ជកម្ម (Trade) ឧស្សាហកម្ម (Industry) ការវិនិយោគផ្ទាល់ពីបរទេស(FDI) និងបច្ចេកវិទ្យា(Technology) និងអថេរDependent Variable គឺផលិតផលក្នុងស្រុកសរុប (GDP)។
- u(i) ជាឥទ្ធិពលនៃប្រទេសដែលមិនបានធ្វើការសង្កេត ឬសិក្សា
- v(it) ជាភាពលម្អៀងដែលមានជាធម្មតានៅក្នុងម៉ូដែល
- CV: គឺជាក្រុមអថេរនៃសូចនាករសាកលូបនីយកម្មបន្ទាប់បន្សំផ្សេងៗទៀតក្រៅអំពីសន្ទស្សន៍

- ទាំង៤ ខាងលើមានដូចជា អថេរពាណិជ្ជកម្ម (Trade) ឧស្សាហកម្ម (Indusrty) ការវិនិយោគផ្ទាល់ពីរបរទេស(FDI)និងបច្ចេកវិទ្យា(Technology)និងអថេរ Dependent Variableគឺផលិតផលក្នុងស្រុកសរុប (GDP)។ ជាដើម។

(៣)ការពន្យល់អំពីសមីការកំណើន

- រូបមន្តសមីការកំណើនទី(៣)គឺពិនិត្យទៅលើឥទ្ធិពលការអភិវឌ្ឍសេដ្ឋកិច្ចក្នុងយុគសាកលូបនីយកម្ម បដិវត្តន៍ឧស្សាហកម្មទី៤.០ ប្រទេសកម្ពុជា ដែលអថេរឯកជ្យ(Independent Variables) មានដូចជា អថេរពាណិជ្ជកម្ម(Trade) ឧស្សាហកម្ម(Industry) ការវិនិយោគផ្ទាល់ពីរបរទេស(FDI) និងបច្ចេកវិទ្យា (Technology) និងអថេរ Dependent Variable គឺផលិតផលក្នុងស្រុកសរុប(GDP)។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់នៃប្រធានបទនេះ យើងមិនអាចកាត់ផ្តាច់ពីឥទ្ធិពលនៃសាកលូបនីយកម្ម និងសមាហរណកម្មសេដ្ឋកិច្ចតំបន់ និងពិភពលោកបាននោះទេ ដែលចង់ ឬមិនចង់ កម្លាំងនិន្នាការសាកលនៃបដិវត្តឧស្សាហកម្មទី៤.០នឹងមានឥទ្ធិពលទៅលើស្ទើរគ្រប់ទិដ្ឋភាពសង្គម សេដ្ឋកិច្ចកម្ពុជា ជាពិសេសវិស័យកម្មន្តសាល វិស័យដឹកជញ្ជូន និងការតភ្ជាប់វិស័យទូរគមនាគមន៍ និងការប្រាស្រ័យទាក់ទងវិស័យពាណិជ្ជកម្ម និងការធ្វើជំនួញតាមប្រព័ន្ធអ៊ិនធឺណេត ខ្សែច្រវ៉ាក់ផលិតកម្ម និងការផ្គត់ផ្គង់ឱ្យគ្នាទៅវិញទៅមកក្នុងតំបន់ក៏ដូចជា វិស័យអប់រំ និងការកសាងហេដ្ឋារចនាសម្ព័ន្ធ និងថ្នាលសម្រាប់ប្រពន្ធ័អប់រំ ឌីជីថល ដែលនឹងឈានទៅដល់ការផ្លាស់ប្តូរបែបឌីជីថល និងឌីជីថលលូបនីយកម្ម នៅក្នុងសង្គម សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានេះ បើតាម ហ៊ុន ម៉ានី។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃសាណារ គឺជាការលើកឡើងពីសេចក្តីសង្ខេបទៅលើជំពូកនីមួយៗ នៅក្នុងសាណានៃការស្រាវជ្រាវ ដែលក្នុងនោះ ត្រូវបានចែកជា ៣ជំពូក មានដូចខាងក្រោម៖

- ជំពូកទី១ ៖ ការរំលឹកទ្រឹស្តី និយមន័យ និងទ្រឹស្តីសំខាន់ៗ បដិវត្តឧស្សាហកម្ម៤.០សម្ទិផលនៃ បដិវត្តឧស្សាហកម្ម ៤.០ឧស្សាហកម្ម៤.០សម្រួលដល់រាជរដ្ឋាភិបាលកម្ពុជាផលិតផលក្នុងស្រុកសរុប ការប្រើប្រាស់បច្ចេកវិទ្យា(ICT)កំណើនការនាំចេញបច្ចេកវិទ្យាខ្ពស់។
- ជំពូកទី២ ៖ ស្ថានភាពទូទៅ នៃគោលនយោបាយអភិវឌ្ឍន៍ប្រទេសកម្ពុជា បដិវត្តឧស្សាហកម្មទី៤.០ នៅកម្ពុជាចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា របស់រដ្ឋាភិបាលការប្រើប្រាស់បច្ចេកវិទ្យារបស់សហគ្រាសតាមកម្រិតនៃភាពចាស់ទុំអំពីវិស័យឧស្សាហកម្ម។
- ជំពូកទី៣ ៖ ការសិក្សា នៃអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងសម័យឧស្សាហកម្ម៤.០កត្តាដែលមានឥទ្ធិពលលើការអភិវឌ្ឍសេដ្ឋកិច្ច នៃការវិនិយោគផ្ទាល់ពីបរទេស ។គោលនយោបាយការវិភាគទំនាក់ទំនងនៃកំណើនផលិតផល

ក្នុងស្រុកសរុបការវិភាគទំនាក់ទំនងនៃផលិតផលក្នុងស្រុកសរុប និងពាណិជ្ជកម្មទំនាក់ទំនងរវាងឧស្សាហកម្ម ការនាំចេញ-នាំចូល នៃប្រទេសកម្ពុជា។

- សេចក្តីសន្និដ្ឋាន និងអនុសាសន៍៖ បដិវត្តឧស្សាហកម្មទី៤.0នៅប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសកម្ពុជា ផលិតផលក្នុងស្រុកសរុប(GDP) មានទំនាក់ទំនងជាមួយកត្តាពាណិជ្ជកម្ម(Trade) និងឧស្សាហកម្ម(Industry)។ តាមលទ្ធផលដែលបានរកឃើញគឺត្រូវបានផ្តល់អនុសាសន៍ ដើម្បីធ្វើឱ្យការអភិវឌ្ឍសេដ្ឋកិច្ចក្នុងយុគសាកលូបនីយកម្មក្នុង និងប្រទេសអភិវឌ្ឍន៍ ជាពិសេសសម្រាប់ប្រទេសកម្ពុជា។

# ជំពូកទី១
# ការរំលឹកទ្រឹស្តី

# ជំពូកទី១
# ការរំលឹកទ្រឹស្តី

## ១. សេចក្តីផ្តើម

សាកលូបនីយកម្មមិនមែនជាទស្សនៈទានថ្មីទេ ឥទ្ធិពលរបស់វាលើបណ្តាប្រទេសនីមួយៗ បានពង្រីកនៅទស្សវត្សរ៍ឆ្នាំ១៩៨០។ ដំណើរការសាកលូបនីយកម្មបាននាំឱ្យមានការពឹងពាក់អាស្រ័យគ្នាទៅវិញទៅមកនៃសេដ្ឋកិច្ច និងពាណិជ្ជកម្មអន្តរជាតិ សេវាកម្ម និងទំនិញនានាមានការកើនឡើង។ ដំណើរការសាកលូបនីយកម្មធ្វើឱ្យឧស្សាហកម្មសេដ្ឋកិច្ចរីកចម្រើនជាមួយនឹងមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍសេដ្ឋកិច្ចនៃបណ្តាលប្រទេសកំពុងអភិវឌ្ឍន៍។ សាកលូបនីយកម្មត្រូវបានគេពន្យល់ជាមួយនឹងការអភិវឌ្ឍការដោះដូរ សេវាកម្ម ទំនិញ និងមូលធនឆ្លងព្រំដែន។ វារួមបញ្ចូលទាំងការអភិវឌ្ឍផ្នែកនយោបាយ សង្គម និងសេដ្ឋកិច្ចរវាងប្រទេស និងប្រទេស។ ការទទួលស្គាល់កាន់តែប្រសើរឡើងនៃជំនឿ និងសង្គម វប្បធម៌ខុសប្លែកគ្នា ហើយនឹងបញ្ហាភ្ជាប់អន្តរទំនាក់ទំនងគ្នា ដូចជា ការពង្រឹងទំនាក់ទំនងអន្តរជាតិ។

សាកលូបនីយកម្មត្រូវបានប្រើប្រាស់នៅក្នុងសកម្មភាពសេដ្ឋកិច្ចអន្តរជាតិ ដែលចាប់ផ្តើមតាំងពីចុងទសវត្សរ៍ឆ្នាំ១៩៨០។ បើតាម Bairoch និង Kozul-Wright (ឆ្នាំ១៩៩៦) សាកលូបនីយកម្មមានការឱ្យនិយមន័យភាគច្រើនយោងទៅលើការបើកចំហ និងការធ្វើសមាហរណកម្ម។ ការបើកចំហគឺសំដៅទៅលើប្រទេសនីមួយៗ ដែលចូលរួមនៅក្នុងសកម្មភាពសេដ្ឋកិច្ចអន្តរជាតិ។ សមាហរណកម្មសំដៅទៅលើការបញ្ចូលគ្នានៅប្រទេសផ្សេងៗ ដែលកើតឡើង តាមរយៈសកម្មភាពឆ្លងដែន និងពាណិជ្ជកម្មអន្តរជាតិ។[1] ចំណែកការហូរចូលសំដៅទៅលើការចលនាទំនិញ និងសេវាកម្ម តាមរយៈការធ្វើពាណិជ្ជកម្ម ការធ្វើអន្តរកម្មផ្នែកហិរញ្ញវត្ថុ ការធ្វើវិនិយោគទុន និងទីផ្សារ ប្តូរប្រាក់បរទេសរួមទាំងការចែករំលែកគំនិតផ្សេងៗ កម្មសិទ្ធបញ្ញា និងបច្ចេកវិទ្យា។ ការវិភាគគឺទៅលើទស្សនៈវិស័យសេដ្ឋកិច្ច និងសាកលូបនីយកម្ម ដែលផ្តោតយ៉ាងសំខាន់ទៅលើនយោបាយ សង្គមវិទ្យា និងមនុស្ស។[2] បើតាម Hay និង Marsh បានអះអាងថាមានការអភិវឌ្ឍសន្ទឹមឆ្ពោះទៅរកសាកលូបនីយកម្មជាជាងការហាក់ចុះយ៉ាងលឿន។ ចំណែកHirst និង Thom pson កត់សម្គាល់ថា អ្វីដែលបានលេចឡើងនោះ មិនមែនជាសេដ្ឋកិច្ចសកលលោកពិតប្រាកដនោះទេ។ ប៉ុន្តែការធ្វើសមាហរណកម្មក្នុងកម្រិតខ្ពស់រវាងអ្នកដើរតួជាមួយនឹងសេដ្ឋកិច្ចអន្តរជាតិ។ សេដ្ឋកិច្ចក្នុងការធ្វើសាកលូបនីយកម្មសំដៅទៅលើផលិតកម្ម ពាណិជ្ជកម្ម វិនិយោគទុន ហិរញ្ញវត្ថុ ការប្រកួតប្រជែង និងតម្រូវការ។[3]

---

1 Bairoch, P. & Kozul-Wright, et all, (1996). "Globalization Myths: Some historical reflections on integration, industrialisation and growth in the world economy".
2 Gundlach, E. & Nunnenkamp, et all, (1994). "Globalisation of Production and Markets", Kiel Institute, Germany.
3 Hay, C. & Marsh, D. ( 2000). "Introduction: Demystifying Globalization in Demystifying Globalization".

សាកលូបនីយកម្មខុសប្លែកពីគ្នា ដូចជា អន្តរជាតិនីយកម្ម (internationalization) សេរីនីយកម្ម (liberalization) សកលនីយកម្ម(universalization) ឬបស្ចិមប្រទេស(Westernization)។ សាកលូបនីយកម្ម គឺជាការរីករាលដាលនៃការឆ្លងកាត់ផែនដី ឬការផ្សារភ្ជាប់ដែនដីនឹងមនុស្ស។ អន្តរជាតិនីយកម្មសំដៅដល់ការកើនឡើងក្នុងប្រតិបត្តិការណ៍ និងការពឹងផ្អែកគ្នាទៅវិញទៅមករវាងប្រទេសនានា។ សេរីនីយកម្ម (liberalization) ចង្អុលប្រាប់អំពីដំណើរការផ្លាស់ប្តូរជាផ្លូវការនូវលក្ខខណ្ឌធនធានរវាងប្រទេសនានា។[4]

សាកលូបនីយកម្មឆ្លុះបញ្ចាំងឱ្យឃើញពីដំណើរការពឹងផ្អែកគ្នាទៅវិញទៅមក ក្នុងចំណោមប្រទេសផ្សេងៗ។ កត្តាចំនួន៤ ដែលជាកម្លាំងជំរុញសំខាន់ៗ នៅពីក្រោយការកើនឡើងនូវការពឹងផ្អែកគ្នាទៅវិញទៅមកដូចជា ពាណិជ្ជកម្ម ការធ្វើសេរីភាវូបនីយកម្ម ការវិនិយោគទុន និងការធ្វើនវានុវត្តន៍បច្ចេកវិទ្យា។ សាកលូបនីយកម្មជាការពឹងផ្អែកគ្នាទៅវិញទៅមកនៃកំណើនសេដ្ឋកិច្ចរបស់បណ្តាប្រទេសផ្សេងៗ នៅលើពិភពលោក។ តាមរយៈការបង្កើនទំហំ និងភាពចម្រុះនៃការធ្វើពាណិជ្ជកម្មឆ្លងដែនលើទំនិញ និងសេវាកម្មផ្សេងៗ និងការហូរចូលនូវមូលធនអន្តរជាតិ ការផ្ទេរបច្ចេកវិទ្យា និងព័ត៌មាន សាកលូបនីយកម្មបានបង្ហាញពីដំណើរការសកម្មភាពសេដ្ឋកិច្ច សង្គម និងនយោបាយ។[5]

សាកលូបនីយកម្មសំដៅទៅលើការកើនឡើងនៃការធ្វើសមាហរណកម្មរវាងតួអង្គផ្សេងៗគ្នារដ្ឋាភិបាល និងសង្គមនៅលើពិភពលោក។ សាកលូបនីយកម្មគឺជាដំណើរការដែលពង្រីកការធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់ប្រទេសជាច្រើនក៏ដូចជា ជំរុញសេដ្ឋកិច្ចពិភពលោក និងសាកលូបនីយកម្មនយោបាយ និងសេដ្ឋកិច្ច។ សាកលូបនីយកម្មក៏សំដៅទៅលើការលេចចេញនូវវប្បធម៌សកលដែលប្រជាជនកាន់ តែច្រើនឡើងៗ ដោយប្រើប្រាស់ទំនិញ និងសេវាកម្ម បង្កើតអាជីវកម្ម និងការប្រើប្រាស់ភាសាដូចគ្នា។ បើតាម Todaro និង Smith (២០០៦) ឱ្យនិយមន័យនៃសាកលូបនីយកម្មសេដ្ឋកិច្ចថា ជាការបើកចំហកាន់តែខ្លាំងឡើង នៃសេដ្ឋកិច្ចរបស់ប្រជាជាតិមួយឆ្ពោះទៅពាណិជ្ជកម្មអន្តរជាតិ លំហូរមូលធនអន្តរជាតិ និងការវិនិយោគផ្ទាល់ពីបរទេស (FDI)។ បើតាម Dreher(២០០៦) គេបានបែងចែកសាកលូបនីយកម្មជាបីផ្នែកគឺសាកលូបនីយកម្មសេដ្ឋកិច្ច សង្គម និងនយោបាយ។ សាកលូបនីយកម្មសេដ្ឋកិច្ច ជាការកើនឡើងនូវសាកលូបនីយកម្មអន្តរជាតិនៃទីផ្សារទំនិញ និងសេវាកម្ម ប្រព័ន្ធហិរញ្ញវត្ថុ ក្រុមហ៊ុន និងឧស្សាហកម្ម។ សាកលូបនីយកម្មវប្បធម៌ ត្រូវបានគេចាត់ទុកថា ជាការបង្រួបបង្រួមវប្បធម៌ក្នុងចំណោមប្រទេសជាច្រើន។ សាកលូបនីយកម្មនយោបាយ គឺជាការបង្រួមនៃប្រព័ន្ធនយោបាយ។ សាកលូបនីយកម្មគឺជាការបើកចំហពាណិជ្ជកម្ម។ បើតាមទ្រឹស្តីកំណើនបាន

---

Hirst, P.Q. & Thompson, G. (1996). “Globalization in Question, Polity”, Cambridge.

[4] Savina Gygli & Florian Haelg, et all., ( 2019 ) . “The KOF Globalization Index”

[5] Fischer, Stanley. (2003). "Globalization and Its Challenges ." American Economic Review, 93(2):1-30

បង្ហាញថាការជាប់ទាក់ទងជាវិជ្ជមានរវាងការបើកចំហពាណិជ្ជកម្ម និងកំណើនសេដ្ឋកិច្ចក្នុងរយៈពេលវែង។ ពាណិជ្ជកម្មអន្តរជាតិការបើកចំហពាណិជ្ជកម្មនៅក្នុងលក្ខខណ្ឌ សេដ្ឋកិច្ចពេញលេញ បង្កើនតម្លៃផលិតកម្មនៅក្នុងសេដ្ឋកិច្ច។[6]

សាកលូបនីយកម្មបើកឱកាសថ្មីសម្រាប់ការអភិវឌ្ឍទូលំទូលាយនៅទូទាំងពិភពលោក។ វាមិនត្រូវបានអភិវឌ្ឍស្មើភាពគ្នានោះទេពីព្រោះតំបន់មួយចំនួនកំពុងត្រូវបានដាក់បញ្ចូលទៅក្នុងសេដ្ឋកិច្ចពិភពលោកជាងតំបន់ផ្សេងទៀត មានភស្តុតាងនៃកំណើនយ៉ាងឆាប់រហ័ស និងកាត់បន្ថយភាពក្រីក។[7] សាកលូនីយកម្មសេដ្ឋកិច្ចកំពុងតែលូតលាស់យ៉ាងឆាប់រហ័សនោះ ចំណេះដឹងក៏មានការរីកចម្រើនយ៉ាងខ្លាំងដែរ។ ក្នុងយុគសម័យបច្ចុប្បន្ននេះ ត្រូវបានមើលឃើញយ៉ាងច្បាស់ថា គោលគំនិត ចំណេះដឹង និងចំណេះធ្វើដើរតួកាន់តែសំខាន់ឡើងៗនៅក្នុងការបង្កើតទ្រព្យសម្បត្តិ និងកំណើនសេដ្ឋកិច្ច និងឧត្តមភាពប្រៀបធៀបរបស់ប្រទេសនីមួយៗ។ វត្ថុធាតុដើម និងកម្លាំងរបស់មនុស្សមានតួនាទីកាន់តែស្តួចស្តើងទៅៗ នៅក្នុងដំណើរការនេះ មូលធនបញ្ញា(Intellectual Capital) បានក្លាយទៅជាកត្តាផលិតកម្មដ៏សំខាន់បំផុត។ នៅក្នុងសេដ្ឋកិច្ច ដែលពឹងផ្អែកលើចំណេះដឹង(Knowledge-based Economy) ទស្សនៈទានផលិតកម្ម(Concept of Production) កំពុងតែត្រូវបានជំនួសដោយទស្សនៈទានអរូបី(Concept of Intangibility) ដែលកំណត់ដោយមូលធនបញ្ញា សមត្ថភាពក្នុងការនិមិត្ត និងការបង្កើតគំនិត។ មូលធនមនុស្ស(Human Capital) ដែលប្រកបទៅដោយសមត្ថភាពជំនាញខ្ពស់ និងដោយនិមិត្តកម្មគឺជាកត្តាដ៏សំខាន់បំផុត ដែលធានានូវភាពប្រជែងឈ្នះរបស់ប្រទេសជាតិ។[8]

ជាការពិតដំណើរសាកលូបនីយកម្មត្រូវបានចាប់ផ្តើម នៅពេលដែលមានពាណិជ្ជកម្មអន្តរជាតិ តាម រយៈការនាំចេញ និងនាំចូលទំនិញ និងសេវាកម្ម ព្រមទាំងការផ្លាស់ប្តូរ និងលំហូរមូលធន ពលកម្ម និង សេវាកម្មផ្សេងៗទៀត រវាងប្រទេសមួយទៅប្រទេសមួយ និងរវាងតំបន់មួយទៅតំបន់មួយទៀត។ ជាពិសេសការផ្សារភ្ជាប់គ្នានូវសកម្មភាពទាំងអស់នេះ នៅទូទាំងពិភពលោក។ ជាក់ស្តែងចរន្តសាកលូបនីយកម្ម ត្រូវបានរំលេចកាន់តែប្រត្យក្សក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ។ សេដ្ឋកិច្ចពិភពលោកបានរីកលូតលាស់យ៉ាងខ្លាំង តាមរយៈការភ្ជាប់គ្នាកាន់តែជិតស្និតជាងមុននូវសកម្មភាពសេដ្ឋកិច្ចគួបផ្សំជាមួយបដិវត្តន៍ថ្មីៗ ក្នុងវិស័យបច្ចេកវិទ្យាព័ត៌មាន ដែលធ្វើឱ្យមានការដឹកជញ្ជូន និងទូរគមនាមន៍ទទួលបានវឌ្ឍនភាពយ៉ាងខ្លាំង និងលឿនឆ្ពោះទៅមុខ។

---

6 Deluna Roperto Jr and Chelly, Antiquisa, (2014). "Economic Growth Financial and Trade Globalization in the Philippines: A Vector Autoregressive Analyis".

7 Vjollca V. Hasani, (2012). "Significance of globalization in economic development", Case of Kosovo.

8 គាត ឈន់, អូន ពន្ធ័មុន្នីរ័ត្ន និងវង្សី វិស្សុត, (ខែមករា ឆ្នាំ១៩៩៩). "គ្រប់គ្រងបញ្ហាប្រឈម និងសកលភាវូបនីយកម្ម"

កត្តាខាងលើនេះ បានជំរុញឱ្យប្រទេសជាច្រើន ធ្វើបដិនិយ័តកម្ម(Deregulate) ពាណិជ្ជកម្ម និងការវិនិយោគ ព្រមទាំងធ្វើសេរីភាវូបនីយកម្មក្នុងវិស័យទីផ្សារហិរញ្ញវត្ថុ។ ម៉្យាងវិញទៀតពាណិជ្ជកម្មអន្តរជាតិ និងលំហូរមូលធនបានកើនឡើងក្នុងទំហំយ៉ាងលឿន។

## ១.១. និយមន័យ និងទ្រឹស្តីសំខាន់ៗ

### ទ្រឹស្តីសេដ្ឋកិច្ច ( Economy )

សេដ្ឋកិច្ចគឺជាប្រព័ន្ធពាណិជ្ជកម្ម និងឧស្សាហកម្ម ដែលទ្រព្យសម្បត្តិរបស់ប្រទេសមួយត្រូវបានបង្កើតឡើង និងប្រើប្រាស់។ សេដ្ឋកិច្ចគឺជាតំបន់នៃផលិតកម្ម ការចែកចាយ និងពាណិជ្ជកម្ម ក៏ដូចជាការប្រើប្រាស់ទំនិញ និងសេវាកម្ម។ សេដ្ឋកិច្ចគឺជាសំណុំដ៏ធំនៃផលិតកម្ម ការប្រើប្រាស់ និងសកម្មភាពទំនាក់ទំនងគ្នា ដែលជួយក្នុងការកំណត់ពីរបៀបដែលធនធានខ្វះខាតត្រូវបានបែងចែក។ ការផលិត ការប្រើប្រាស់ និងការចែកចាយទំនិញ និងសេវាកម្មត្រូវបានប្រើប្រាស់ដើម្បីបំពេញតម្រូវការជីវភាពរស់នៅ និងប្រតិបត្តិការនៅក្នុងសេដ្ឋកិច្ចដែលត្រូវបានគេហៅថាប្រព័ន្ធសេដ្ឋកិច្ចផងដែរ។ សេដ្ឋកិច្ចគឺគ្របដណ្តប់លើសកម្មភាពទាំងអស់ដែលទាក់ទងនឹងផលិតកម្ម ការប្រើប្រាស់ និងពាណិជ្ជកម្មទំនិញ និងសេវាកម្មនៅក្នុងតំបន់មួយ។ ការសម្រេចចិត្តទាំងនេះត្រូវបានធ្វើឡើងតាមរយៈការរួមបញ្ចូលគ្នានៃប្រតិបត្តិការទីផ្សារ និងការសម្រេចចិត្តសមូហភាព។ មនុស្សគ្រប់រូបពីបុគ្គលទៅអង្គភាព ដូចជាគ្រួសារ សាជីវកម្ម និងរដ្ឋាភិបាលចូលរួមក្នុងដំណើរការនេះ។

ពាក្យ "សេដ្ឋកិច្ច" (Economy) មានអត្ថន័យសំខាន់បី: ១. "សេដ្ឋកិច្ច" គឺជាទំនាក់ទំនងផលិតកម្ម ការប្រើប្រាស់ ការដោះដូរ និងការបែងចែកធនធានក្នុងសង្គម។ ឧទាហរណ៍សំណុំទំនាក់ទំនងផលិតកម្មក្នុងសេដ្ឋកិច្ចទីផ្សារ ខឿនសេដ្ឋកិច្ចជាតិ និងរចនាសម្ព័ន្ធសេដ្ឋកិច្ចទីផ្សារ ឬសេដ្ឋកិច្ចផែនការជាដើម។ ២.សេដ្ឋកិច្ចក្នុងអត្ថន័យជាការកំណត់អំពីអត្តសញ្ញាណវិស័យឬផ្នែកនៃការវាស់ទំហំសេដ្ឋកិច្ចមួយឧទាហរណ៍សេដ្ឋកិច្ចឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្ម សេដ្ឋកិច្ចជនបទ ដែលទាំងអស់នេះ ជាការកំណត់អត្តសញ្ញាណថា ជាវិស័យសេដ្ឋកិច្ច។ ៣.សេដ្ឋកិច្ចគឺជាកម្មវត្ថុសិក្សា ឬជាវិទ្យាសាស្ត្រ ឧទាហរណ៍វិទ្យាសាស្ត្រសេដ្ឋកិច្ច(Economics) សេដ្ឋកិច្ចនយោបាយ(Political Economy) ឬទ្រឹស្តីសេដ្ឋកិច្ចជាដើម(Economic theory)។[10]

អាដាមស្មីត ត្រូវគេចាត់ទុកថា ជាបិតាសេដ្ឋកិច្ច ដោយសារទស្សនៈវិស័យរបស់គាត់អំពីលទ្ធិមូលធននិយម ដែលជាប្រព័ន្ធសេដ្ឋកិច្ចមួយមានលក្ខណៈល្អប្រសើរបំផុត។ អាដាមស្មីត ថាការបែងចែកម្លាំងពលកម្ម (Division of labor) ជាផ្នែកមួយនៃកំណើនសេដ្ឋកិច្ច។ អាដាមស្មីត បានយល់ឃើញច្បាស់ពីផលវិបាករបស់សេដ្ឋកិច្ច។ នៅទសវត្សរ៍ឆ្នាំ១៧៣០ឧបករណ៍បន្ទះសំពត់ដេរបិទពីលើត្រូវបានគេច្នៃបង្កើតឡើង ដោយមាន

[10] គាត ឈន់, អូន ពន្ធ័មុន្នីរ័ត្ន និងវង្សី វិស្សុត, (ខែមករា ឆ្នាំ១៩៩៩). "គ្រប់គ្រងបញ្ហាប្រឈម និងសកលភាវូបនីយកម្ម"

ប្រសិទ្ធិភាពជាងក្រណាត់ត្បាញសំពត់ដោយដៃ។ ប្រការនេះធ្វើឱ្យដំណើរការត្បាញមានភាពរហ័សជាងមុន។ នៅឆ្នាំ១៧៦៩ ម៉ាស៊ីនរវៃកប្បាសត្រូវបានច្នៃបង្កើតឡើង ដែលអនុញ្ញាតឱ្យមនុស្សម្នាក់អាចរវៃអំបោះបានច្រើនដងក្នុងពេលជា មួយគ្នា។ នវានុវត្តន៍(Innovation) និងបច្ចេកវិទ្យាថ្មីៗ ធ្វើឱ្យកម្មករទទួលបានលទ្ធផលការងារប្រកបដោយ ផលិតភាពការងារខ្ពស់ ជាងការងារដែលធ្វើដោយគ្មានគ្រឿងម៉ាស៊ីន។

តាមទស្សនៈ អាដាមស្មីត ដោយសារឧស្សាហកម្មក្នុងស្រុកថ្មីៗពុំសូវមានបទពិសោធន៍ និងចំណេះដឹងក្នុងផលិតកម្មទំនិញ ជាងក្រុមហ៊ុនក្រៅស្រុកទាំងនោះនឹងប្រឈមមុខទល់នឹងគូរប្រកួតប្រជែងក្នុងប្រទេស។ អាដាមស្មីត បានបន្តទៀតថា ការអះអាងអំពីការនិយមនេះ ត្រឹមត្រូវប្រសិនបើប្រទេសមួយនឹងអភិវឌ្ឍជំនាញខាងផលិតកម្មនៅក្នុងឧស្សាហកម្មថ្មី ក្រុមហ៊ុនក្នុងស្រុកត្រូវតែទទួលបានការការពាររហូតដល់ក្រុមហ៊ុនទាំងនោះ ទទួលបានបទពិសោធន៍ចាំបាច់។ អាដាមស្មីត ប្រឆាំងនឹងការអះអាងដែលការពារឧស្សាហកម្មក្មេងខ្ចីនេះដោយគ្មានហេតុផលថា សកម្មភាពការពារនិយមនេះ នឹងបង្កើតឱ្យមានក្រុមហ៊ុនផ្តាច់មុខ ដែលគ្មានប្រសិទ្ធភាព ហើយធនធានវិនិយោគជាច្រើន និងត្រូវបង្វែរទៅឱ្យក្រុមហ៊ុនផ្តាច់មុខទាំងនោះ។ អាដាមស្មីត បានព្យាយាមពន្យល់អំពីប្រាក់ចំណូល ដែលត្រូវបានបែងចែកពីការផលិតទំនិញ និងសេវា។ ក្នុងនាមជាសេដ្ឋវិទូទី១ ដែលព្យាយាមពន្យល់ពីគោលការណ៍កំណត់ការបែងចែកប្រាក់ចំណូល អាដាមស្មីត បានរួមចំណែកយ៉ាងច្រើន។ ការរួមចំណែកទាំងនេះ ប្រមូលផ្តុំជុំវិញការវិភាគអំពីកត្តាកំណត់ថ្លៃទំនិញ និងកត្តាកំណត់ផលចំណូលរបស់ផលិតករទំនិញ។ អាដាមស្មីត បានចាប់ផ្តើមដោយញែកថ្លៃទំនិញទីផ្សារ និងថ្លៃទំនិញធម្មតា(National price of a goods)។ ថ្លៃទំនិញទីផ្សារជាថ្លៃដែលអតិថិជនបង់ឱ្យសម្រាប់ប្រតិបត្តិការសេដ្ឋកិច្ច។ ថ្លៃទំនិញទីផ្សារត្រូវបានកំណត់ដោយបរិមាណទំនិញថេរដែលគេនាំយកទៅទីផ្សារ ដោយសារតម្រូវការទំនិញទាំងនោះ។ ផ្ទុយទៅវិញថ្លៃទំនិញធម្មតា ជាថ្លៃសមតា (Equilibrium price) ឬជាថ្លៃឆ្ពោះទៅរកថ្លៃទំនិញទីផ្សារដែលផ្លាស់ទី ឡើងឬចុះ។

ដៃអរូបី(Invisible hard) អាដាមស្មីត ជាមូលដ្ឋាននៃទស្សនៈសេដ្ឋកិច្ចទីផ្សារដែលមានសេរីភាពបុគ្គលជាកត្តាសំខាន់។ សេរីភាពបុគ្គល មានន័យថា ជាសេរីភាពក្នុងការទិញទំនិញ ឬប្រើប្រាស់ទំនិញ និងសេវាកម្មដែលដាក់លក់ក្នុងក្របខណ្ឌប្រកួតប្រជែង ជាពិសេសមានសេរីភាពក្នុងការជ្រើសរើសទំនិញ និងសេវាដែលខ្លួនពេញចិត្ត និងមានថ្លៃសមស្រប។ សេរីភាពក្នុងនាមជាអ្នកលក់ ជាសេរីភាពក្នុងការជ្រើសរើសមុខរបរ ឬពង្រីកអាជីវកម្ម ជាអ្នកកំណត់ថ្លៃជាពិសេស សេរីភាពក្នុងហានិភ័យដែលអាចទទួលបរាជ័យ ឬទទួលជោគជ័យក្នុងសកម្មភាពរបស់ខ្លួន។ អត្ថន័យ "ដៃអរូបី" បញ្ជាក់បន្ថែមទៀតថា ប្រសិនបើមនុស្សទាំងអស់សុទ្ធតែល្អ សុទ្ធតែសប្បុរស សុទ្ធតែឧស្សាហ៍ព្យាយាម តាំងពីចាប់កំណើតមកនោះ ក្នុងដំណើរការសេដ្ឋកិច្ចពុំចាំបាច់មានកម្លាំងអ្វីមកសម្របសម្រួល ឬជួយជំរុញនោះទេ។ ប៉ុន្តែជាទូទៅបុគ្គលម្នាក់ៗច្រើនមានចរិតអាត្មានិយម លោភលន់អាចខ្ជិលច្រអូស និងមិនប្រាកដថា ពួកគេយល់ច្បាស់ពីអត្ថប្រយោជន៍នៃហានិភ័យ។ ទម្លាប់មិនល្អនេះ តម្រូវឱ្យ

មានកម្លាំងពីក្រៅសម្រាប់សម្របសម្រួល និងជំរុញសកម្មភាព អសកម្មនានា នោះគឺ "ដៃអរូបី" ដែលនាំមកនូវការកែប្រែជំរុញ និងលើកទឹកចិត្តដើម្បីឱ្យបុគ្គលម្នាក់ៗខិតខំព្យាយាមក្នុងមុខរបរចិញ្ចឹមជីវិត។ "ដៃអរូបី" ជាអ្នកធ្វើឱ្យមនុស្សចេះប្រឹងប្រែងព្យាយាមបំពេញការងារ ចេះបណ្តាក់ទុនរកស៊ី ជាពិសេស "ដៃអរូបី" មានកត្តាប្រកួតប្រជែង ដែលក្នុងធុរកិច្ចជំរុញឱ្យបុគ្គលម្នាក់ៗ ចេះចំណាយដោយប្រុងប្រយ័ត្ន ចេះសន្សំសំចៃ ចេះផ្សាយពាណិជ្ជកម្ម និងផ្តល់សេវាល្អៗ ជូនអតិថិជន។ ទន្ទឹមនឹងនោះ ភ្នាក់ងារនីមួយៗ ក្នុងសកម្មភាពសេដ្ឋកិច្ចរបស់ខ្លួនគិតតែផលប្រយោជន៍រៀងៗខ្លួនក្នុងការដាក់ទុនដើម្បីស្វែងរកប្រាក់ចំណេញ ពិតមែន ក៏ប៉ុន្តែធាតុពិតសកម្មភាពប្រកួតប្រជែងរបស់គេ និងសេរីភាពនានា បម្រើឱ្យយន្តការទីផ្សារមានដំណើរការបានតាមលំដាប់លំដោយ។ ភ្នាក់ងារសេដ្ឋកិច្ចនីមួយៗ មានតួនាទីជំរុញឱ្យមានការចាប់យកកម្លាំងជីវភាព(Dynamics) ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។ ដោយឡែកភ្នាក់ងារ សេដ្ឋកិច្ចនីមួយៗ រួមគ្នាជាផ្នែកមួយនៃការរីកចម្រើនរបស់សង្គមជាតិទាំងមូល។

ចំណែកឯ ទ្រឹស្តីរបស់ដាវីត រីការដូ(David Ricado) គឺជាទ្រឹស្តីសេដ្ឋកិច្ចដ៏វៃឆ្លាត។ គាត់បានអភិវឌ្ឍម៉ូដែលទ្រឹស្តីដើម្បីបង្ហាញអំពីភាពសាំញ៉ាំដែលក្នុងនោះដំណើរការទីផ្សារបានដឹកនាំ និងត្រួតពិនិត្យលើសេដ្ឋកិច្ចទីផ្សារសេរី និងការប្រកួតប្រជែង។ រីការដូ បានសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការរីកលូតលាស់នៃមូលធន តាមរយៈការសន្សំ(Saving) និងការវិនិយោគ(Investment)។ ថ្វីត្បិតតែការយល់ឃើញរបស់លោកដូចគ្នានឹង ម៉ាល់ទូស ប៉ុន្តែលោកមានទុទ្ធិដ្ឋិនិយមអំពីសុខុមាលភាពអនាគតរបស់មនុស្សភាគច្រើន។ ចំណែកឯទ្រឹស្តីរបស់កេនស៍ (John Mayanard Keynes) នយោបាយអសមតុល្យថវិកា គំនិតជាមូលដ្ឋានរបស់កេនស៍ ក្នុងការដោះស្រាយនិកម្មភាព និងការធ្លាក់ចុះនៃសេដ្ឋកិច្ចគឺត្រូវធ្វើអសមតុល្យថវិការដ្ឋាភិបាល។ ពោលគឺរដ្ឋាភិបាលត្រូវកាត់បន្ថយពន្ធលើប្រាក់ចំណូល ហើយទន្ទឹមនឹងនេះត្រូវបង្កើនការចំណាយទៅក្នុងលំហូរនៃចំណូល។ ទស្សនៈនេះតម្រូវឱ្យរដ្ឋាភិបាលធ្វើអសមតុល្យថវិកា ដោយប្រើគោលនយោបាយឱនភាពថវិកា ក្នុងការបោះពុម្ពរូបិយវត្ថុបន្ថែមទៀតដើម្បីហិរញ្ញប្បទានចំណាយ និងបង្កើនបរិមាណរូបិយវត្ថុ ដើម្បីចំណាយ និងបញ្ចូលទៅក្នុងលំហូរនៃចំណូលនៅក្នុងសេដ្ឋកិច្ច។ ប៉ុន្តែគំនិតនេះ មិនត្រូវបានទទួលយកដោយថ្នាក់ដឹកនាំនយោបាយ សភាជាតិអ្នកជំនួញ និងប្រជាជនទូទៅនោះទេ ដែលប្រកាន់យកនូវគំនិតធ្វើឱ្យមានថវិកាសមតុល្យ(Balanced Budget)។

## ១.២. ទ្រឹស្តីការអភិវឌ្ឍសេដ្ឋកិច្ច

ការអភិវឌ្ឍគឺជាដំណើរការនៃការអភិវឌ្ឍ ឬកំពុងអភិវឌ្ឍន៍។ ការអភិវឌ្ឍគឺជាព្រឹត្តិការណ៍ដែលបង្កើតជាដំណាក់កាលថ្មីមួយនៅក្នុងស្ថានភាពផ្លាស់ប្តូរ។ ការអភិវឌ្ឍគឺជាដំណើរការនៃការមានជាអត្ថិភាព ការបង្កើតអ្វីដែលថ្មី ឬប្រសើរជាងមុន។ ការអភិវឌ្ឍគឺជាដំណើរការដែលបង្កើតឱ្យមានការរីកចម្រើនវឌ្ឍនភាព ការផ្លាស់ប្តូរជាវិជ្ជមាន ឬការបន្ថែមសមាសធាតុរូបវន្ត សេដ្ឋកិច្ច បរិស្ថាន សង្គម និងប្រជាសាស្ត្រ។

### ១.២.១ និយមន័យអំពីការអភិវឌ្ឍសេដ្ឋកិច្ច( Economic Development )

ការសិក្សាសេដ្ឋកិច្ចនៃវិស័យសាធារណៈ ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម គឺជាដំណើរការដែលមានសុខុមាលភាពសេដ្ឋកិច្ច និងគុណភាពជីវិតរបស់ប្រទេសជាតិ តំបន់ សហគមន៍មូលដ្ឋាន ឬបុគ្គលម្នាក់ៗត្រូវបានកែលម្អទៅតាមគោលដៅ និងគោលបំណងដែលបានកំណត់។ ការអភិវឌ្ឍសេដ្ឋកិច្ចគឺជាដំណើរការដែលសេដ្ឋកិច្ចប្រទេសមួយមានចំណូលទាប និងសាមញ្ញ ត្រូវបានផ្លាស់ប្ដូរទៅជាសេដ្ឋកិច្ចឧស្សាហកម្មទំនើប។ ការអភិវឌ្ឍសេដ្ឋកិច្ចគឺជាកម្មវិធី គោលនយោបាយ ឬសកម្មភាពដែលស្វែងរកការកែលម្អមានសុខុមាលភាពសេដ្ឋកិច្ច និងគុណភាពជីវិតសម្រាប់សហគមន៍។ ការអភិវឌ្ឍសេដ្ឋកិច្ចគឺជាដំណើរការដែលសេដ្ឋកិច្ចមានការរីកចម្រើន ឬផ្លាស់ប្ដូរ និងមានភាពជឿនលឿន ជាពិសេសការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមត្រូវបានធ្វើឱ្យប្រសើរឡើង។

ការអភិវឌ្ឍសេដ្ឋកិច្ច(កំណើនសេដ្ឋកិច្ចឬការរីកចម្រើន) គឺសំដៅលើការបង្កើតទ្រព្យសម្បត្តិដែលត្រូវបានរកឃើញក្នុងផលប្រយោជន៍ និងការរីកចម្រើននៃសង្គម។ ការអភិវឌ្ឍសេដ្ឋកិច្ចគឺជាដំណើរការដែលប្រទេសមួយមានសេដ្ឋកិច្ចរីកចម្រើនក្លាយជាសេដ្ឋកិច្ចជឿនលឿន។

**ការអភិវឌ្ឍសេដ្ឋកិច្ច៖** ការអភិវឌ្ឍសេដ្ឋកិច្ច(Economic Development) គឺជាដំណើរការនៃការអភិវឌ្ឍទៅលើសុខុមាលភាពសេដ្ឋកិច្ច និងគុណភាពជីវិតរបស់ប្រជាជាតិ ឬតំបន់។ ពាក្យថា "ទំនើបភាវូបនីយកម្ម (Modernization) បច្ចឹមប្រទេស(Westernization)" និងជាពិសេស "ឧស្សាហូបនីយកម្ម (Industrialization)" គឺជាពាក្យផ្សេងទៀតដែលត្រូវបានប្រើជាញឹកញាប់ នៅពេលពិភាក្សាអំពីការអភិវឌ្ឍសេដ្ឋកិច្ច។ ចំណែកឯការអភិវឌ្ឍសេដ្ឋកិច្ចគឺជាគោលនយោបាយដែលមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពរបស់ប្រជាជន និងកំណើនសេដ្ឋកិច្ច ដែលជាបាតុភូតមួយនៃផលិតភាព ទីផ្សារ(Market Productivity) និងកំណើនផលិតផលក្នុងស្រុកសរុប(GDP)។ បើតាម Amartya Sen លើកឡើងថា "កំណើនសេដ្ឋកិច្ច(Economic Growth) គឺជាផ្នែកមួយនៃដំណើរការអភិវឌ្ឍសេដ្ឋកិច្ច"។

**កំណើន និងការអភិវឌ្ឍសេដ្ឋកិច្ច៖** កំណើនសេដ្ឋកិច្ចទាក់ទងនឹងការកើនឡើង ការអភិវឌ្ឍសេដ្ឋកិច្ចគឺទាក់ទងទៅនឹងការកើនឡើងលទ្ធផលរួមជាមួយនឹងភាពល្អប្រសើរនៃសុខុមាលភាពសង្គម និងនយោបាយរបស់ប្រជាជននៅក្នុងប្រទេសមួយ។ ការអភិវឌ្ឍសេដ្ឋកិច្ចរួមបញ្ចូលទាំងតម្លៃកំណើន និងសុខុមាលភាព។ តាមទ្រឹស្ដីនៃភាពអាស្រ័យ(Dependency Theorists) បានអះអាងថា ប្រទេសក្រីក្រពេលខ្លះ មានកំណើនសេដ្ឋកិច្ចជាមួយនឹងគំនិតផ្ដួចផ្ដើមអភិវឌ្ឍសេដ្ឋកិច្ចតិចតួច។ កំណើនធ្វើឱ្យមានការអភិវឌ្ឍ ពីព្រោះការកើនឡើងប្រាក់ចំណូលមួយចំនួន ត្រូវបានយកទៅចំណាយលើកត្តាអភិវឌ្ឍមនុស្ស(Human Development) ដូចជា ការអប់រំ និងសុខភាព។

ការអភិវឌ្ឍសេដ្ឋកិច្ចពឹងផ្អែកលើកំណើនសេដ្ឋកិច្ច(បរិមាណ) និងគុណភាពជីវិត(គុណភាព)។ កំណើនសេដ្ឋកិច្ច ត្រូវបានគេកំណត់អត្តសញ្ញាណផ្អែកលើចំណេះដឹង ពាណិជ្ជកម្ម ការសន្សំ។ សេដ្ឋកិច្ចផ្អែកលើចំណេះដឹងត្រូវបានរកឃើញភាពលេចធ្លោភាគច្រើននៃកំណើនសេដ្ឋកិច្ច បន្ទាប់មកគឺផ្អែកលើមូលដ្ឋានពាណិជ្ជកម្ម។ ការផ្អែកលើចំណេះដឹង និងការធ្វើពាណិជ្ជកម្មនៃកំណើនសេដ្ឋកិច្ច ជះឥទ្ធិពលវិជ្ជមាន ទាំងគុណភាពនៃគោលបំណង និងគុណភាពនៃជីវិត ក៏ដូចជាការកាត់បន្ថយជម្លោះក្នុងស្រុក និងអន្តរជាតិ។ ប្រទេសកំពុងអភិវឌ្ឍន៍ ឬអភិវឌ្ឍន៍ អនុវត្តគោលនយោបាយសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចអថេរនីមួយៗនៃចំណេះដឹង ព្រមទាំងសេដ្ឋកិច្ចផ្អែកលើពាណិជ្ជកម្ម ត្រូវបានបង្កើតឡើង គួរតែត្រូវពិនិត្យដោយប្រៀបធៀបទៅនឹងប្រទេសនីមួយៗសម្រាប់ភាពខ្លាំងរបស់គេ។

ការអភិវឌ្ឍសេដ្ឋកិច្ចផ្អែកលើធាតុផ្សំបីយ៉ាង ៖ កំណើនសេដ្ឋកិច្ច គុណភាពជីវិត និងការអភិវឌ្ឍមនុស្ស។ ទោះបីធាតុផ្សំទាំងបីនៃការអភិវឌ្ឍសេដ្ឋកិច្ចមានទំនាក់ទំនងគ្នាទៅវិញទៅមក ភាពខុសគ្នាក្នុងចំណោមកត្តាទាំងបី គឺកំណើនសេដ្ឋកិច្ចមានបរិមាណ រីឯកត្តាពីរផ្សេងទៀត បង្ហាញពីវិមាត្រគុណភាពនៃការអភិវឌ្ឍ។ ការអភិវឌ្ឍមនុស្ស(សន្ទស្សន៍អភិវឌ្ឍមនុស្ស) មានគោលបំណងពីគុណភាពជីវិត(QLI)។ ការប្រែប្រួលសេដ្ឋកិច្ចអន្តរជាតិជាច្រើន ជះឥទ្ធិពលដល់ការអភិវឌ្ឍសេដ្ឋកិច្ច។ បើតាម Goklany មានឥទ្ធិពលវិជ្ជមាននៃសាកលូបនីយកម្មសេដ្ឋកិច្ច ផ្អែកលើពាណិជ្ជកម្មសេរី បានជួយលើកកម្ពស់សុខុមាលភាពមនុស្ស។ សាកលូបនីយកម្មសេដ្ឋកិច្ចមានទំនាក់ទំនងគ្នាកាន់តែខ្លាំងឡើងៗ ជាមួយពិភពលោក។[9]

ការអភិវឌ្ឍសេដ្ឋកិច្ចសាកលូបនីយកម្មក្នុងពិភពលោក គឺជាការផ្លាស់ប្តូរសំខាន់ៗ ដែលបានកើតឡើងក្នុងរយៈពេលពីរទសវត្សរ៍កន្លងមក នៅក្នុងសេដ្ឋកិច្ចអន្តរជាតិ គឺការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស នៅក្នុងការប្រើប្រាស់ផលិតកម្ម ការវិនិយោគ សេវាកម្ម មូលធន និងបច្ចេកវិទ្យា។

ការអភិវឌ្ឍសេដ្ឋកិច្ច សំដៅទៅលើការធ្វើឱ្យប្រសើរឡើងនូវគុណភាពជីវិតមនុស្ស។ ការអភិវឌ្ឍសេដ្ឋកិច្ចមានន័យថា ការផ្លាស់ប្តូរសមត្ថភាពសេដ្ឋកិច្ចក្នុងស្រុក និងការបង្កើតទ្រព្យសម្បត្តិ(Kane &Sand,1988)។ ការអភិវឌ្ឍសេដ្ឋកិច្ចសំដៅទៅលើប្រព័ន្ធសេដ្ឋកិច្ចដែលអាចជាមធ្យោបាយ ដើម្បីបង្កើនទំហំដើមទុន ឬផលិតកម្មប្រចាំឆ្នាំ ដោយមិនគិតពីចំនួនប្រជាជន ប៉ុន្តែក្នុងន័យទំនើប ការអភិវឌ្ឍសេដ្ឋកិច្ចទាក់ទងនឹងប្រាក់ចំណូលពិតប្រាកដសម្រាប់មនុស្សម្នាក់ៗ។

ប្រសិទ្ធភាពជំរុញកំណើនសេដ្ឋកិច្ច និងបង្កើតការងារនៅក្នុងប្រទេសឧស្សាហកម្ម ជាឱកាសទៅកាន់ឧស្សាហូបនីយកម្ម ផ្តោតលើការនាំចេញ ក្នុងប្រទេសដែលមានប្រាក់ចំណូលខ្ពស់។ បើតាម Jacobson បាន

---

[9] Hae S Kim, (June 04, 2014). "Patterns of Economic Development in the World"

បញ្ជាក់ថា សេដ្ឋកិច្ចពិភពលោកថ្មី ដែលបានលេចចេញនៅក្រោមឆ័ត្រសាកលូបនីយកម្ម ត្រូវបានកំណត់ដោយបរិមាណ និងល្បឿននៃលំហូរមូលធនអន្តរជាតិ និងរចនាសម្ព័ន្ធផលិតកម្ម និងការស្វែងរក ទីផ្សារទំនិញ និងសេវាកម្ម ត្រូវបានដាក់បញ្ចូលគ្នា។ ដំណើរការនៃសាកលូបនីយកម្មកំពុងដើរតួនាទីយ៉ាងសំខាន់ ក្នុងការកំណត់ពាណិជ្ជកម្ម សេដ្ឋកិច្ច និងយុទ្ធសាស្ត្រអភិវឌ្ឍជាតិ។[10]

ការអភិវឌ្ឍសេដ្ឋកិច្ចសំដៅទៅលើដំណើរការនៃការធ្វើឱ្យប្រសើរឡើងនូវឱកាសសេដ្ឋកិច្ច និងគុណភាពនៃការរស់នៅរបស់មនុស្ស និងការកាត់បន្ថយភាពក្រីក្រ។ គ្រឿងបរិក្ខាប្រើប្រាស់ផ្នែកសុខាភិបាល ការអប់រំល្អប្រសើរ បរិស្ថានស្អាត និងការប្រើប្រាស់ធនធាន គឺជាសមាសធាតុសំខាន់នៃការអភិវឌ្ឍសេដ្ឋកិច្ច។ ម៉្យាងវិញទៀត ការបែងចែកទំនិញ និងសេវាកម្មត្រឹមត្រូវ គឺជាផ្នែកមួយនៃការអភិវឌ្ឍសេដ្ឋកិច្ចផងដែរ។ បណ្តាញចែកចាយល្អ ដែលរួមបញ្ចូលទាំងប្រព័ន្ធដឹកជញ្ជូនល្អ ផ្តល់លទ្ធផលមិនត្រឹមតែការដឹកជញ្ជូនទំនិញ និងសេវាកម្មបានល្អប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យប្រសើរឡើងនូវការផ្លាស់ប្តូរកម្លាំង ពលកម្ម។បើតាម Bell, (1987) ការអភិវឌ្ឍសេដ្ឋកិច្ចទាក់ទងទៅនឹងដំណើរការនៃការអភិវឌ្ឍ វាមិនត្រឹមតែផ្តោតលើមធ្យោបាយនៃការលើកកម្ពស់ការផ្លាស់ប្តូររចនាសម្ព័ន្ធ និងកំណើនសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែវាក៏ធ្វើឱ្យប្រសើរឡើងនូវសក្តានុពលនៃចំនួនប្រជាជន។ សាកលូបនីយកម្មបានផ្លាស់ប្តូរសេដ្ឋកិច្ចពិភពលោក តាមរយៈការបង្កើនពាណិជ្ជកម្មឆ្លងកាត់ព្រំដែន ការប្តូររូបិយប័ណ្ណ លំហូរមូលធនសេរី ចលនាប្រជាជន និងលំហូរព័ត៌មាន។ សាកលូបនីយកម្មបានបង្ហាញនូវគោលគំនិត ដែលមិនមានព្រំដែន និងសមាហរណកម្មសេដ្ឋកិច្ចពិភពលោក។ សាកលូបនីយកម្មបានផ្តល់គំនិតថ្មីដល់អាជីវកម្មនៅទូទាំងពិភពលោក។ ការផ្លាស់ប្តូរយុទ្ធសាស្ត្រជាច្រើន ត្រូវបានកើតឡើងនៅក្នុងអាជីវកម្ម។ បច្ចុប្បន្ននេះ វាជាទីផ្សារគោលដៅសម្រាប់អាជីវកម្មទូទាំងពិភពលោក។

**ទំនាក់ទំនងរវាងប្រាក់សន្សំ និងកំណើនសេដ្ឋកិច្ច៖** ការសន្សំកើនឡើង ជាមួយនឹងការកើនឡើងប្រាក់ចំណូល និងកំណើនសេដ្ឋកិច្ចបង្កើនចំនួនប្រាក់សន្សំផងដែរ។ យោងតាមគំរូកំណើនរបស់ Harrod-Domar សេដ្ឋកិច្ចនីមួយៗ ត្រូវតែសន្សំសមាមាត្រជាក់លាក់ នៃប្រាក់ចំណូលជាតិរបស់ខ្លួន ប្រសិនបើគ្រាន់តែជំនួសទំនិញមូលធនដែលបាត់បង់ ឬអន់ថយ (អគារ ឧបករណ៍ និងសម្ភារ) សម្រាប់កំណើនសេដ្ឋកិច្ច ពួកគេអាចសន្សំកាន់តែច្រើន និងវិនិយោគបានកាន់តែលឿន ពួកគេអាចមានការរីកចម្រើនបាន។ ការវិនិយោគថ្មីនឹងនាំមកនូវការ

[10] Vjollca V. Hasani, (2012)."Significance of globalization in economic development", Case of Kosovo

កើនឡើង នៅក្នុងលំហូរនៃផលិតផលជាតិសរុប(GNP)។ ដូច្នេះយន្តការនៃកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ ជាបញ្ហានៃការបង្កើនការសន្សំ និងវិនិយោគជាតិ។[11]

## ១.៣ ទ្រឹស្តីការវិនិយោគផ្ទាល់ពីបរទេស

ការវិនិយោគផ្ទាល់ពីបរទេស(FDI) គឺជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច នៅក្នុងសេដ្ឋកិច្ចពិភពលោកដែលកាន់តែរីកចម្រើន។ លំហូរការវិនិយោគផ្ទាល់ពីបរទេស(FDI) ត្រូវបានគេមើលឃើញថា ជាវិធីសាស្ត្រជំរុញការអភិវឌ្ឍ និងកំណើនសេដ្ឋកិច្ច ព្រមទាំងជួយក្នុងដំណើរការផ្លាស់ប្តូរដែលរួមមានទាំងកំណែទម្រង់សេដ្ឋកិច្ច និងវិធានការសេរីភាវូបនីយកម្ម អាជីវកម្មកំពុងដំណើរការនៅក្នុងប្រទេសនានា (Freeman,2002)។ ឥទ្ធិពលការវិនិយោគផ្ទាល់ពីបរទេស(FDI) ទៅលើកំណើនសេដ្ឋកិច្ចគឺវិជ្ជមាន។ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ការវិនិយោគផ្ទាល់ពីបរទេស(FDI) ត្រូវបានគេចាត់ទុកថា ជាមធ្យោបាយមួយដើម្បីផ្ទេរ បច្ចេកវិទ្យា និងដើមទុនពីបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងអភិវឌ្ឍន៍។ ការផ្តល់ការលើកទឹកចិត្តជាពិសេស ដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស(FDI) ជាញឹកញាប់កើតចេញពីការវិនិយោគផ្ទាល់ពីបរទេស ការផលិត ការផ្ទេរបច្ចេកវិទ្យា។ កំណើនសេដ្ឋកិច្ចរបស់ប្រទេសមួយ ត្រូវបានជះឥទ្ធិពលដោយកត្តាជាច្រើនសម្រាប់សេដ្ឋកិច្ចជាទូទៅ និងសេដ្ឋកិច្ចកំពុងរីកចម្រើនជាពិសេសការវិនិយោគផ្ទាល់ពីបរទេស(FDI)។ លំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស(FDI) បានបង្កើតឱកាសការងារ វាអាចផ្តល់អត្ថប្រយោជន៍ដល់កំណើនសេដ្ឋកិច្ចរបស់ប្រទេសកំពុងអភិវឌ្ឍន៍ តាមរយៈការផ្ទេរបច្ចេកវិទ្យាជឿនលឿន។

ការវិនិយោគផ្ទាល់ពីបរទេស(FDI) ជាប្រភពដ៏សំខាន់បំផុត នៃលំហូរធនធានខាងក្រៅទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ហើយបានក្លាយជាផ្នែកសំខាន់មួយនៃការបង្កើតដើមទុននៅក្នុងប្រទេសទាំងនេះ។ តួនាទីនៃការវិនិយោគផ្ទាល់ពីបរទេស(FDI) ត្រូវបានគេទទួលស្គាល់ជាទូទៅថា ជាកត្តាជំរុញកំណើននៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ (Falki, 2009)។ បង្កើនការ ផ្តល់ថវិកាសម្រាប់ការវិនិយោគក្នុងស្រុក លើកទឹកចិត្តដល់ការបង្កើតការងារថ្មី ពង្រឹងការផ្ទេរបច្ចេកវិទ្យា និងការកើនឡើងនូវកំណើនសេដ្ឋកិច្ច (Dritsaki & Stiakakis, 2014)។ ស្ថាប័នអន្តរជាតិនានា អ្នកសិក្សា អ្នកបង្កើតគោលនយោបាយ បានរកឃើញថា ការវិនិយោគផ្ទាល់ពីបរទេស(FDI) មានឥទ្ធិពលវិជ្ជមានយ៉ាងខ្លាំងទៅលើកំណើនសេដ្ឋកិច្ចរបស់ប្រទេសកំពុងអភិវឌ្ឍន៍។ ការវិនិយោគផ្ទាល់ពីបរទេស(FDI) ដើរតួយ៉ាងសំខាន់ ក្នុងការពង្រីកសេដ្ឋកិច្ចនៅពេលមានកង្វះខាតប្រាក់សន្សំក្នុងស្រុក។ការវិនិយោគទុនផ្ទាល់ពីបរទេស(FDI) ដើរតួយ៉ាងសំខាន់សម្រាប់កំណើនសេដ្ឋកិច្ច

---

[11] Muhammad Akram Ch, Muhammad Asim Faheem, et all,(2011).˝Globalization and its Impacts on the World Economic Development˝,

របស់ប្រទេស ជាច្រើន ហើយលំហូរនៃការវិនិយោគទុនផ្ទាល់ពីបរទេស(FDI) មានសារៈសំខាន់សម្រាប់ការធ្វើសមាហរណកម្មហិរញ្ញវត្ថុក្នុងតំបន់។ បើតាម Jalilian និង Weiss ឆ្នាំ២០០១ ក្នុងការសិក្សាស្រាវជ្រាវបានភ្ជាប់ទំនាក់ទំនងរវាង(FDI) និងការកាត់បន្ថយភាពក្រីក្រនៅតំបន់អាស៊ាន ហើយរកឃើញថាប្រហែល ៤០ភាគរយឥទ្ធិពលនៃការកាត់បន្ថយភាពក្រីក្រ។ ការវិនិយោគផ្ទាល់ពីបរទេស(FDI) វាបានជួយជំរុញកំណើនសេដ្ឋកិច្ច។ បើតាម Kee និង Mirza នៅឆ្នាំ២០០៣ បានបង្ហាញពីសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការក្នុងតំបន់ ក្នុងការជំរុញការវិនិយោគផ្ទាល់ពីបរទេស(FDI) នៅតំបន់អាស៊ាន។ កិច្ចខិតខំប្រឹងប្រែងក្នុងការទាក់ទាញការវិនិយោគ**ភាព**ផ្ទាល់ពីបរទេស(FDI)បានធ្វើឱ្យមានលក្ខណៈប្រកួតប្រជែងក្នុងចំណោមប្រទេសផ្សេងៗ ក្នុងតំបន់។ ជាទូទៅគេទទួលស្គាល់ថា បង្កើនការធ្វើសមាហរណកម្មហិរញ្ញវត្ថុ ទាក់ទងជាមួយនិងលំហូរមូលធន។[12]

### ១.៣.១ ទ្រឹស្តីការប្រកួតប្រជែង

**ទ្រឹស្តីឧត្តម ដាច់ខាត**(Absolute advantage) នៅឆ្នាំ១៧៧៦ **អាដាមស្មីត** ទ្រឹស្តីសេដ្ឋកិច្ចឈានមុខគេនៅក្នុងសៀវភៅ "The Wealth of Nations"។ **ស្មីត** បានផ្តល់នូវទ្រឹស្តីពាណិជ្ជកម្មថ្មីមួយដែលត្រូវបានគេហៅថា "អត្ថប្រយោជន៍ដាច់ខាត" ដែលផ្តោតលើសមត្ថភាពរបស់ប្រទេសមួយដើម្បីផលិតនូវផលិតផលដែលមានប្រសិទ្ធិភាពជាងប្រទេសមួយផ្សេងទៀត។ **ស្មីត** បានវាយប្រហារទៅលើការសន្មតរបស់អ្នកនិយមគោលនយោបាយសេដ្ឋកិច្ចពាណិជ្ជកម្ម។ **ស្មីត** បានអះអាងថាប្រទេសនានា មានសមត្ថភាពផ្សេងៗគ្នាក្នុងការផលិតទំនិញប្រកបដោយប្រសិទ្ធភាព។ **ស្មីត** បានលើកហេតុផលថា ពាណិជ្ជកម្មរវាងប្រទេសនានា មិនគួរត្រូវបានកំណត់ ឬរឹតត្បិតដោយគោលនយោបាយ ឬអន្តរាគមន៍របស់រដ្ឋាភិបាលឡើយ។ លោកបានបញ្ជាក់ថាពាណិជ្ជកម្មគួរតែហូរតាមបែបធម្មជាតិយោងទៅតាមកម្លាំងទីផ្សារ។ ប្រទេស ពីរ ប្រសិនបើប្រទេស(A) អាចផលិតបានទំនិញល្អហើយមានតម្លៃថោកជាង ឬលឿនជាង ឬបានទាំងពីរជាងប្រទេស(B) នោះ យ៉ាងហ្នឹងប្រទេស(A) មានគុណប្រយោជន៍ ហើយអាចផ្តោតលើជំនាញផលិតផលិតផលនោះ។ ស្រដៀងគ្នានេះដែរ ប្រសិនបើប្រទេស(B) មានជំនាញក្នុងការផលិតរបស់ល្អមួយផ្សេងទៀត ហើយល្អជាងវាក៏អាចផ្តោតលើជំនាញផងដែរ។ ដោយសារជំនាញនេះ ប្រទេសនានានឹងបង្កើតប្រសិទ្ធភាព ពីព្រោះកម្លាំងពលកម្មរបស់ពួកគេនឹងមានជំនាញ ជាងមុនដោយធ្វើការងារដូចគ្នា។ ការផលិតក៏នឹងកាន់តែមានប្រសិទ្ធភាពផងដែរ ពីព្រោះវានឹងមានការលើកទឹកចិត្តក្នុងការបង្កើតវិធីសាស្ត្រផលិត លឿន និងប្រសើរជាងមុន ដើម្បីបង្កើនជំនាញអត្ថប្រយោជន៍ ដាច់ខាតកើតឡើង ក្នុងការផលិតនូវផលិត ផលនៅពេលវាមានប្រសិទ្ធភាព ជាងប្រទេសដទៃទៀត ក្នុងការផលិត។ យោងតាម **ស្មីត** ប្រទេសនានាគួរតែមានជំនាញ ក្នុង

[12] តួនាទីរបស់ការអភិវឌ្ឍនវិស័យឯកជនសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន់ និងការធ្វើសមាហរណកម្មហិរញ្ញវត្ថុ ៖ទស្សនវិស័យរបស់អាស៊ាន

ការផលិតទំនិញដែលពួកគេ មានគុណសម្បត្តិដាច់ខាតបន្ទាប់មកធ្វើពាណិជ្ជកម្មទំនិញទាំងនេះជាមួយប្រទេសផ្សេងៗ ទៀត។

**ទ្រឹស្តីឧត្តមភាពប្រៀបធៀប(Comparative Advantage)** បញ្ហាប្រឈមចំពោះទ្រឹស្តីអត្ថប្រយោជន៍ដាច់ខាត គឺថាប្រទេសខ្លះ អាចផលិតទំនិញបានល្អប្រសើរ ហេតុដូច្នេះហើយ ទើបមានគុណសម្បត្តិនៅក្នុងវិស័យជាច្រើន។ ផ្ទុយទៅវិញប្រទេសមួយទៀត ប្រហែលជាមិនមានគុណសម្បត្តិដាច់ខាតដែលមានប្រយោជន៍ទេ។ ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមនេះ **ដាវីត រីការដូ** (David Ricardo) សេដ្ឋវិទូអង់គ្លេស បានណែនាំឱ្យមានទ្រឹស្តីនៃឧត្តមភាពប្រៀបធៀបក្នុងឆ្នាំ១៨១៧។ **រីការដូ** បានលើកហេតុផលថា ទោះបីជាប្រទេស(A) មានគុណសម្បត្តិដាច់ខាតក្នុងការផលិតផលិតផល និងជំនាញក៏ដោយ ក៏ពាណិជ្ជកម្មនៅតែអាចកើតមានរវាងប្រទេសទាំងពីរដែរ។ ឧត្តមភាពប្រៀបធៀបកើតឡើង នៅពេលដែលប្រទេសមួយមិនអាចផលិតផលិតផលប្រកបដោយប្រសិទ្ធភាពជាងប្រទេសដទៃ។ ប៉ុន្តែទោះយ៉ាងណាក៏ដោយ ក៏ប្រទេសនេះអាចផលិតផលិតផលបានល្អប្រសើរ និងមានប្រសិទ្ធភាពជាងផលិតផលផ្សេងទៀតដែរ។ ឧត្តមភាពប្រៀបធៀបផ្តោតលើភាពខុសគ្នានៃផលិតភាព ចំណែកឧត្តមភាពដាច់ខាតគឺផ្តោតទៅលើអត្ថប្រយោជន៍ដាច់ខាត ដែលផលិតផលផ្សេងៗមិនអាចជំនួសបានដូច។[13]

ឧត្តមភាពប្រៀបធៀប(Comparative Advantage)ពាណិជ្ជកម្មអន្តរជាតិ អាចជំរុញឱ្យមានកំណើនទិន្នផលជាទូទៅ។ ថ្លៃឱកាស(Opportunity Costs) គឺអថេរទំនិញ ឬសេវាដែលយើងតម្រូវ ប៉ុន្តែត្រូវបានបោះបង់ចោលដើម្បីទទួលបានអ្វីផ្សេង។ ឧត្តមភាពប្រៀបធៀប(Comparative advantage) គឺជាលទ្ធផលដែលប្រទេសមួយអាចផលិតនូវទំនិញណាមួយក្នុងថ្លៃឱកាសទាបជាងប្រទេសដែលយើងធ្វើពាណិជ្ជកម្មជា មួយ។ ឧត្តមភាពដាច់ខាត(Absolute advantage) សំដៅដល់សមត្ថភាពរបស់ប្រទេសមួយដែលអាចផលិតនូវផលិតផលជាក់លាក់ណាមួយប្រកបដោយអត្ថប្រយោជន៍លើសគេ។ លក្ខខណ្ឌពាណិជ្ជកម្ម(Term of Trade) ជាអត្រាដែលផលិតផលត្រូវបានដោះដូរគ្នា បានន័យថា ជាបរិមាណរបស់ផលិតផល(A) ដែលបោះបង់ដើម្បីបានផលិតផល(B) តាមរយៈការដោះដូរ។ ប្រទេសមួយនឹងមិនធ្វើពាណិជ្ជកម្មទេលើកលែងតែលក្ខខណ្ឌពាណិជ្ជកម្មមានភាពល្អប្រសើរជាងឱកាសក្នុងស្រុក។[14]

នៅដើមទសវត្សរ៍ឆ្នាំ១៩៥០ អ្នកសេដ្ឋកិច្ចអាមេរិក ដើមកំណើតរុស្ស៊ី Wassily W. Leontief បានសិក្សាពីសេដ្ឋកិច្ចសហរដ្ឋអាមេរិក បានកត់សម្គាល់ថា សហរដ្ឋអាមេរិកសម្បូរទៅដោយមូលធន ដូច្នេះគួរតែនាំចេញ

[13] International Trade Theory. (2016, Mar 17). Retrieved from [https://studymoose.com/international-trade-theory-essay](https://studymoose.com/international-trade-theory-essay)

[14] Schiller, (......) "Essentials of Economics".

ទំនិញដែលពឹងផ្អែកលើមូលធនឱ្យបានច្រើន។ ទោះជាយ៉ាងណាក៏ដោយការស្រាវជ្រាវដែលប្រើប្រាស់ទិន្នន័យជាក់ស្តែង បានបង្ហាញចំណុចផ្ទុយពីនេះ គឺសហរដ្ឋអាមេរិក កំពុងនាំចូលទំនិញដែលពឹងផ្អែកលើមូលធនយ៉ាងច្រើន។ យោងទៅតាមទ្រឹស្តីសមាមាត្រ បង្ហាញថា សហរដ្ឋអាមេរិក គួរតែនាំចូលទំនិញដែលពឹងផ្អែកលើកម្លាំងពលកម្ម ប៉ុន្តែផ្ទុយទៅវិញប្រទេសនេះ បាននាំចេញទំនិញទាំងនេះទៅវិញ។ ការវិភាគរបស់គាត់ត្រូវបាន គេស្គាល់ថា Leontief Paradox ដោយសារវាជាការផ្ទុយពីអ្វីដែលបានរំពឹងទុកដោយទ្រឹស្តីសមាមាត្រ។ នៅក្នុងឆ្នាំបន្តបន្ទាប់ អ្នកសេដ្ឋកិច្ចបានកត់សម្គាល់ជាប្រវត្តិសាស្ត្រនៅពេលនោះថា កម្លាំងពលកម្មនៅសហរដ្ឋអាមេរិក មានទាំងការផ្គត់ផ្គង់ថេរ និងមានផលិតភាពច្រើនជាងនៅប្រទេសជាច្រើនទៀត ជាហេតុធ្វើឱ្យវាសមហេតុផលក្នុងការនាំចេញទំនិញ ដែលពឹងផ្អែកលើកម្លាំងពលកម្ម។

ពាណិជ្ជកម្មអន្តរជាតិគឺជាភាពស្មុគស្មាញ និងបានជះឥទ្ធិពលលើកត្តាជាច្រើន ដែលតែងតែមានការផ្លាស់ប្តូរ។ ពាណិជ្ជកម្មមិនអាចត្រូវបានពន្យល់យ៉ាងល្អិតល្អន់ដោយទ្រឹស្តីតែមួយបានទេ ហើយសំខាន់ជាងនេះទៀត ការយល់ដឹងរបស់យើងអំពីទ្រឹស្តីពាណិជ្ជកម្មអន្តរជាតិនៅតែបន្តវិវឌ្ឍន៍ទៅមុខ។ កុំព្យូទ័រគឺជាផលិតផលថ្មីនៅទសវត្សរ៍ឆ្នាំ១៩៧០ និងបានអភិវឌ្ឍទៅជាផលិតផលអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ និង១៩៩០។ បច្ចុប្បន្នកុំព្យូទ័រកំពុងស្ថិតក្នុងដំណាក់កាលផលិតផលស្តង់ដា ហើយភាគច្រើននៃក្រុមហ៊ុន ផលិត និងដំណើរការនៃការផលិតត្រូវបានធ្វើនៅក្នុងប្រទេសដែលមានតម្លៃថោក នៅអាស៊ី និងម៉ិកស៊ិក។ ទ្រឹស្តីវដ្តជីវិតផលិតផលមិនសូវមានលទ្ធភាពពន្យល់ពីលំនាំពាណិជ្ជកម្មបច្ចុប្បន្ន ដែលការច្នៃប្រឌិត និងការផលិតកើតឡើងនៅជុំវិញពិភពលោកនោះទេ។ ឧទាហរណ៍ក្រុមហ៊ុនបានធ្វើការស្រាវជ្រាវ និងអភិវឌ្ឍនៅក្នុងទីផ្សារកំពុងអភិវឌ្ឍជាកន្លែងដែលកម្លាំងពលកម្មមានជំនាញខ្ពស់ និងតម្លៃថោកជាង។ ទោះបីជាបែបណាការស្រាវជ្រាវ និងការអភិវឌ្ឍ ជាធម្មតាត្រូវបានផ្សារភ្ជាប់ជាមួយនឹងដំណាក់កាលផលិតផលដំបូង ឬថ្មី។ ដូច្នេះហើយ ទើបផលិតផលប្រភេទនេះ ត្រូវបានផលិតបញ្ចប់នៅក្នុងប្រទេសកំណើត ប្រទេសកំពុងអភិវឌ្ឍ ឬប្រទេសដែលមានទីផ្សារកំពុងរីកចម្រើន ដូចជា ប្រទេសឥណ្ឌា និងចិន ដែលផ្តល់ជូនទាំងកម្លាំងពលកម្មជំនាញខ្ពស់ និងកន្លែងស្រាវជ្រាវថ្មី។

**ទ្រឹស្តីពាណិជ្ជកម្មអន្តរជាតិ**(International Trade) ដែលមានភាពលើសលុបនាពេលបច្ចុប្បន្នៈ ទ្រឹស្តីដែលមានការពន្យល់ពីការវិវដ្តនៃទ្រឹស្តីពាណិជ្ជកម្មអន្តរជាតិ ទ្រឹស្តីនេះបានជួយអ្នកសេដ្ឋកិច្ច រដ្ឋាភិបាល និងអ្នកជំនួញឱ្យយល់ច្បាស់ពីពាណិជ្ជកម្មអន្តរជាតិ និងវិធីលើកកម្ពស់ការគ្រប់គ្រង និងពាណិជ្ជកម្មអន្តរជាតិ។ បណ្តាប្រទេសមួយចំនួនមិនមានគុណសម្បត្តិដាច់ខាត នៅក្នុងវិស័យផលិតកម្ម ឬសេវាកម្មជាច្រើនហើយតាមពិតកត្តាផលិតកម្មមិនត្រូវបានចែកចាយរវាងប្រទេសនីមួយៗទេ។ ប្រទេសខ្លះ មានផលប្រយោជន៍មិនសមាមាត្រដោយសារកត្តាមួយចំនួន។ សហរដ្ឋអាមេរិកមានដីដាំដុះជាច្រើនដែលអាចត្រូវបានប្រើសម្រាប់ផលិតផលកសិកម្មជាច្រើន។ ប្រទេសនេះក៏មានលទ្ធភាពទូលំទូលាយក្នុងការទទួលបានដើមទុនផងដែរ។ ខណៈពេលដែលកន្លែងការងាររបស់

ខ្លួន ប្រហែលជាមិនមានតម្លៃថោកទេនោះ សហរដ្ឋអាមេរិកគឺជាប្រទេសមួយស្ថិតក្នុងប្រទេសដែលទទួលបានការអប់រំខ្ពស់បំផុតនៅលើពិភពលោក។ គុណសម្បត្តិទាំងនេះដែលស្ថិតនៅក្នុងកត្តាផលិតកម្មបានជួយឱ្យសហរដ្ឋអាមេរិកក្លាយជាប្រទេសមានសេដ្ឋកិច្ចធំជាងគេ និងមានជាងគេបំផុតនៅលើពិភពលោក។ សហរដ្ឋអាមេរិកក៏នាំចូលទំនិញ និងសេវាកម្មក្នុងបរិមាណយ៉ាងច្រើនផងដែរ ដោយសារអ្នកប្រើប្រាស់អាមេរិក ប្រើទ្រព្យសម្បត្តិរបស់ពួកគេដើម្បីទិញអ្វីដែលពួកគេត្រូវការ និងចង់បានដែលភាគច្រើននៃទំនិញទាំងនោះ ត្រូវបានផលិតនៅប្រទេសផ្សេងៗទៀត ដែលស្វែងរកការបង្កើតគុណសម្បត្តិប្រៀបធៀបផ្ទាល់ខ្លួន តាមរយៈកម្លាំងពលកម្មថោក។ នៅក្នុងការអនុវត្តជាក់ស្តែងរដ្ឋាភិបាល និងក្រុមហ៊ុនប្រើការរួមបញ្ចូលគ្នានៃទ្រឹស្តីទាំងនេះ ដើម្បីបកស្រាយនិន្នាការ និងការបង្កើតយុទ្ធសាស្ត្រ។ ទ្រឹស្តីទាំងនេះ បានបដិវត្តក្នុងរយៈពេល៥០០ឆ្នាំកន្លងមកនោះ នឹងបន្តផ្លាស់ប្តូរ និងសម្របខ្លួនជាមួយកត្តាថ្មីដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មអន្តរជាតិ។[15]

ប្រវត្តិនៃបដិវត្តឧស្សាហកម្ម

បច្ចេកវិទ្យា និងការច្នៃប្រឌិតបច្ចេកវិទ្យា គឺជាលក្ខណៈពិសេសដ៏សំខាន ជាប្រវត្តិសាស្ត្រនៃបដិវត្តឧស្សាហកម្ម។ នៅដើមសតវត្សរ៍ទី១៩ នេះផ្តោតលើ "ម៉ាស៊ីន"។ ប្រហែលឆ្នាំ១៩០០ អ្នកស្រាវជ្រាវបានសិក្សាចាប់ផ្តើមស្វែងយល់ពីធម្មជាតិ និងមូលហេតុនៃការបង្កើតថ្មីនៃបច្ចេកវិទ្យាដោយម៉ាក្ស វេប៊ើ។ នៅសម័យក្រោយសង្គ្រាម ការវាយតម្លៃដោយសុទិដ្ឋិនិយមបានមើលឃើញការច្នៃប្រឌិតផ្នែកបច្ចេកវិទ្យានៃបដិវត្តឧស្សាហកម្មជាចំណុចរបត់ដ៏សំខាន់ក្នុងប្រវត្តិសាស្ត្រនៃកំណើនសេដ្ឋកិច្ចលោកខាងលិច។ កំឡុង ពេលក្រោយឆ្នាំ១៩៧០ បានសង្កេតឃើញមានវិស័យកាន់តែទូលំទូលាយ រួមទាំងការច្នៃប្រឌិតផលិតផល ឧស្សាហកម្ម ឧស្សាហូបនីយកម្ម និងឧស្សាហកម្មផ្សេងៗ ដូចជា កប្បាស ដែក និងម៉ាស៊ីនចំហាយទឹក។

បច្ចេកវិទ្យា ជាពិសេសសម្រាប់ការប្រើប្រាស់ក្នុងឧស្សាហកម្ម គឺជាចំណុចកណ្តាលនៃការយល់ដឹង និងការស្រមើស្រមៃរបស់មនុស្សជាយូរមកហើយអំពីបដិវត្តឧស្សាហកម្ម(IR)ជាពាក្យដែលប្រើដើម្បីបង្ហាញពីការផ្លាស់ប្តូរដែលបានកើតឡើង នៅក្នុងសេដ្ឋកិច្ចអង់គ្លេស ចន្លោះពីឆ្នាំ១៧៦០ និងឆ្នាំ១៨៣០។ ប្រវត្តិវិទូសេដ្ឋកិច្ចអាស្តុន នៅពេលគាត់បង្ហាញ ភាពច្នៃប្រឌិតបដិវត្តឧស្សាហកម្ម(IR) ថាជា «រលកនៃឧបករណ៍ដែលវាយលុកពេញប្រទេសអង់គ្លេស»។ សារៈសំខាន់ជាបន្តបន្ទាប់នៃបច្ចេកវិទ្យាក្នុងការស្រាវជ្រាវទៅលើបដិវត្តឧស្សាហកម្ម ។

---

[15] International Trade Theory. (2016, Mar 17). Retrieved from https://studymoose.com/international-trade-theory-essay

### ១.៣.២ បដិវត្តឧស្សាហកម្មមាន៤ ដំណាក់កាល

#### ១.៣.១.១ បដិវត្តឧស្សាហកម្មទី១.០

បដិវត្តឧស្សាហកម្មទី១.០ ចាប់ផ្តើមនៅអំឡុងឆ្នាំ១៧៦០-១៨២០ រកឃើញដោយអ្នកប្រាជ្ញអឺរ៉ុប ដើម្បីផ្លាស់ប្តូរវិធីសាស្ត្រផលិតដោយដៃ ទៅជាផលិតកម្មដោយម៉ាស៊ីន។ ការប្រើប្រាស់ថាមពលចំហាយ និងថាមពលទឹក នៅក្នុងផលិតកម្មវាយនភ័ណ្ឌ ឧស្សាហកម្មដែក រ៉ែ និងកសិកម្ម នាវាដឹកជញ្ជូន និងរថភ្លើង ដើម្បីពង្រឹងកម្លាំងរុករកតាមផ្លូវទឹក ការផ្លាស់ប្តូរទំនិញ ការដឹកជញ្ជូនតាមផ្លូវដែក ដោយមានភាពងាយស្រួលជាងមុន។ ការប្រើប្រាស់បច្ចេកវិទ្យា ធ្វើឱ្យរោងចក្រអាចផលិតទំនិញបានច្រើន ផលិតភាពខ្ពស់ មនុស្សអាចផ្លាស់ប្តូរទីកន្លែងរស់នៅពីជនបទទៅទីក្រុងជាមួយនឹងការកកើតឡើងនូវទីក្រុងថ្មីៗជាច្រើនទៀត ធ្វើឱ្យវណ្ណៈកណ្តាលកើនឡើងនៅក្នុងសង្គម។ នៅសតវត្សរ៍ទី១៨ ឧស្សាហកម្ម១.០ បានរីកដុះដាលពេញទ្វីបអ៊ឺរ៉ុប និងទ្វីបអាមេរិក។ បច្ចេកវិទ្យាថ្មីៗជាច្រើន ត្រូវបានបង្កើតឡើង ឧស្សាហកម្មត្រូវបានផ្លាស់ ប្តូរពីការងារប្រើប្រាស់កម្លាំងមនុស្សជំនួសដោយម៉ាស៊ីន ឧបករណ៍បច្ចេកវិទ្យាយន្តកម្ម ដែលអាចជួយកំណត់ទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច ផ្នែកវាយនភណ្ឌ និងគ្រឿងដែក។ បដិវត្តឧស្សាហកម្មបានប្រែក្លាយជនបទទៅជាទីក្រុងទំនើបស៊ីវិលល័យ ជំរុញកម្លាំងសេដ្ឋកិច្ច និងការផ្លាស់ប្តូរទម្រង់សង្គម។

#### ១.៣.១.២ បដិវត្តឧស្សាហកម្មទី២.០

បដិវត្តបច្ចេកវិទ្យា(អំឡុងឆ្នាំ១៨៧០-១៩១៤) បានរកឃើញ និងបង្កើតប្រព័ន្ធអគ្គិសនីដែលមានតម្លៃទាប អាចប្រើប្រាស់សម្រាប់ជីវភាពប្រចាំថ្ងៃ។ ការចម្រាញ់រ៉ែដែកក្នុងទ្រង់ទ្រាយធំៗ ដើម្បីផលិតរថយន្ត ចាប់ផ្តើម Ford Model T នៅដើមឆ្នាំ១៩០០ ជាមួយនឹងបង្កើតខ្សែតេឡេក្រាមដំបូងសម្រាប់ការទំនាក់ទំនង។ បដិវត្តឧស្សាហកម្មទី២ ត្រូវបានសំគាល់ដោយការតភ្ជាប់ចរន្តអគ្គីសនី ធ្វើឱ្យមានកំណើនសេដ្ឋកិច្ចដ៏អស្ចារ្យ ជាមួយនឹងការកើតឡើងនូវផលភាព ប៉ុន្តែអាចប៉ះពាល់ដល់ការងារកម្មករដោយសារការប្រើប្រាស់ម៉ាស៊ីនកាន់តែទំនើប។ ការរកឃើញអគ្គិសនីគឺជាការរួមចំណែកក្នុងការបង្កើតបច្ចេកវិទ្យាថ្មីៗ និងទំនើប ដូចជា ទូរស័ព្ទ អំពូលភ្លើង ឧបករណ៍សម្រាប់ថត ផលិតសម្លេង (Phonograph) និងម៉ាស៊ីនចំហេះធ្វើឱ្យមានឥទ្ធិពលជាវិជ្ជមានដល់ការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គម។ ការប្រើប្រាស់ដែកថែបដែលជាវត្ថុធាតុដើមថ្មី ក្នុងផលិតកម្ម ការប្រើប្រាស់ធ្យូងថ្ម និងប្រេងឥន្ធនៈសម្រាប់ផលិតថាមពល ការបង្កើតខ្សែចង្វាក់ផលិតកម្ម ការបង្កើតអំពូភ្លើង ការបង្កើតទូរលេខ ទូរសព្ទ និងវិទ្យុ ការបង្កើតរថយន្ត កប៉ាល់ទឹក និងយន្តហោះ ដែលជាសមិទ្ធផលដ៏ធំធេងនៃផលិតកម្មទ្រង់ទ្រាយធំ (Mass Production) ។

### ១.៣.១.៣ បដិវត្តឧស្សាហកម្មទី៣.០

បដិវត្តឌីជីថល (Digital revolution) កកើតនៅពាក់កណ្ដាល សតវត្សរ៍ទី២០ (ក្រោយសង្គ្រាមលោកលើកទី២ ឆ្នាំ១៩៤៥) មានការរីកចម្រើនខ្លាំងផ្នែកឧស្សាហកម្ម និងបច្ចេកវិទ្យា ពិសេសការបង្កើតឧបករណ៍អេឡិចត្រូនិច ត្រង់ស៊ីស្ទ័រ មីក្រូប្រូសែសស័រ (Microprocessors)។ បដិវត្តឌីជីថល គឺជាការចាប់ផ្ដើមយុគព័ត៌មាន ការរីកចម្រើនបច្ចេកវិទ្យា(ឧបករណ៍អេឡិចត្រូនិច និងមេកានិច) ទៅជាឧបករណ៍ឌីជីថល ឌីជីថលកុំព្យូទ័រ(Computing digtital) និងបច្ចេកវិទ្យាគមនាគមន៍អ៊ីនធឺណេត ទូរសព្ទ័វៃឆ្លាត ការបោះពុម្ភៈ 3D (3D Printing) ថាមពលបៃតង ថាមពលកើតឡើងវិញ និងថាមពលនុយក្លេអែរ) នៅកំឡុងឆ្នាំ១៩៨០។ ប្រពន្ធ័ទូរគមនាគមន៍បានបង្កើតទូរសព្ទ័ចល័តដំបូង Motorola និងកុំព្យូទ័រ Macintosh ដោយក្រុមហ៊ុន Apple ការផ្លាស់ប្ដូរពីមេការនិច និងអេឡិចត្រូនិចអាណាឡូក (Analogue electronics) ទៅជាអេឡិចត្រូនិចឌីជីថល(Digital electronics) ចាប់ផ្ដើមពីចុងទស្សវត្សរ៍ឆ្នាំ៥០ ដល់ទស្សវត្សរ៍ឆ្នាំ៨០ ជាមួយនឹងការកកើត ឌីជីថលកុំព្យូទ័រ និងការរក្សាទិន្នន័យឌីជីថលរហូតមកដល់បច្ចុប្បន្ននេះ។ បដិវត្តឧស្សាហកម្មទី៣បានកែច្នៃ និងអភិវឌ្ឍគ្រឿងអេឡិចត្រូនិច កុំព្យូទ័រទៅជាកុំព្យូទ័រ លឿនលឿន (១៩៦០) កុំព្យូទ័រយួរដៃ(ឆ្នាំ១៩៧០-៨០) និងអ៊ិនធឺណិត(១៩៩០)។

### ១.៣.១.៤ បដិវត្តឧស្សាហកម្មទី៤.០

បើតាម Schwab ជឿថាបដិវត្តឧស្សាហកម្មទី៤.០ បាននិងកំពុងអភិវឌ្ឍតាំងពីដើមសតវត្សរ៍ទី២១ មកម្ល៉េះ ហើយដំណើរវិវដ្តនេះ គឺពឹងផ្អែកលើមូលដ្ឋានគ្រឹះរបស់បច្ចេកវិទ្យាឌីជីថល ក្នុងបដិវត្តឧស្សាហកម្មទី៣។ ភាពជឿនលឿន និងទំនើបផ្ដាច់គេនៃនវានុវត្តន៍របស់បច្ចេកវិទ្យាថ្មីៗ ដូចជា ប្រព័ន្ធវិភាគទិន្ន័យធំ(Big Data Analytics) បច្ចេកវិទ្យាណាណូ(Nano Technology) បច្ចេកវិទ្យា Gene Sequencing និង Quantum Computing ជាដើម។ បដិវត្តឧស្សាហកម្មទី៤.០ ត្រូវបានគេជឿថា នឹងច្របាច់បញ្ចូលគ្នាបច្ចេកវិទ្យារវាងពិភពរូបសាស្ត្រ ពិភពឌីជីថល និងពិភពជីវសាស្ត្រ។ ភាពរីកចម្រើននៃបច្ចេកវិទ្យា មានការសាយភាយយ៉ាងឆាប់រហ័ស ឧទាហរណ៍ ប្រព័ន្ធអ៊ិធឺណេត ចំណាយពេលតិចជាងមួយទសវត្សរ៍ប៉ុណ្ណោះក្នុងការរីកសាយភាយនៅទូទាំងពិភពលោក។ បើតាម Schwab បានគូសបញ្ជាក់របកគំហើញវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាថ្មីៗ មួយចំនួន ដែលបានរួមចំណែកដល់ការកកើតឡើងនៃការបដិវត្តឧស្សាហកម្មទី៤.០ ដោយបានរាប់បញ្ចូលជាក្រុមទៅតាមប្រភេទរូបសាស្ត្រ។ ការបោះពុម្ភ 3D បច្ចេកវិទ្យារ៉ូបូត Advanced Robotics និងរថយន្តដំណើរការស្វ័យប្រវត្តិ ប្រភេទឌីជីថលឧបករណ៍ភ្ជាប់ប្រព័ន្ធអ៊ិនធឺណេត (Internet of Things or IoT និងឧបករណ៍កំណត់សញ្ញា-Sensor) និងប្រភេទជីវសាស្ត្របច្ចេកវិទ្យា(Gene Sequencing និងGene Editing)។ ប្រភេទទាំងបីនេះ មានទំនាក់ទំនង និងពឹងផ្អែកលើដំណើរការអភិវឌ្ឍរវាងគ្នាទៅវិញទៅមក។ គួរកត់សម្គាល់ផងដែរថា ការអនុវត្ត ប្រព័ន្ធអ៊ីនធឺណេតរូបសាស្ត្រ (Cyber-Physical System) គឺជាអ្វីដែលធ្វើឱ្យបដិវត្តឧស្សាហកម្មទី៤.០។ ម៉ាស៊ីន និងឧបករណ៍វៃឆ្លាត

របស់បច្ចេកវិទ្យាថ្មីនេះ នឹងត្រូវការអន្តរគមន៍ពីមនុស្សតិចជាងមុនក្នុងការត្រួតពិនិត្យ និងប្រតិបត្តិការ ព្រោះវាត្រូវបានកំណត់ដើម្បីឱ្យធ្វើការទាក់ទងគ្នា និងដើរដោយស្វ័យប្រវត្តិ និងឯករាជ្យនៅក្នុងប្រព័ន្ធ។

បច្ចេកវិទ្យា និងនវានុវត្តន៍ថ្មីៗ ដូចជា បញ្ញាសប្បនិម្មិត និងបច្ចេកវិទ្យារ៉ូបូត(Robotics) បដិវត្តឧស្សាហកម្មនឹងជះឥទ្ធិពលយ៉ាងខ្លាំងលើគ្រប់ទិដ្ឋភាពនៃជីវិតរបស់មនុស្សរួមទាំងអភិបាលកិច្ច សង្គម និងរចនាសម្ព័ន្ធសេដ្ឋកិច្ច។ ទោះបីជាមានកាលានុវត្តភាព និងបច្ចេកវិទ្យាថ្មីៗ និងទំនើបៗ។ ការរីកចម្រើនឥតឈប់ឈរនៃបច្ចេកវិទ្យា និងនវានុវត្តន៍ថ្មីៗ បានរុញច្រានពិភពលោកទៅកាន់បដិវត្តន៍ឧស្សាហកម្មថ្មីមួយនាអំឡុងទសវត្សរ៍ទី១ នៃឆ្នាំ ២០០០ ដែលបានវិវឌ្ឍចេញពីបដិវត្តឧស្សាហកម្មទី៣ ដោយពឹងផ្អែកលើមូលដ្ឋានគ្រឹះបច្ចេកវិទ្យាឌីជីថល។ បដិវត្តឧស្សាហកម្ម៤.0 ដែលគេនិយមហៅថា ឧស្សាហកម្ម៤.0 ឬរោងចក្រឆ្លាតវៃបានចាប់ផ្តើមនៅឆ្នាំ២០១១ ក្នុងឱកាសតាំងពិពណ៌ពាណិជ្ជកម្ម Hannover Messe នៅក្រុង Hanover។

## ១.៤. បដិវត្តឧស្សាហកម្ម៤.0

បដិវត្តឧស្សាហកម្ម កើតឡើងដំបូងនៅចក្រភពអង់គ្លេស ជាសម័យកាលនៃឧស្សាហូបនីយកម្ម និងនវានុវត្តន៍នៃការបង្កើតថ្មី បាននាំឱ្យសេដ្ឋកិច្ចមូលនិយមកើតមានឡើង និងបានកែប្រែវិធីសាស្ត្រផលិតបែបបុរាណឱ្យទៅជាផលិតកម្មបែបឧស្សាហកម្ម(Chen,2019)។ បដិវត្តឧស្សាហកម្មបានធ្វើឱ្យមានការផ្លាស់ប្តូរទាំងស្រុងនៅតាមជនបទ និងទីក្រុងក្នុងតំបន់ជាច្រើននៃទ្វីបអឺរ៉ុប និងសហរដ្ឋអាមេរិកឱ្យក្លាយជាទីក្រុងឧស្សាហកម្ម ដែលបង្កើតប្រាក់ចំណូល និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស តាមរយៈផលិតកម្មផ្អែកលើឧស្សាហកម្ម (History, 2019)។ កម្រិតជីវភាពរបស់ប្រជាជនបានកើនឡើង ដោយសារមនុស្សកាន់តែច្រើន អាចរកប្រាក់ចំណូលបានខ្ពស់ នៅពេលធ្វើការក្នុងរោងចក្រ។ ម៉្យាងវិញទៀត ការប្រាស្រ័យទាក់ទង និងការដឹកជញ្ជូនមានភាពរហ័ស និងទំនើបជាង ដោយសារនវានុវត្តន៍បច្ចេកវិទ្យាថ្មីៗ ដែលត្រូវបានបង្កើតឡើងក្នុងសម័យកាលបដិវត្តឧស្សាហកម្ម។[16]

បដិវត្តឧស្សាហកម្ម បានដឹកកប់មធ្យោបាយប្រពៃណីនៅក្នុងការផលិត។ បដិវត្តឧស្សាហកម្មបានបំបាត់វិធីប្រពៃណីនៅក្នុងជម្រើសខាងសេដ្ឋកិច្ច។ បដិវត្តឧស្សាហកម្ម ដកឫសកែវនៃរបៀបចាស់ក្នុងជីវភាពរស់នៅរបស់មនុស្ស។ បដិវត្តឧស្សាហកម្មបាននាំមកមធ្យោបាយថ្មី ដែលមានលក្ខណល្អប្រសើរសម្រាប់មនុស្សមួយចំនួន នឹងរឹតតែអាក្រក់សម្រាប់មនុស្សមួយចំនួនទៀត។ បដិវត្តឧស្សាហកម្មបានផ្តល់ឱ្យនូវឧស្សាហករមូលធននិយមនូវកាលានុវត្តភាព ក្នុងការជួលជំនួសកម្លាំងពលកម្ម។ ផលិតកម្មដែលដើរដោយម៉ាស៊ីនមានប្រសិទ្ធភាពខ្ពស់ជាងយ៉ាងខ្លាំង បើប្រៀបធៀបទៅនឹងផលិតកម្ម ដែលប្រើដោយឧបករណ៍ហត្ថកម្មរបស់ពួកសិប្បករ។ ធាតុ

[16] តាន់ មុន្នីវិសាល "បដិវឌ្ឍឧស្សាហកម្មទី៤ (ឧស្សាហកម្ម៤.0)" លេខទី៣ ថ្ងៃទី ៤ខែមិថុនា ឆ្នាំ២០១៩ ទំព័រ១-២

ចេញ(Outputs) សម្រាប់កម្មករម្នាក់ៗ គឺមានកម្រិតខ្ពស់ ដែលធ្វើឱ្យពាណិជ្ជកម្មទាំងឡាយ បានទទួលចំណេញយ៉ាងខ្លាំង។ ដោយសារតែប្រាក់ចំណេញដ៏ខ្ពស់ឧស្សាហករមូលធននិយម បានទិញម៉ាស៊ីនកាន់តែច្រើនឡើង ហើយពួកគេបានទទួលបានប្រាក់ចំណេញកាន់តែច្រើន ទីបំផុតពួកគេក៏កសាងរោងចក្រចំនួនកាន់ច្រើនឡើងថែមទៀត។ ដំណើរការនៃឧស្សាហូបនីយកម្ម(Industrialization) ដែលធ្វើឱ្យផលិតភាពមានចំនួនកើនឡើងយ៉ាងលឿនបំផុត។[17]

### ១.៤.១ សម្ទិផលនៃ បដិវត្តឧស្សាហកម្ម ៤.0

បដិវត្តឧស្សាហកម្មទី៤.0 គឺជាកត្តាលីករយ៉ាងសំខាន់ ក្នុងការរួមចំណែក ជំរុញកំណើនប្រកបដោយចីរភាព ហើយក៏បាននឹងកំពុងជួយជំរុញផលិតភាព និងលើកកម្ពស់ភាពប្រកួតប្រជែងរបស់សហគ្រាសធុនមីក្រូ តូច និងមធ្យម ដែលជាឆ្អឹងខ្នងសេដ្ឋកិច្ច និងជាប្រភពសម្រាប់បង្កើតការងារ ការបង្កើតប្រាក់ចំណូល ព្រមទាំងសម្រាប់ការលើកកម្ពស់សហគ្រិនភាពក្នុងចំណោមស្ត្រី និងយុវជន។ ជារួមគ្នាផ្អែកលើស្មារតីនៃការមូលមតិរបស់វេទិការដើម្បីសម្រេចនូវការស្តារនិងជំរុញការងើបឡើងវិញនៃកំណើនសេដ្ឋកិច្ចប្រកប ដោយភាពធន់ យើងត្រូវការជាចាំបាច់នូវការពង្រឹងកិច្ចសហការអាស៊ីអឺរ៉ុបឱ្យកាន់តែពេញលេញ និងស៊ីជម្រៅបន្ថែមទៀត ជាពិសេសដោយផ្តោតលើកិច្ចការអាទិភាពមួយចំនួន រួមមាន (១)- ការរៀបចំនិងការអនុវត្តយុទ្ធសាស្ត្រ និងផែនការស្តារសេដ្ឋកិច្ចឡើងវិញក្នុងតំបន់(២)-ការធ្វើឌីជីថលសេដ្ឋកិច្ចសង្គម (៣)-ការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម (៤)-ការអភិវឌ្ឍធនធានមនុស្ស និង(៥)-ការដោះស្រាយបញ្ហាដែលកើតចេញពីការប្រែប្រួលអាកាសធាតុ។ ការបើកចំហនិងការគាំទ្រប្រព័ន្ធពាណិជ្ជកម្មពហុភាគីសម្រាប់កិច្ចសហការអភិវឌ្ឍរបស់យើង ដើម្បីលើកកម្ពស់ភាពទាក់ទាញនិងភាពអំណោយផលនៃបរិយាកាសសម្រាប់សកម្មភាពធុរៈកិច្ច ពាណិជ្ជកម្ម និងការវិនិយោគ សំដៅឆ្លើយតបទៅនឹងនិន្នាការនៃការផ្លាស់ប្តូរនៅក្នុងនិម្មាបនកម្មសេដ្ឋកិច្ច និងពាណិជ្ជកម្មសាកល។[18]

### ១.៤.២ ឧស្សាហកម្ម៤.0សម្រួលដល់រាជរដ្ឋាភិបាលកម្ពុជា

បានត្រៀមខ្លួនក្នុងការទទួលយកបដិវត្តឧស្សាហកម្ម៤.0 ដោយដាក់ចេញនូវយុទ្ធសាស្ត្រតាមក្រសួងស្ថាប័នទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិព្រមទាំងពង្រឹងការអភិវឌ្ឍធនធានមនុស្សបំពាក់គ្រឿងអេឡិចត្រូនិកតាមគ្រឹះស្ថានសិក្សានានា បណ្តុះបណ្តាលគ្រូបង្គោល និងអ្នកជំនាញ និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យ គ្រឹះស្ថានសិក្សាឯកជន ក្នុងការបញ្ចូលកម្មវិធី សិក្សាទាក់ទងនឹងបច្ចេកវិទ្យាឌីជីថល។ ជាក់ស្តែងការយល់ដឹងទាក់ទងនឹងការប្រើប្រាស់បច្ចេកវិទ្យា និងសម្ភារអេឡិចត្រូនិកនានាក្នុងកម្ពុជានៅមានកម្រិត

---

[17] ស៊ុំ សុចិន្តា "២០១០" ប្រវត្តិគំនិតសេដ្ឋកិច្ច សាកលវិទ្យាល័យជាតិគ្រប់គ្រង បោះពុម្ពលើកទី៤

[18] សុន្ទរកថាបិទ របស់ អូន ពន្ធ័មុនីរត្ន័ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០២១) "ការផ្លាស់ប្តូរគន្លងថ្មី លើកកម្ពស់ការចូលរួមក្នុងខ្សែចង្វាក់ តម្លៃសកល ពហុភាគីនិយម និងបដិវត្តន៍ឧស្សាហកម្មទី៤"

នៅឡើយ។ ការចាប់យកបដិវត្តឧស្សាហកម្ម៤.០ជាកត្តាដែលនឹងជួយឱ្យកម្ពុជា មានការរីកចម្រើនលើគ្រប់វិស័យ និងអាចក្លាយជាប្រទេសដែលមានចំណូលខ្ពស់ត្រឹមឆ្នាំ២០៥០។ ក្នុងន័យនេះកម្ពុជាបានត្រៀមលក្ខណៈមួយចំនួនដូចជា ការអភិវឌ្ឍធនធានមនុស្ស ការពង្រឹងធនធានហិរញ្ញវត្ថុ ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានវិទ្យា កាលានុវត្តភាព និងដាក់ចេញនូវយុទ្ធសាស្ត្រនានា ដើម្បីដោះស្រាយបញ្ហាប្រឈមឱ្យកាន់តែមានប្រសិទ្ធភាព និងទាញយកគុណប្រយោជន៍ជាអតិបរមាពីបដិវត្តឧស្សាហកម្ម៤.០។[19]

ក្នុងដំណើរការផ្លាស់ប្តូរបែបឌីជីថល តម្រូវឱ្យប្រទេសកម្ពុជាកំណត់ភាពខ្លាំង និងភាពខ្សោយរបស់ខ្លួនដោយសង្កត់ធ្ងន់ទៅលើការធ្វើអាទិភាវូបនីយកម្ម ដើម្បីកសាងបរិស្ថានមួយ និងប្រើប្រាស់ឱ្យអស់លទ្ធភាពនូវកាលានុវត្តភាព។ ក៏ដូចជាការជំនះឱ្យផុតពីផលវិបាកនានានៃបដិវត្តឧស្សាហកម្ម៤.០ និងសេដ្ឋកិច្ចឌីជីថល។ អនាគតវិស័យអប់រំ ការងារ ពាណិជ្ជកម្ម ឧស្សាហកម្ម និងបរិយាកាសនៃការរស់នៅក្នុងសង្គមកម្ពុជា ដែលមានភាពប្រែប្រួលក្នុងបរិស្ថានមួយដែលកាន់តែទំនើប និងជឿនលឿន។ យ៉ាងណាក្តី យើងមិនអាចបដិសេធបាន ឡើយថា ឌីជីថលូបនីយកម្ម និងស្វ័យប្រវត្តិកម្ម ដែលនឹងកាន់តែចូលជ្រៅក្នុងស្រទាប់សង្គមអាចនាំមកទាំងសក្តានុពល ក្នុងការប្រែក្លាយមុខមាត់កម្ពុជា ក្នុងយុគសាកលឌីជីថល ហើយក៏បាននាំមកនូវបញ្ហាប្រឈមមួយចំនួន។ ស្ថានភាពជាអ្នករងចាំទទួលការផ្ទេរ និងជាអ្នកប្រើប្រាស់បច្ចេកវិទ្យា ជាជាងអ្នកផលិត និងអភិវឌ្ឍន៍ដោយខ្លួនឯងរបស់ប្រទេសកម្ពុជា ដែលកំពុងស្ថិតក្នុងដំណាក់កាលនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានចាំបាច់ដើម្បីទទួលយកបដិវត្តឧស្សាហកម្ម។ ប្រទេសកម្ពុជា កំពុងដាក់ចេញនូវគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពពាក់ព័ន្ធជាច្រើន ក្នុងការសម្របខ្លួន និងការចាប់យកបដិវត្តឧស្សាហកម្មទី៤.០ ទោះជាស្ថិតក្នុងទស្សនៈទាននៅឡើយ ក៏គ្រប់ភាគីពាក់ព័ន្ធទាំងវិស័យសាធារណៈ និងវិស័យឯកជន ប្រតិបត្តិករ ស្ថាប័នស្រាវជ្រាវ អង្គការមិនមែនរដ្ឋាភិបាល និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ ក៏ដូចជាសាកលវិទ្យាល័យរដ្ឋ និងឯកជន។

**១.៤.៣ ការវិវត្តនៃបច្ចេកវិទ្យាឌីជីថល**

នៅក្នុងទិដ្ឋភាពបច្ចេកទេស បច្ចេកវិទ្យា និងវិទ្យាសាស្ត្រ ប្រទេសកម្ពុជាជាអ្នកប្រើប្រាស់បច្ចេកវិទ្យា ជាជាងជាអ្នកផលិត។ ប្រទេសកម្ពុជា ត្រូវការចាំបាច់ផ្តោតសំខាន់លើការអភិវឌ្ឍថ្នាលឌីជីថល និងហេដ្ឋរចនាសម្ព័ន្ធគាំទ្រវិស័យឌីជីថលដែលជាឆ្អឹងខ្នងនៃការផ្លាស់ប្តូរបែបឌីជីថលឆ្ពោះទៅកាន់ឧស្សាហកម្ម៤.០ ដែលរួមមានពង្រាយ និងពង្រីកបណ្តាញខ្សែកាបអុបទិក ខ្សែកាបអុបទិកបាតសមុទ្រ ការចែកចាយ និង បណ្តាញសេវាទូរស័ព្ទ បណ្តាញទំនាក់ទំនង បណ្តាញចរន្តអគ្គីសនី ដែលមាននិរន្តភាព និងតម្លៃថោក និងប្រព័ន្ធអ៊ីនធឺណេត

[19] តើកម្ពុជាគួរត្រៀមខ្លួនដូចម្តេច សម្រាប់បដិវត្តន៍ឧស្សហកម្មទី៤?

ដែលមានល្បឿនលឿន និងតម្លៃសមរម្យទៅដល់គ្រប់ទីកន្លែងទូទាំងប្រទេស។ម្យ៉ាងវិញទៀត កត្តាប្រឈមផ្សេងៗ កត្តាមនុស្ស សម្ភារៈ ចំណេះដឹង ចំណេះធ្វើ និងការវិនិយោគជារួមលើវិស័យបច្ចេកវិទ្យាដូចជា គម្លាតឌីជីថលរវាងទីក្រុង និងជនបទ លទ្ធភាពប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកកង្វះធនធាន និងវត្ថុធាតុដើម សម្រាប់ដំណើការផលិតកម្ម និងឧស្សាហកម្ម និងបច្ចេកវិទ្យាស្វ័យប្រវត្តិទំនើប កង្វះធនធានមនុស្ស និងចំណេះដឹងក្នុងវិស័យវិសកម្ម និងអភិវឌ្ឍបច្ចេកវិទ្យាដោយខ្លួនឯង សន្តិសុខប្រព័ន្ធអ៊ីនធឺណេត ក៏ដូចជា ការបង្កើតក្របខណ្ឌ និងបរិស្ថានអំណោយផល សម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យា រួមទាំងក្របខណ្ឌគតិយុត្ត និងការអនុវត្តគោលនយោបាយពាក់ព័ន្ធជាលក្ខណៈប្រទាក់ក្រឡាគ្នា នៅតែជាបញ្ហាចំបងសម្រាប់កម្ពុជា អាចអភិវឌ្ឍន៍ឈរលើមូលដ្ឋានបច្ចេកវិទ្យា។[20]

**១.៤.៣.១ បដិវត្តឧស្សាហកម្មជំរុញដល់កំណើនសេដ្ឋកិច្ច**

ការច្នៃប្រឌិតនៃបដិវត្តឧស្សាហកម្មអង់គ្លេស គឺជាការឆ្លើយតបទៅនឹងបរិយាកាសសេដ្ឋកិច្ច។ ការកើនឡើងនៃផលិតភាពដែលប្រែទៅជាកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព។ សតវត្សរ៍ទី១៩ គឺខុសគ្នាបដិវត្តឧស្សាហកម្មទី១ បានប្រែក្លាយទៅជាកំណើនសេដ្ឋកិច្ចទំនើប។ បើតាមម៉ក់យី ចំណេះដឹងវិទ្យាសាស្ត្របានកើនឡើងគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឱ្យមានការច្នៃប្រឌិតជាបន្តបន្ទាប់។ ការកែលម្អបច្ចេកវិទ្យាគឺពិតជាចំណុចស្នូលនៃបញ្ហានេះ។ ប្រាក់ចំណូលបន្តកើនឡើង ក្នុងរយៈពេលមួយរយឆ្នាំ និងបានបន្តពេញមួយសតវត្សរ៍ទី១៩។

កប្បាសគឺជាកត្តាឧស្សាហកម្មដ៏អស្ចារ្យនៃបដិវត្តឧស្សាហកម្ម Gerschenkron(១៩៦២) បានអះអាងថា កំណើនសេដ្ឋកិច្ចនៅក្នុងប្រទេសជឿនលឿនគឺផ្អែកលើការពង្រីកទំនិញប្រើប្រាស់ខណៈដែលកំណើននៅក្នុងប្រទេសដែលអន់ថយ គឺផ្អែកលើទំនិញអ្នកផលិតវត្ថុធាតុដើម។ សមិទ្ធផលដ៏អស្ចារ្យនៃបដិវត្តឧស្សាហកម្មអង់គ្លេស តាមពិតទៅការបង្កើតឧស្សាហកម្មដ៏ធំដំបូងគេ ដែលអាចផលិតគ្រឿងចក្របង្កើនផលិតភាពយ៉ាងច្រើន។ ការផលិតគ្រឿងម៉ាស៊ីន គឺជាមូលដ្ឋាននៃការអភិវឌ្ឍន៍ចំនួនបីដែលជាការពន្យល់នៃការបន្តកំណើនសេដ្ឋកិច្ចរហូតដល់សង្គ្រាមលោកលើកទីមួយ។ ការអភិវឌ្ឍន៍ទាំងនោះគឺៈ(១) យន្តការទូទៅនៃឧស្សាហកម្ម (២) ផ្លូវដែក និង (៣) កប៉ាល់ដែកដើរដោយចំហាយទឹក។ ដំបូងការលើកកម្ពស់ផលិតភាពនៅក្នុងសេដ្ឋកិច្ចអង់គ្លេសខ្លួនឯង ទីពីរ និងទីបី បានបង្កើតសេដ្ឋកិច្ចពិភពលោក និងការបែងចែកពលកម្មអន្តរជាតិ ដែលទទួលខុសត្រូវចំពោះការកើនឡើងយ៉ាងសំខាន់ ក្នុងកម្រិតជីវភាពរស់នៅ ទូទាំងទ្វីបអឺរ៉ុប។ បច្ចេកវិទ្យាចំហាយទឹក បានធ្វើឱ្យមានកំណើនផលិតភាពការងារនៅក្នុងប្រទេសអង់គ្លេស ក្នុងពាក់កណ្ដាលនៃសតវត្សរ៍ទី១៩ (Crafts, ២០០៤)។

[20] តើកម្ពុជាគួរត្រៀមខ្លួនដូចម្ដេច សម្រាប់បដិវត្តន៍ឧស្សហកម្មទី ៤?

ឧស្សាហកម្មនៅសតវត្សរ៍ទី១៩ គឺចេញពីឧស្សាហកម្មធ្យូងថ្ម និងបានវិវឌ្ឍន៍ហេតុបង្កើនផលិតភាពក្នុងសតវត្សរ៍ទី១៩ ដោយផ្អែកលើម៉ាស៊ីនចំហាយទឹក និងដែកតម្លៃថោក។ ទាំងពីរនេះ ដូចដែលយើងបានឃើញមានទំនាក់ទំនងជិតស្និទ្ធនឹងធ្យូងថ្ម។ ម៉ាស៊ីនចំហាយត្រូវបានបង្កើតឡើង ដើម្បីប្រើប្រាស់ធ្យូងថ្ម។ មានទំនាក់ទំនងជាច្រើនទៀត៖ ជាពិសេសផ្លូវដែក គឺជាចេញពីឧស្សាហកម្មធ្យូងថ្ម។ ផ្លូវដែកត្រូវបានសាកល្បងនិងធ្វើឡើងដំបូងនៅសតវត្សរ៍ទីដប់ប្រាំពីរ ដើម្បីដឹកធ្យូងថ្មពីអណ្តូងរ៉ែទៅកាន់ព្រែកឬទន្លេ។ នៅពេលដែលវាត្រូវបានបង្កើតឡើង និងឆ្លងកាត់បទពិសោធន៍ជាបន្តបន្ទាប់ហេតុកែលម្អផ្លូវមកជាផ្លូវរថភ្លើង។ ជាលទ្ធផលផ្លូវដែកត្រូវបានបង្កើតឡើង នៅសតវត្សរ៍ទីដប់ប្រាំបី។ លើសពីនេះទៀត តម្រូវការសម្រាប់ការដឹកជញ្ជូនបានផ្តល់ទីផ្សារដំបូងសម្រាប់ក្បាលរថភ្លើង។ មិនមានទីផ្សារសម្រាប់យានជំនិះដែលដើរដោយថាមពលចំហាយទឹកទេ ដោយសារផ្លូវមិនមានក្រាលកៅស៊ូ និងមិនស្មើគ្នា។ ប៉ុន្តែផ្លូវដែកបានផ្តល់ឱ្យរថភ្លើង និងក្បាលរថភ្លើងដំបូងគេអាចដំណើរការបាន។ លោកចច ស្តេហ្វេនសាន់ បានបង្កើត រ៉ក់កែត សម្រាប់ការសាកល្បង Rainhill គាត់បានសាកល្បងគំនិតរចនា នៅក្នុងក្បាលរថភ្លើង ដែលគាត់កំពុងសាងសង់សម្រាប់ផ្លូវរថភ្លើងធ្យូងថ្ម។ ការធ្វើពាណិជ្ជកម្ម និងនវានុវត្តន៍ បច្ចេកវិទ្យាបានលើកកម្ពស់ការអភិវឌ្ឍបន្ថែមទៀត ខណៈដែលការចំណាយលើការស្រាវជ្រាវ និងអភិវឌ្ឍន៍(R&D) ក៏មានការកើនឡើងផងដែរ។[21]កប្បាសបានដើរតួនាទីគាំទ្រ ការរីកចម្រើននៃឧស្សាហកម្មវិស្វកម្មគឺវាបានកើនឡើងដល់ទំហំដ៏ធំ ដែលជាលទ្ធផលនៃការប្រកួតប្រជែងសកល។ នៅដើមសតវត្សរ៍ទី១៨ ចក្រភពអង់គ្លេស ផលិតបានតែផ្នែកតូចមួយនៃកប្បាសរបស់ពិភពលោក។ អ្នកផលិតដែលសំខាន់ៗ គឺនៅអាស៊ី។ ជាលទ្ធផលការបត់បែនតម្លៃនៃតម្រូវការសម្រាប់កប្បាសអង់គ្លេសមានទំហំធំ។ ប្រសិនបើអង់គ្លេស អាចក្លាយជាការប្រកួតប្រជែង នោះវាអាចពង្រីកផលិតកម្មយ៉ាងខ្លាំង ដោយជំនួសផលិតកររបស់ប្រទេសឥណ្ឌា និងចិន។ យន្តការបាននាំទៅរកលទ្ធផលគឺឧស្សាហកម្មដ៏ធំ នគរូបនីយកម្មធំទូលាយ និងការជំរុញដល់សេដ្ឋកិច្ចដែលមានប្រាក់ឈ្នួលខ្ពស់។ បើតាម ជេកាតរូម ការច្នៃប្រឌិតដ៏ល្បីរបស់បារាំងនាសម័យនោះ បានកាត់បន្ថយថ្លៃដើម ផលិតក្រណាត់ និងប៉ាក់ហើយបានជំរុញឱ្យមានការកើនឡើងនៃទិន្នផល។ ប៉ុន្តែការប៉ាក់មិនមែនជាឧស្សាហកម្មសកលទេ ហើយការបត់បែននៃតម្រូវការមានកម្រិតតិចតួច ដូច្នេះការពង្រីកទិន្នផលនៅមានកម្រិត។ ហេតុផលមួយដែលបច្ចេកវិទ្យាកប្បាសរបស់អង់គ្លេស មានការផ្លាស់ប្តូរយ៉ាងខ្លាំងនោះ គឺឧស្សាហកម្មកប្បាសជាឧស្សាហកម្មសកលដែលមានតម្រូវការឆ្លើយតបនឹងតម្លៃច្រើនជាងវាយនភ័ណ្ឌផ្សេងទៀត។ ការរីកចម្រើន និងទំហំនៃឧស្សាហកម្មកប្បាស រួមជាមួយនឹងការពឹងផ្អែកលើគ្រឿងម៉ាស៊ីនបានទ្រទ្រង់ឧស្សាហកម្មវិស្វកម្ម ដោយផ្តល់ឱ្យនូវទីផ្សារដ៏ធំ និងរីកចម្រើនសម្រាប់ឧបករណ៍។ ប្រវត្តិនៃ

[21] Karl Marx Capital (2018). From Industrial Revolution to modern economic growth

ឧស្សាហកម្មកប្បាស គឺជាផ្នែកមួយនៃការកែលម្អការរចនាម៉ាស៊ីនដោយឥតឈប់ឈរ ទីមួយជាមួយនឹងការកាត់ និងបង្វិល ហើយក្រោយមកជាមួយនឹងការត្បាញ។ ម៉ាស៊ីនដែលបានកែលម្អ ឧបករណ៍មានតម្រូវការវិនិយោគខ្ពស់។ នៅពាក់កណ្តាលសតវត្សរ៍ទី១៩ ម៉ាស៊ីនបានរីករាលដាលពាសពេញផលិតកម្មរបស់ចក្រភពអង់គ្លេស វាបានធ្វើឱ្យកើនឡើងនៃប្រាក់ចំណូលជាបន្តបន្ទាប់។[22]

នៅក្នុងប្រវត្តិសាស្ត្រនៃបច្ចេកវិទ្យាក្នុងអំឡុងពេលបដិវត្តឧស្សាហកម្ម។ ការច្នៃប្រឌិតនៅសតវត្សរ៍ទី១៨ គឺជាការកែលម្អ ដែលបង្កើនតម្រូវការដើមទុន និងថាមពលទាក់ទងនឹងកម្លាំងពលកម្ម។ ដោយសារដើមទុន និងថាមពលមានតម្លៃថោកនៅចក្រភពអង់គ្លេស វាពិតជាមានតម្លៃក្នុងការអភិវឌ្ឍ ការច្នៃប្រឌិត ហើយមានតម្លៃប្រើប្រាស់វាក្នុងទម្រង់ដើម។ ទម្រង់ទាំងនេះ មិនមានប្រសិទ្ធភាពក្នុងការចំណាយនៅកន្លែងផ្សេងទៀត ដែលកម្លាំងពលកម្មមានតម្លៃថោកជាងថាមពល។ ទោះជាយ៉ាងណាក៏ដោយ វិស្វករអង់គ្លេសបានកែលម្អបច្ចេកវិទ្យានេះ។ ដោយសារការប្រើប្រាស់ធ្យូងថ្មនៃថាមពលចំហាយទឹកបានធ្លាក់ចុះពី៣៥ផោនក្នុងមួយសេះក្នុងមួយម៉ោងមកត្រឹម ៥ផោន ដើម្បីអនុវត្តថាមពលចំហាយទឹកក្នុងការប្រើប្រាស់កាន់តែច្រើនឡើង។ ការរីករាលដាលហួសពីឧស្សាហកម្មវាយនភណ្ឌកប្បាស នៅពាក់កណ្តាល សតវត្សរ៍ទី១៩។ ការធ្លាក់ចុះនៃការប្រើប្រាស់ធ្យូងថ្ម មានន័យថា ជាការរីករាលដាលតាមភូមិសាស្ត្រ ក៏ដូចជាការរីករាលដាលផ្នែកឧស្សាហកម្ម។ ម៉ាស៊ីនចំហាយគ្មានប្រសិទ្ធភាព បែបទំនើប មិនមែនជាបច្ចេកវិទ្យា "សមរម្យ" សម្រាប់ប្រទេសដែលធ្យូងថ្មមានតម្លៃថ្លៃនោះទេ។ នៅពេលដែលម៉ាស៊ីនចំហាយកាន់តែសន្សំសំចៃ វាត្រូវបាននាំយកទៅប្រទេសកាន់តែច្រើន សូម្បីតែធ្យូងថ្មមានតម្លៃថ្លៃក៏ដោយ។ តាមរបៀបនោះ បដិវត្តឧស្សាហកម្ម បានរីករាលដាលពាសពេញពិភពលោក។ ភាពប៉ិនប្រសប់នៃវិស្វកម្មអង់គ្លេស មិនត្រឹមតែធ្វើឱ្យមានឧត្តមភាពប្រៀបធៀបរបស់ចក្រភពអង់គ្លេសទេ។ វាជារឿងសំខាន់ដែលការច្នៃប្រឌិតរបស់ជនជាតិអង់គ្លេស នៅសតវត្សរ៍ទី១៨ បង្កើតបានដែកដែលមានតម្លៃថោក និងម៉ាស៊ីនចំហាយ។[23]

### ១.៤.២.២ បដិវត្តឧស្សាហកម្ម៤.0 លើវិស័យសេដ្ឋកិច្ច និងអប់រំ

គោលបំណងចម្បងនៃបដិវត្តឧស្សាហកម្ម៤.0 គឺបំពេញនូវតម្រូវការរបស់អតិថិជនម្នាក់ៗដែលបានផ្តល់គុណប្រយោជន៍ដល់វិស័យមួយចំនួន ដូចជា ការគ្រប់គ្រងលើការបញ្ជាទិញ ការស្រាវជ្រាវ និងការអភិវឌ្ឍបេសកកម្មនៃផលិតកម្ម និងតម្រូវការប្រើប្រាស់ និងកែច្នៃផលិតកម្ម(Neugebauer, Hippmann, Leis,&Landherr,2016)។ បដិវត្តឧស្សាហកម្ម បានផ្តល់នូវអត្ថប្រយោជន៍ច្រើនដល់ការអភិវឌ្ឍប្រព័ន្ធ

[22] Karl Marx Capital (2018). From Industrial Revolution to modern economic growth

[23] Karl Marx Capital (2018). From Industrial Revolution to modern economic growth

ព័ត៌មានវិទ្យា និងបច្ចេកវិទ្យា(ICT)។ បដិវត្តឧស្សាហកម្ម៤.0 គឺជាចក្ខុវិស័យមួយដែលនាំឱ្យមានការគិតច្បាស់លាស់ លើការបង្កើតនូវប្រព័ន្ធអ៊ីធឺណេត ឧស្សាហកម្មអនឡាញ ផលិតកម្មឆ្លាតវៃ និងផលិតកម្មអនឡាញ (Vaidya, Ambad, & Bhosle, 2018)។ ភាពខុសគ្នារវាងឧស្សាហកម្ម៤.0 និងផលិតកម្មកុំព្យូទ័រ គឺជាតួនាទីរបស់មនុស្សក្នុងផលិតកម្ម។ ឧស្សាហកម្ម៤.0 មាន តួនាទីដ៏សំខាន់ ដែលបង្ហាញពីសកម្មភាពការងាររបស់កម្មករ ក្នុងដំណើរការផលិតកម្មដែលផលិតកម្ម កុំព្យូទ័រ មានតម្រូវការកម្មករ តិចក្នុងដំណើរការផលិតកម្ម។ យោងតាមការលើកឡើងរបស់ក្រុមស្រាវជ្រាវ Sipsas, Alexopoulos, Xanthakis, និង Chryssolouris (2016) គំរូនៃឧស្សាហកម្ម៤.0 មានមុខងារសំខាន់ក្នុងការតភ្ជាប់គ្នានៃសម្ភាររូបវ័ន្តមួយចំនួន ដូចជា៖ សេនសឺ (sensors) ឧបករណ៍ (device) និងទ្រព្យសហគ្រាស (enterprise assets)។

លទ្ធផលស្រាវជ្រាវរបស់ Vaidya, Ambad, និង Bhosle (២០១៨) បង្ហាញថា បដិវត្តឧស្សាហកម្ម ៤.0 បានផ្តល់នូវអត្ថប្រយោជន៍ លើការអប់រំ ដូចជា ការបណ្តុះបណ្តាល និងអភិវឌ្ឍ សមត្ថភាព ផ្នែក បច្ចេកវិទ្យា ពត៌មានវិទ្យា និងបច្ចេកវិទ្យា។ បដិវត្តឧស្សាហកម្ម៤0. បានរួមចំណែកក្នុងការអភិវឌ្ឍ គុណភាពអប់រំ ដែលសំដៅការបង្កើនសមត្ថភាពធនធានមនុស្ស។ នេះបើតាម Damayanti,(២០២១) បានបង្ហាញថា ការស្រាវជ្រាវរបស់ Ahmad, Segaran, & Sapry,(២000) បានលើកឡើងពីបដិវត្តឧស្សាហកម្មទី៤.0 ក្នុងការពង្រឹងគុណភាពប្រព័ន្ធអប់រំ ប្រសិទ្ធភាពនៃការរៀនសូត្រប្រសិទ្ធផលនៃចំណេះដឹងលើការងារគ្រប់គ្រង និងគំនិតច្នៃប្រឌិតប្រកបដោយសមត្ថភាពនវានុវត្តន៍។

បដិវត្តឧស្សាហកម្ម៤.0 លើវិស័យអប់រំ សេដ្ឋកិច្ច និងប្រព័ន្ធ ICT ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពមនុស្សផ្នែកប្រព័ន្ធព័ត៌មានវិទ្យា និងបច្ចេកវិទ្យា Vaidya, Ambad, & Bhosle,២០១៨។ បង្កើនសមត្ថភាពធនធានមនុស្ស Damayanti, ២០២១។ ការពង្រឹងគុណភាពប្រព័ន្ធអប់រំៈ ប្រសិទ្ធភាពនៃការរៀនសូត្រប្រសិទ្ធផលនៃចំណេះដឹងលើការងារគ្រប់គ្រង និងគំនិតច្នៃប្រឌិតប្រកបដោយសមត្ថភាពនវានិវត្តន៍ Ahmad, Segaran, &Sapry, ២០២០។ ឧស្សាហកម្មផលិតកម្មធ្វើឱ្យមានការផ្លាស់ប្តូរនូវផលិតផលពីប្រជាករទៅការបញ្ជាទិញ។ ការរៀបចំ និងពិនិត្យលើសង្វាក់ផលិតកម្ម ដើម្បីបង្កើនតម្រូវការផលិត ផលិតកម្មបច្ចេកវិទ្យា និងការប្រើប្រាស់បច្ចេកវិទ្យាក្នុងឧស្សាហកម្មធ្វើឱ្យមានការកើនឡើងនូវចង្វាក់ផលិតកម្ម។ ចក្ខុវិស័យនៃការគិតច្បាស់លាស់ លើប្រព័ន្ធអ៊ីធឺណេត ផលិតកម្មឆ្លាតវៃ និងផលិតកម្មអនឡាញ Vaidya, Ambad, & Bhosle,២០១៨។ បដិវត្តនៃម៉ាស៊ីនធម្មតាទៅជាម៉ាស៊ីនស្វ័យប្រវត្តិដើម្បីអភិវឌ្ឍសកម្មភាពរួម និងការគ្រប់គ្រងលើការថែទាំ Lee, Kao, & Yang, ២០១៤។ ការកសាងនៃវេទិកាផលិតកម្មបើកចំហ និងស្អាតសម្រាប់ការផ្តល់ព័ត៌មានបណ្តាញឧស្សាហកម្ម Bahrin, Othman, Nor, & Azli, ២០១៦។

បដិវត្តឧស្សាហកម្ម៤.0 មានឥទ្ធិពលលើការអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យា និងបច្ចេកវិទ្យា ដែលសំដៅទៅលើចក្ខុវិស័យនៃគិតច្បាស់លាស់ ដោយផ្តោតសំខាន់លើប្រព័ន្ធអ៊ីធឺណេត ផលិតកម្មឆ្លាតវៃ និងផលិតកម្ម។ បើតាម Lee, Kao, & Yang បានបង្ហាញថាបដិវត្តឧស្សាហកម្ម៤.0ទៅលើបដិវត្តនៃម៉ាស៊ីន ធម្មតាទៅជាម៉ាស៊ីនស្វ័យប្រវត្តិ ដើម្បីអភិវឌ្ឍសកម្មភាពរួម និងការគ្រប់គ្រងលើការថែទាំ។ បដិវត្តឧស្សាហកម្ម៤.0 បានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដល់ការអភិវឌ្ឍវិស័យអប់រំ សេដ្ឋកិច្ច និងប្រព័ន្ធពត៌មានវិទ្យា និងបច្ចេកវិទ្យា។ សម្រាប់បរិបទកម្ពុជា បដិវត្តឧស្សាហកម្ម៤.0 បានជួយលើកកម្ពស់ការអភិវឌ្ឍគុណភាពអប់រំ បង្កើន វិស័យសេដ្ឋកិច្ចឱ្យមានការរីកចម្រើន និងជួយជំរុញ និងបណ្តុះបណ្តាលនូវជំនាញព័ត៌មានវិទ្យា និងបច្ចេកវិទ្យាប្រកបដោយការច្នៃប្រឌិតខ្ពស់។[24]

### ១.៤.២.៣ បដិវត្តឧស្សាហកម្ម៤.0 ជួយសម្រួលសាកលូបនីយកម្ម

បដិវត្តឧស្សាហកម្មទី៤.0 គឺជាធ្វើការទំនើបកម្មឆ្ពោះទៅស្វ័យប្រវត្តិកម្មការផ្លាស់ប្តូរទិន្នន័យបច្ចេកវិទ្យាដំណើរការផលិតកម្មដោយប្រពន្ធ័អ៊ិនធឺណេត(Internet of Things) ការយល់ដឹង និងភាពឆ្លាតវៃនៃបញ្ញាសិប្បនិម្មិត (Intelligence-AI) និងបច្ចេកវិទ្យាក្លោដ (Cloud technology)។ ឧស្សាហកម្ម៤.0 គឺជាផ្នែកមួយនៃបដិវត្តឧស្សាហកម្មទី៤.0 (Fourth industry revolution) ដែលពាក់ពន្ធ័ទៅនឹងឧស្សាហកម្ម ហើយគ្របដណ្តប់ទៅលើវិស័យ ដូចជា រោងចក្រឆ្លាតវៃ ទីក្រុងឆ្លាតវៃ ដែលមានម៉ាស៊ីនភ្ជាប់គ្នា(ឥតខ្សែ) ភ្ជាប់ទៅនឹងឧបករណ៍ចាប់សញ្ញាជាមួយប្រព័ន្ធដែលអាចមើលឃើញខ្សែច្រវ៉ាក់ផលិតកម្ម ហើយប្រព្រឹត្តទៅដោយស្វ័យប្រវត្តិ។ បដិវត្តឧស្សាហកម្ម ការធ្វើទំនើបកម្មឧស្សាហកម្ម ដោយប្រើប្រាស់គ្រឿងចក្រ ម៉ាស៊ីន ជំនួសឱ្យការប្រើប្រាស់ឧបករណ៍សាមញ្ញ (លក្ខណៈគ្រួសារ) បានចាប់ផ្តើមអនុវត្តនៅប្រទេសអង់គ្លេស នាសតវត្សរ៍ទី១៨ ដើម្បីឆ្លើយតបទៅនឹងកំណើនប្រជាជន តម្រូវការម្ហូបអាហារ ផលិតផល និងសេវា ដែលមានល្បឿនលឿនជាងមុន មានការច្នៃប្រឌិត ប្រើប្រាស់ម៉ាស៊ីនទំនើប និងបច្ចេកវិទ្យារុករកថាមពលថ្មីៗ ដើម្បីដំណើរការរោងចក្រទទួលបានទិន្នន័យផលខ្ពស់ ស្របតាមកំណើនប្រជាជន។ បដិវត្តឧស្សាហកម្មនេះ នាំមកនូវការផ្លាស់ប្តូរ និងរីកចម្រើនដល់មនុស្សជាតិ រួចមានផលិតកម្មសម្បូរបែបបរិមាណច្រើន ក្នុងល្បឿនលឿន ដែលនាំឱ្យសកម្មភាពជំនួញអន្តរជាតិកាន់តែសកម្ម ហើយប្រទេសដែលពុំទាន់មានបដិវត្តឧស្សាហកម្មអាចមានឱកាសទិញ ប្រើប្រាស់ផលិតផលទំនើបៗ តាមរយៈការធ្វើពាណិជ្ជកម្មតំបន់ និងក្នុងពិភពលោក។ បដិវត្តឧស្សាហកម្មបានសាយភាយលើសកលលោក មនុស្សចាប់ផ្តើមធ្វើចំណាកស្រុកពីជនបទមកទីក្រុង ដែលជាបណ្តុំរោងចក្រ

[24] Ahmad, Abd. R., Segaran, P. G. R., & Sapry, H. R. Md. (2020). Academic Staff and Industry Revolution 4.0: Knowledge,

ដើម្បីប្រកបការងារក្រៅពីកសិកម្ម។ នៅពេលដែលឧស្សាហកម្មឈានដល់ចំណុចកំពូល បរិមាណផលិតមានសន្ទុះខ្លាំង ផលិតផល មានពិពិធកម្ម និងមានគុណភាពខ្ពស់ ចំណែកឯមធ្យោបាយនៃការផលិតមានភាពទំនើបជាមួយនឹងគ្រឿងយន្តដ៏សម្បូរបែប។ ពិភពលោកកំពុងតែស្ថិតក្នុងការផ្លាស់ប្តូរីកចម្រើនពាក់ពន្ធ័នឹងបែបផែនផលិតកម្មបច្ចេកវិទ្យាឌីជីថល ដែលជាការផ្លាស់ប្តូរឧស្សាហកម្មនិងបញ្ជាក់ថា ឧស្សាហកម្មទី៤.0 បានចាប់ផ្តើមអនុវត្តនៅក្នុងខ្សែច្រវ៉ាក់ផលិតកម្ម ។[25]

បដិវត្តឧស្សាហកម្មទី១ បានកើតឡើងរវាងឆ្នាំ១៧៦០ និងឆ្នាំ១៨៤០ ផលិតផលមេកានិច ក៏បានបង្ហាញខ្លួនជាលើកដំបូង តាមរយៈការបង្កើតម៉ាស៊ីនដើរដោយចំហាយទឹក គួបផ្សំជាមួយនឹងការប្រើប្រាស់ផ្លូវរថភ្លើង។ ការច្នៃប្រឌិតថ្មីនេះ បានត្រួសត្រាយផ្លូវផលិតកម្មឧស្សាហកម្មដំបូងគេ ដូចជា ឧស្សាហកម្មដែក និងដែកថែប ដែលបានលេចឡើងយ៉ាងឆាប់រហ័ស នៅក្នុងដំណើរការនៃការផលិត។ បដិវត្តឧស្សាហកម្មទី២ នៅចុងសតវត្សរ៍ទី២០ តាមរយៈរបកគំហើញថាមពលអគ្គីសនី និងការបង្កើតខ្សែសង្វាក់ផលិតកម្មនៅក្នុងរោងចក្រ។ ម៉្យាងទៀតផលិតកម្មទ្រង់ទ្រាយធំក៏ត្រូវបានចាត់ទុកជាលក្ខណៈកំណត់មួយនៃបដិវត្តន៍ឧស្សាហកម្មទី២ផងដែរ។ ជាមួយនឹងការចាប់ផ្តើមនៃយុគសម័យឌីជីថលនៅសតវត្សរ៍ឆ្នាំ៦០ បដិវត្តឧស្សាហកម្មទី៣ បានកើតឡើង ដោយផ្អែកលើការអភិវឌ្ឍផ្នែកបច្ចេកវិទ្យា ប្រព័ន្ធអ៊ីនធឺណេត ព័ត៌មានវិទ្យា (IT) ស៊ីមី កុងឌុចទ័រ (Semiconductor) និងកុំព្យូទ័រភាវូបនីយកម្ម(Computerization)។ បដិវត្តឧស្សាហកម្មទី៤.0 វានឹងមានឥទ្ធិពលយ៉ាងធំធេងលើជីវិតមនុស្សជាងបដិវត្តឧស្សាហកម្មនានាកន្លងមក។

ប្រទេសជាច្រើនបានកំណត់យកបដិវត្តឧស្សាហកម្មទី៤.0 ជាអាទិភាពចម្បងសម្រាប់កំណើន និងការអភិវឌ្ឍសេដ្ឋកិច្ច។ ជាមួយនឹងបច្ចេកវិទ្យា និងនវានុវត្តន៍ថ្មីៗ ដូចជា បញ្ញាសប្បនិម្មិត និងរ៉ូបូតវិទ្យា(Robo tics) បដិវត្តឧស្សាហកម្មនឹងជះឥទ្ធិពលយ៉ាងខ្លាំង លើគ្រប់ទិដ្ឋភាពនៃជីវិតរបស់មនុស្សរួមទាំងអភិបាលកិច្ចសង្គម និងរចនាសម្ព័ន្ធសេដ្ឋកិច្ច។ ទោះបីជាមានកាលានុវត្តភាព និងភាពរំជើបរំជួលជាច្រើនពីបច្ចេកវិទ្យាថ្មីៗនិងទំនើបៗ ក្នុងបដិវត្តឧស្សាហកម្មនេះ។[26] បដិវត្តឧស្សាហកម្មទី៤.0 ត្រូវបានគេព្យាករថា នឹងមានឥទ្ធិពលយ៉ាងខ្លាំងក្លាលើគ្រប់ទិដ្ឋភាពនៃជីវិតរបស់មនុស្សបូករួមទាំងផលវិជ្ជមាននិងអវិជ្ជមានដោយអាស្រ័យលើការប្រើប្រាស់បច្ចេកវិទ្យារបស់វា និងកម្រិតនៃការត្រៀមខ្លួនរបស់សង្គមមនុស្សក្នុងតំបន់ និងពិភពលោក ដើម្បីសម្របខ្លួនទៅនឹងការផ្លាស់ប្តូរដ៏ធំធេងរបស់ឧស្សាហកម្ម៤.0។ ចំពោះផលវិជ្ជមាននៃបច្ចេកវិទ្យា និងនវានុវត្តន៍របស់បដិវត្តឧស្សាហកម្ម៤.0 ត្រូវបានរំពឹងទុកថា នឹងលើកកម្ពស់គុណភាពជីវិតរបស់មនុស្សក៏ដូចជា ធ្វើឱ្យ

[25] ហ៊ាប សាហ៊ីប "ទស្សនៈសេដ្ឋកិច្ច និងវិទ្យាសាស្ត្រសេដ្ឋកិច្ច" ភ្នំពេញ ឆ្នាំ២០២១ ទំព័រ៤៩៤-៤៩៥

[26] តាន់ មុន្នីវិសាល (ថ្ងៃទី៤ ខែមិថុនាឆ្នាំ២០១៩) "បដិវត្តន៍ឧស្សាហកម្មទី៤ (ឧស្សាហកម្ម៤.0)". វ៉ុល ១ លេខទី៣

របៀបរស់នៅ និងប្រព័ន្ធគមនាគមន៍កាន់តែប្រសើរឡើង។[27] ខណៈដែលបដិវត្តឧស្សាហកម្ម៤.0 មានការទាក់ទងជាមួយនឹងការផ្លាស់ប្តូរបច្ចេកវិទ្យាជារួមក្នុងទិដ្ឋភាពផ្សេងៗនៃជីវិតមនុស្ស។ ឧស្សាហកម្ម៤.0នេះគឺពាក់ព័ន្ធនឹងការផ្លាស់ប្តូរបច្ចេកវិទ្យានៃប្រព័ន្ធផលិតកម្មក្នុងវិស័យឧស្សាហកម្ម។ បដិវត្តឧស្សាហកម្ម សំដៅលើការផ្លាស់ប្តូរក្នុងខ្សែសង្វាក់តម្លៃសកលដែលកើតឡើងដោយកិច្ចសហប្រតិបត្តិការរវាងប្រព័ន្ធនិម្មិត និងប្រព័ន្ធរូបសាស្ត្រនៃផលិតកម្មក្នុង"រោងចក្រវៃឆ្លាត" ។

បច្ចេកវិទ្យារបស់បដិវត្តឧស្សាហកម្មទី៤.0 ក៏អាចបង្កើនកម្រិតនៃភាពងាយស្រួលដល់មនុស្សផ្ទាល់ចំពោះអ្នកមានលទ្ធភាពប្រើប្រាស់សេវាកម្មក្នុងពិភពឌីជីថល ព្រោះសេវាកម្មជាច្រើន ដូចជាការទិញទំនិញតាមអនឡាញ និងការកក់សំបុត្រយន្តហោះជាដើម អាចធ្វើពីចម្ងាយបានដោយងាយ។ លើសពីនេះដោយសារតែទិន្នន័យអនឡាញជាច្រើនបញ្ជូនពីឧបករណ៍ផ្សេងៗ ដែលត្រូវបានតភ្ជាប់ទៅប្រព័ន្ធពពក (the Cloud) បញ្ញាសប្បនិម្មិតនឹងអាចធ្វើការវិភាគ និងព្យាករដើម្បីបង្កើតសេវាកម្មវៃឆ្លាតយ៉ាងឆាប់រហ័សសម្រាប់អតិថិជនក្នុងវិស័យផ្សេងៗជាច្រើន ដូចជា វិស័យសុខាភិបាល ដឹកជញ្ជូន ហិរញ្ញវត្ថុ និងសេវាសាធារណៈទូទាំងប្រទេស។

រូបភាពទី១.៤.២.៣ ដំណាក់កាលបដិវត្តឧស្សាហកម្មទី៤.0 រូបភាពទី១.៤.២.៣ បដិវត្តឧស្សាហកម្មទី ៤.0







បញ្ញាសិប្បនិម្មិត (Artificial Intelligence) ក្នុងរ៉ូបូត និងម៉ាស៊ីនកុំព្យូទ័រអាចដើរតួជំនួសមនុស្សក្នុងការបំពេញភារកិច្ចធ្វើស្វ័យសម្រេចចិត្ត និងកែលម្អដោយខ្លួនឯងតាមប្រព័ន្ធបច្ចេកវិទ្យាជំនួសខួរក្បាលមនុស្ស និងការរៀនចេះចាំដោយម៉ាស៊ីន(Cognitive Computing and Machine Learning) ដែលនាំឱ្យមានការវិភាគ និងទាយទុកភ្លាមៗ(Real-Time Predictive Analytics)។ ប្រព័ន្ធកម្មវិធីធ្វើផែនការធនធានសហគ្រាស(Enterprise Resource Planning) មានសមត្ថភាពគ្រប់គ្រងដំណើរការអាជីវកម្ម និងព័ត៌មានទូទៅរបស់អង្គភាពនៅក្នុងពេលវេលាជាក់ស្តែង និងសម្របសម្រួលដោយ Software និងបច្ចេកវិទ្យា។ ប្រព័ន្ធ ERP

[27] តាន់ មុន្នីវិសាល ,(ថ្ងៃទី៤ ខែមិថុនាឆ្នាំ២០១៩) "បដិវត្តន៍ឧស្សាហកម្មទី៤ (ឧស្សាហកម្ម៤.0)" វ៉ុល ១ លេខទី៣

នេះមានសមត្ថភាពតាមដានធនធានអាជីវកម្ម សាច់ប្រាក់ វត្ថុធាតុដើម សមត្ថភាពផលិតកម្ម ការបញ្ជាទិញ ការលក់ និងប្រាក់ខែបុគ្គលិក។

បដិវត្តឧស្សាហកម្មទី៤.0 ក៏បាននាំមកនូវការព្រួយបារម្ភមួយចំនួនផងដែរ ដែលក្នុងនោះរួមមាន ការកើនឡើងនៃបញ្ញាសប្បនិម្មិតនិងប្រព័ន្ធស្វ័យប្រវត្តិកម្មនៅក្នុងវិស័យការងារដែលអាចនឹងជំនួសកម្លាំងពលកម្មមនុស្ស ហើយអាចនាំឱ្យឈានទៅដល់ការបាត់បង់ការងារ និងនាំឱ្យមានកំណើននៃនិកម្មភាពកាន់តែខ្ពស់ជាងមុន។ ទោះបីជាបន្លាស់ប្តូរការងាររបស់កម្មករពឹងផ្អែកលើសន្ទុះនៃការចាប់យកបច្ចេកវិទ្យាមកប្រើប្រាស់ដោយស្ថាប័នជំនួញ និងសេដ្ឋកិច្ចក៏ដោយកម្មករប្រមាណ៣៧៥លាននាក់ និងនៅតែត្រូវការផ្លាស់ប្តូរមុខរបររបស់ខ្លួននៅឆ្នាំ២០៣០។ ដូច្នេះជំនាញ និងចំណេះដឹងថ្មីៗ ឬការសម្របខ្លួនជាមួយនឹងបច្ចេកវិទ្យា ហើយនឹងម៉ាស៊ីនទំនើបៗគួរតែជាអាទិភាពចម្បង។

ការបោះពុម្ព 3D គឺជាដំណើរការនៃការបង្កើតវត្ថុ ពីការរចនាជំនួយដោយកុំព្យូទ័រ (Computera-ided Design) នៃរូបរាងស្ទើរតែទាំងអស់ពីគំរូឌីជីថល។ ប្រព័ន្ធប្រតិបត្តិការ M2MP មានសមត្ថភាពធ្វើការទំនាក់ទំនងពីម៉ាស៊ីនមួយទៅម៉ាស៊ីនមួយ តាមរយៈបណ្តាញឥតខ្សែ ឬមានខ្សែតាមប្រព័ន្ធបច្ចេកវិទ្យា AI និងប្រព័ន្ធរៀនចេះចាំដោយម៉ាស៊ីន។ ប្រព័ន្ធវិភាគទិន្នន័យធំ និងដំណោះស្រាយកម្រិតខ្ពស់ (Big Data Analytics and Advanced Algorithms) ជាសំណុំនៃបច្ចេកទេស និងឧបករណ៍ត្រូវបានប្រើប្រាស់ដើម្បីដំណើរការត្រួតពិនិត្យ និងបកស្រាយបរិមាណទិន្នន័យជាច្រើន ដែលជួយឱ្យក្រុមហ៊ុនធ្វើការសម្រេចចិត្តផ្អែកអាជីវកម្មរបស់ខ្លួនផ្អែកលើព័ត៌មានត្រឹមត្រូវ។ លើសពីនេះ ប្រព័ន្ធប្រតិបត្តិការអ៊ីនធឺណិត 5G ប្រព័ន្ធបច្ចេកវិទ្យាណាណូ(Nanotechnology) បច្ចេកវិទ្យាហិរញ្ញវត្ថុ(Fintech) និងប្រព័ន្ធប្រាក់ឌីជីថល Blockchain សុទ្ធតែជាប្រព័ន្ធប្រតិបត្តិការរហ័ស និងមានប្រសិទ្ធិភាពខ្ពស់ក្នុងការជួយសម្រួលអាជីវកម្ម និងការរស់នៅរបស់មនុស្ស (រតនីធតា ២០១៩)។[28]

[28] និត កុសល, (ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២០) "តើកម្ពុជា គួរត្រៀមខ្លួន ដូចម្តេចសម្រាប់បដិវត្តន៍ឧស្សាកម្មទី៤"

រូបភាពទី១.៤.២.៣ បដិវត្តឧស្សាហកម្មទី៤.0




រូបភាពទី ១.៤.២.៣ បដិវត្តឧស្សាហកម្មទី៤.0 រោងចក្រស្មាត




បដិវត្តឧស្សាហកម្ម៤.0 ជាដំណើរថ្មីនៃបដិវត្តឧស្សាហកម្មផ្តោតសំខាន់ លើបច្ចេកវិទ្យា ឌីជីថលវៃឆ្លាត ដែលអាចជំរុញផលិតភាព ភាពបត់បែន ភាពរហ័សរហួន និងប្រាក់ចំណេញក្នុងការធ្វើអាជីវកម្ម។ កម្ពុជាបានមើលឃើញអំពីកាលានុវត្តភាពក្នុងការជំរុញកំណើននិងអភិវឌ្ឍសេដ្ឋកិច្ចយូរអង្វែងប្រកប ដោយចីរភាពតាមរយៈការចាប់យកបដិវត្តឧស្សាហកម្ម៤.0។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានបន្តអនុវត្តគោលនយោបាយដែលមានស្រាប់ និងរៀបចំគោលនយោបាយថ្មីមួយចំនួនបន្ថែមទៀត។ កត្តាមួយចំនួនរួមមាន ធនធានមនុស្សជំនាញផ្នែកឌីជីថល បទដ្ឋានគតិយុត្ត និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល។ ជម្រើសគោលនយោបាយមួយចំនួនក្នុងការត្រៀមខ្លួនទាញយកអត្ថប្រយោជន៍ជាអតិបរមាពីបដិវត្តឧស្សាហកម្មទី៤.0 ដូចជា ជំរុញការវិនិយោគក្នុងវិស័យអប់រំ ការស្រាវជ្រាវ និងច្នៃប្រឌិត ការរៀបចំបទប្បញ្ញត្តិ ការគ្រប់គ្រងសុវត្ថិភាព និងសន្តិសុខឌីជីថល ការលើកកម្ពស់ការប្រើប្រាស់ការធ្វើអាជីវកម្មនិងពាណិជ្ជកម្មអេឡិចត្រូនិក ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធឌីជីថល ក៏ដូចជា ការពង្រីកសេវាកម្មរបស់រាជរដ្ឋាភិបាលឌីជីថល។[29]

បដិវត្តឧស្សាហកម្មទី៤.0ជាដំណាក់កាលបង្កើនប្រសិទ្ធភាពប្រើប្រាស់កុំព្យូទ័រឧស្សាហកម្មខណៈ កុំព្យូទ័រត្រូវបានតភ្ជាប់គ្នាដោយស្វ័យប្រវត្តិនិងការបញ្ចូលគ្នារវាងប្រព័ន្ធគ្រប់គ្រងដោយកុំព្យូទ័រជាមួយប្រព័ន្ធ អ៊ិនធឺណិតរូបវន្ត(Cyberphysical Systems) និងការតភ្ជាប់ទំនាក់ទំនងដើម្បីបញ្ចូល ប្រមូលទិន្នន័យ ផ្លាស់ប្តូរទិន្នន័យ។ បច្ចេកវិទ្យាឆ្លាតវៃ ធ្វើឱ្យមានភាពងាយស្រួល និងភាពឆ្លាតវៃ ការផលិតកាន់តែមានប្រសិទ្ធភាព និងសន្សំសំចៃខ្ពស់ជាងមុន។ បដិវត្តឧស្សាហកម្មទី៤.0ធ្វើឱ្យមានការផ្លាស់ប្តូរបុគ្គលភាព មានផលប៉ះពាល់ដល់

[29] និត កុសល, (ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២០) "តើកម្ពុជា គួរត្រៀមខ្លួន ដូចម្តេចសម្រាប់បដិវត្តន៍ឧស្សាកម្មទី៤"

អត្តសញ្ញាណបុគ្គល និងភាពជាកម្មសិទ្ធិ ទម្រង់ប្រើប្រាស់ពេលវេលាធ្វើការ និងការកែលម្អ របៀបអភិវឌ្ឍន៍ការងារ ផលិតកម្ម និងការពង្រឹងផលិតភាព។ បច្ចេកវិទ្យាជំរុញឱ្យមានភាពងាយស្រួលរហ័ស និងមានប្រសិភាព អាចពន្លឿន និងពង្រីកកម្រិតសុខុមាលភាពសង្គម ការយល់ដឹង និងសមត្ថភាពមនុស្សជាមួយនឹងរបកគំហើញថ្មីៗ ដែលមានសារប្រយោជន៍សម្រាប់មនុស្សជាតិ។ បដិវត្តឧស្សាហកម្មទី៤.0 គឺការដាក់បញ្ចូលគ្នានូវបណ្តាញអ៊ិនធឺណិតនៃសម្ភារៈតាមរយៈការតភ្ជាប់សម្ភារៈដោយប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិត ដើម្បីអាចបញ្ចូល និងទទួលទិន្នន័យជាមួយបណ្តាញបច្ចេកវិទ្យារូបវន្តផ្សេងៗ ទៀត ដូចជាបច្ចេកវិទ្យាវិភាគទិន្នន័យផលិតកម្មតាមការបន្ថែមស្រទាប់(ការបោះពុម្ព3D) បច្ចេកវិទ្យា ក្វាន់ទុម (Quantum technology) បច្ចេកវិទ្យា (Nanotechnology) ជីវៈបច្ចេកវិទ្យា (Biotechnology) រ៉ូប៉ូតឆ្លាតវៃ (Intelligent robots) ប្លុកឆេន (Blockchain) ការប្រើប្រាស់កុំព្យូទ័រមានសមត្ថភាពខ្ពស់ បញ្ញាសិប្បនិម្មិត ការប្រើរថយន្តបើកដោយស្វ័យប្រវត្តិ និងបច្ចេកវិទ្យា ការប្រើប្រាស់កុំព្យូទ័រជំនួសខួរក្បាលមនុស្ស សម្ភារៈទំនើបៗ ជំនួសដោយកុំព្យូទ័រ។

បដិវត្តឧស្សាហកម្មទី៤.0 គឺជាការរួមបញ្ចូលគ្នារវាងពិភពឌីជីថល និងពិភពរូបវន្តរួមមានអ៊ិនធឺណេតល្បឿនលឿន ទិន្នន័យអេឡិចត្រូនិច ប្រព័ន្ធស្វ័យប្រវត្តិនៅកន្លែងធ្វើការងារ និងបញ្ញាសិប្បនិម្មិតឬភាពឆ្លាតវៃនៃកុំព្យូទ័រដែលជួយសម្រួលការងារ។ ឧស្សាហកម្ម៤.0មានគោលការណ៍សំខាន់៤ ១-ការតភ្ជាប់គ្នារវាងឧបករណ៍ចាប់សញ្ញា និងមនុស្សដើម្បីភ្ជាប់ប្រាស្រ័យទាក់ទងគ្នាតាមរយៈអ៊ិនធឺណេត២-ប្រតិបត្តិការប្រមូលទិន្នន័យនិងព័ត៌មានពីគ្រប់ចំណុចក្នុងដំណើរការផលិត៣-ជំនួយបច្ចេកទេសគាំទ្រដល់ការសម្រេចចិត្ត(បែបរិមជ្ឈការ)តាមប្រព័ន្ធរូបវិទ្យាអ៊ិនធឺណេតដោយស្វ័យប្រវត្តិពិសេសជួយជំរុញផលិតផលកម្មប្រកបដោយចីរភាពតាមរយៈដំណើរការផលិតកម្មបៃតង ការគ្រប់គ្រងខ្សែច្រវ៉ាក់ផ្គត់ផ្គង់បៃតង និងផលិតផលបៃតង។

ឥទ្ធិពលនៃបដិវត្តឧស្សាហកម្មទី៤.0 ការប្រើប្រាស់ម៉ាស៊ីនដែលអាចប្រមូលទិន្នន័យបានច្រើន មានឥទ្ធិពលលើការថែទាំ ដំណើរការ និងការដោះស្រាយបញ្ហានានា ហើយការវិភាគទិន្នន័យទាំងឡាយ អាចកំណត់រូបរាង និងទស្សនៈដែលមនុស្សមិនអាចធ្វើបាន។ ឧស្សាហកម្មទី៤.0 ផ្តល់ឱកាសដល់ផលិតករ ដើម្បីបង្កើនដំណើរការផលិតបានលឿនឆាប់រហ័ស និងមានប្រសិទ្ធភាព ដោយការប្រើប្រាស់រ៉ូបូត (Robot) ដែលមានតម្លៃសមស្របអាចជួយដឹកជញ្ជូនទំនិញពីឃ្លាំង ជួយរៀបចំទំនិញឱ្យរួចរាល់ដើម្បីដឹកចេញជួយការផលិតកាន់តែលឿននិងមានសុវត្ថិភាព។ រ៉ូបូតមានភាពបត់បែនខ្ពស់មានមុខងារជឿនលឿនអាចប្រត្តិបត្តការលើវិស័យជាច្រើន។ នៅពេលដែលបច្ចេកវិទ្យាឈានដល់ចំនុចកំពូល រ៉ូបូតនឹងធ្វើអន្តរកម្ម សហការយ៉ាងសកម្មជាមួយមនុស្ស អាចជំនួសកម្លាំងពលកម្មបានពេញលេញក្រោមការណែនាំពីអ្នកពិនិត្យ។ ការបោះពុម្ពដោយបច្ចេកវិទ្យា 3D បានជួយបង្កើនផលិតភាព និងគុណភាពដែលបង្កភាពងាយស្រួលដល់ផលិតកម្មបំពេញតាមតម្រូវការអតិថិជន(ពីការបោះពុម្ពក្រដាសធម្មតាទៅជាការបោះពុម្ពផលិតផលពិតៗបន្ថែមទៀត)។ មុខងារសំ

ខាន់ៗរបស់ឧស្សាហកម្ម៤.០ គឺការបញ្ចូលការប្រមូលទិន្នន័យ និងការផ្លាស់ប្តូរទិន្នន័យដោយការភ្ជាប់វត្ថុទៅនឹងអ៊ិនធឺណិត ជួយកំណត់តួនាទីឧបករណ៍ចងភ្ជាប់គ្នា ដើម្បីផ្ទុកទិន្នន័យប្រកបដោយសុវត្ថិភាព។

សមាសធាតុដែលបង្កើនភាពប្រកួតប្រជែងក្នុងឧស្សាហកម្ម៤.០ គឺ១-ការធ្វើសមាហរណកម្មខ្សែចង្វាក់ម្លៃតាមខ្សែបញ្ឈរ និងផ្តេក ២-ឌីជីថលលូបនីយកម្មនៃផលិតផល និងសេវា ដោយការបង្កើតផលិតផលឌីជីថលថ្មី កសាងទិន្នន័យស្តីអំពីការប្រើប្រាស់ផលិតផល ហើយអាចកែលម្អផលិផល ដើម្បីឆ្លើយតបទៅនិងតម្រូវការអតិថិជនបានយ៉ាងឆាប់រហ័ស ៣-កសាងម៉ូដែលអាជីវកម្មឌីជីថល ការបើកច្រកចូលទៅកាន់អតិថិជន ការកែលម្អផលិតផលកម្មដែលមានស្រាប់ តាមតម្រូវការអតិថិជន ដើម្បីផ្តល់នូវដំណោះស្រាយឌីជីថលឆ្លើយតបបានទាន់ពេលវេលា និងមានប្រសិទ្ធភាព។[30]

**១.៤.២.៤ ឧស្សាហកម្មទី៤.០ ជួយសម្រួលដល់បច្ចេកវិទ្យា**

ឧស្សាហកម្មទី៤.០ក៏នាំមកនូវកាលានុវត្តភាពសេដ្ឋកិច្ចបន្ថែមទៀតដល់វិស័យឧស្សាហកម្ម ដែលអាចធ្វើការផ្លាស់ប្តូរផ្នែកបច្ចេកវិទ្យានិងប្រព័ន្ធឌីជីថលរបស់ខ្លួន។ការវិនិយោគលើបច្ចេកវិទ្យារបស់ឧបករណ៍តភ្ជាប់ និងគ្រប់គ្រងដោយប្រព័ន្ធអ៊ីនធឺណិតក្នុងឧស្សាហកម្ម ត្រូវបានព្យាករថានឹងទទួលបានផលចំណេញកាន់តែខ្ពស់លើកំណើននៃតម្លៃសេដ្ឋកិច្ចរបស់ខ្លួន។ បើតាម Accenture and General Electric ក្នុងឆ្នាំ ២០១៥ បានបង្ហាញថា ការអភិវឌ្ឍបច្ចេកវិទ្យាឧស្សាហកម្មទី៤.០នៅក្នុងវិស័យឧស្សាហកម្មផ្សេងៗ អាចផ្តល់កាលានុវត្តភាពសេដ្ឋកិច្ចខ្ពស់។ សហរដ្ឋអាមេរិក តាមពីក្រោយដោយប្រទេសចិន អាល្លឺម៉ង់ និងចក្រភពអង់គ្លេសបានក្លាយជាប្រទេសដែលបានទទួលអត្ថប្រយោជន៍ច្រើនបំផុតពីការអភិវឌ្ឍបច្ចេវិទ្យា។[31]

ការផ្លាស់ប្តូរបច្ចេកវិទ្យា ជារួមលើទិដ្ឋភាពផ្សេងៗ នៃជីវិតមនុស្សខណៈដែលឧស្សាហកម្មទី៤.០ គឺសំដៅលើការផ្លាស់ប្តូរបច្ចេកវិទ្យា ផលិតកម្មក្នុងវិស័យឧស្សាហកម្ម។ ប្រទេសជាច្រើនក្នុងសកលលោក រួមទាំងកម្ពុជា បាននិងកំពុងយកចិត្តទុកដាក់រៀបចំគោលនយោបាយ ដើម្បីត្រៀមខ្លួន និងទទួលយកបដិវត្តន៍ថ្មីនេះ។ បដិវត្តឧស្សាហកម្មទី៤.០ សំដៅដល់ដំណាក់កាលថ្មីនៃដំណើរការបដិវត្តឧស្សាហកម្ម ផ្តោតសំខាន់លើបច្ចេកវិទ្យាឌីជីថលក្នុងរោងចក្រ ហើយម៉ាស៊ីនត្រូវបានបំពាក់ដោយឧបករណ៍តភ្ជាប់ឥតខ្សែ និងឧបករណ៍ចាប់សញ្ញាភ្ជាប់ទៅនឹងប្រព័ន្ធ ដែលអាចមើលឃើញខ្សែសង្វាក់ផលិតកម្មទាំងមូល និងធ្វើស្វ័យសម្រេចចិត្ត។ ការឆ្ពោះទៅកាន់ស្វ័យប្រវត្តិកម្ម ការផ្លាស់ប្តូរទិន្នន័យនៅក្នុងបច្ចេកវិទ្យាផលិតកម្ម និងដំណើរការដោយប្រព័ន្ធរូបសាស្ត្រស៊ីប៊ែរ(Chyber-Physical Systems) អ៊ិនធឺណិតនៃវត្ថុ(Internet of Things) ឧស្សាហកម្មនៃអ៊ីនធឺ

[30] ហ៊ាប សាហ៊ីប, (២០២១) "ទស្សនៈសេដ្ឋកិច្ច និងវិទ្យាសាស្ត្រសេដ្ឋកិច្ច" ភ្នំពេញ ទំព័រ ៤៩៥-៥០៥

[31] តាន់ មុន្នីវិសាល, (ថ្ងៃទី៤ ខែមិថុនាឆ្នាំ២០១៩) "បដិវត្តន៍ឧស្សាហកម្មទី៤ (ឧស្សាហកម្ម ៤.០)" វ៉ុល ១ លេខទី៣

ណិតនៃវត្ថុ (Industrial IoTs) ប្រព័ន្ធកុំព្យូទ័រពពក (Cloud Computing) ប្រព័ន្ធបច្ចេកវិទ្យាជំនួសខួរក្បាលមនុស្ស(Cognitive Computing) និងបញ្ញាសប្បនិម្មិត(Artificial Intelligence)។ ប្រព័ន្ធរូបសាស្ត្រស៊ីប៊ែរ ជាប្រព័ន្ធដែលគ្រប់គ្រង និងត្រួតពិនិត្យផ្អែកលើកុំព្យូទ័រ ដែលជាការរួមបញ្ចូលគ្នាយ៉ាងជិតស្និតជាមួយអ៊ីនធឺណេត និងអ្នកប្រើប្រាស់។ ការងារគ្រប់យ៉ាងជាមួយអ៊ីនធឺណេតនៃវត្ថុក្នុងឧស្សាហកម្មអ៊ីនធឺណេតនៃវត្ថុ គឺជាការតភ្ជាប់គ្នារវាងវត្ថុរូបសាស្ត្រនិងជីវសាស្ត្រ ដូចជាឧបករណ៍ចាប់សញ្ញា ដែលមានសមត្ថភាពផ្គត់ផ្គង់វត្ថុប្រចាំថ្ងៃដោយកំណត់អត្តសញ្ញាណ អារម្មណ៍ការទំនាក់ទំនងប្រព័ន្ធតាមដានសុខភាព ប្រព័ន្ធគ្រប់គ្រងភារកិច្ច និងប្រព័ន្ធគ្រប់គ្រងម៉ាស៊ីន និងទិន្នន័យដែលអាចធានាប្រសិទ្ធភាពប្រតិបត្តិការ(WTO, 2018)។ ប្រព័ន្ធកុំព្យូទ័រពពក(Cloud Computing) ជាការប្រើប្រាស់ម៉ាស៊ីនមេរួមមួយ ដែលមានទំនាក់ទំនងគ្នាលើអ៊ីនធឺណេតដើម្បីរក្សាទុកគ្រប់គ្រង និងដំណើរការទិន្នន័យ។

សហគ្រាសធុនតូច និងមធ្យម ក៏នឹងទទួលបាននូវឱកាសក្នុងការបង្កើនផលិតភាព និងប្រសិទ្ធភាពពីបច្ចេកវិទ្យាថ្មីៗ ដូចជាឧបករណ៍កំណត់សញ្ញា(Sensors)និងប្រព័ន្ធវិភាគទិន្នន័យធំ(Big Data Analytics) ដែលអាចជួយឱ្យមានការយល់ដឹងកាន់តែច្បាស់អំពីសេចក្តីលម្អិតនៃដំណើរការផលិតកម្ម និងជួយពួកគេស្វែងរកជម្រើសដែលត្រូវការពេលវេលានិងធនធានតិចជាងមុនសម្រាប់ផលិតកម្មរបស់ខ្លួន។[32] ការប្រើប្រាស់បច្ចេកវិទ្យារបស់វា និងកម្រិតនៃការត្រៀមខ្លួនរបស់សង្គមមនុស្សក្នុងតំបន់ និងពិភពលោក ដើម្បីសម្របខ្លួនទៅនឹងការផ្លាស់ប្តូរដ៏ធំធេងដែលឧស្សាហកម្មទី៤.០។ ចំពោះផលវិជ្ជមាននៃបច្ចេកវិទ្យា និងនវានុវត្តន៍របស់បដិវត្តឧស្សាហកម្មទី៤.០ ត្រូវបានរំពឹងទុកថានឹងលើកកម្ពស់គុណភាពជីវិតរបស់មនុស្សក៏ដូចជាធ្វើឱ្យរបៀបរស់នៅ និងប្រព័ន្ធគមនាគមន៍កាន់តែប្រសើរឡើង។[33]

ការប្រើប្រាស់បច្ចេកវិទ្យាមានទំនាក់ទំនងជាមួយការផលិតនិងការកែច្នៃ ដើម្បីឱ្យផលិតផលដំណើរការប្រកបដោយប្រសិទ្ធភាព។ បច្ចុប្បន្ននេះការរីកចម្រើនផ្នែកបច្ចេកវិទ្យានាំឱ្យមានការប្រែប្រួលដល់សេដ្ឋកិច្ចសង្គមនិងការប្រកួតប្រជែងដែលវាអាចមានផលប៉ះពាល់ទៅដល់ការគ្រប់គ្រងការងាររបស់សហគ្រាស ដែលត្រូវកែសម្រួលប្រព័ន្ធការងារ និងប្រព័ន្ធព័ត៌មានថ្មី។ ការនាំបច្ចេកវិទ្យា(Robots) និងប្រព័ន្ធផលិតស្វ័យប្រវត្តិ(Automation) មកប្រើដើម្បីបង្កើនផលិតផលនៅក្នុងរោងចក្រឧស្សាហកម្មក៏ដូចជា ការចំណេញពេលវេលាគុណភាពឬប្រព័ន្ធផលិតតាមស្តង់ដាដើម្បីដំណើការឱ្យមានប្រសិទ្ធភាព។[34]បច្ចេកវិទ្យាបានក្លាយជាផ្នែកមួយ

---

[32] តាន់ មុន្នីវិសាល, (ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៩) "បដិវត្តន៍ឧស្សាហកម្មទី៤ (ឧស្សាហកម្ម៤.០)" វ៉ុល ១ លេខទី៣

[33] តាន់ មុន្នីវិសាល, (ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៩) "បដិវត្តន៍ឧស្សាហកម្មទី ៤ (ឧស្សាហកម្ម ៤.០)" វ៉ុល ១ លេខទី៣

[34] ជា ចំរើន, សួន ឱសថ, (២០១០) " មគ្គុទ្ទេសន៍នៃភាពជាអ្នកដឹកនាំ និងកិច្ចចាត់ចែងការ" ភ្នំពេញ, ទំព័រ ៣៥-៥៧

ដ៏សំខាន់ នៃការប្រត្តិបត្តិការប្រចាំថ្ងៃនៅក្នុងអាជីវកម្ម។ ការផ្លាស់ប្តូរជាច្រើនជួយធ្វើឱ្យអាជីវកម្មមានសមត្ថភាពថ្មី ការផ្លាស់ប្តូរនូវតម្លៃត្រូវបានផ្តល់ឱ្យជាមួយនឹងគុណសម្បត្តិនៃការប្រកួតប្រជែងនៅក្នុងអាជីវកម្ម។ ជាមួយនឹងបច្ចេកវិទ្យាកាន់តែច្រើន នៅក្នុងសកម្មភាពប្រចាំថ្ងៃ វាមានភាពងាយស្រួលជាច្រើននៃដំណើរការជារួមនៅក្នុងពេលតែមួយដែលទាមទារឱ្យមានពេលវេលា និងបុគ្គលិកជំនាញ។ ដូច្នេះ ពេលវេលានិងការខិតខំប្រឹងប្រែងជាច្រើនទៀត ផ្តោតលើសកម្មភាពអាជីវកម្ម ដែលនឹងជំរុញឱ្យមានកំណើន និងការទទួលបាននូវភាពជោគជ័យ ការបង្កើនប្រសិទ្ធភាព កាត់បន្ថយពេលវេលា និងការចំណាយលើការអនុវត្តនូវបច្ចេកវិទ្យាថ្មី។ បើតាម Raghunathan និង Kunnathar កត្តាដែលមានឥទ្ធិពលទៅលើការអនុវត្តនៃការប្រើប្រាស់បច្ចេកវិទ្យាថ្មីក្នុងអាជីវកម្មការប្រើប្រាស់បច្ចេកវិទ្យាគឺអាចបង្កើននូវផលិតភាព និងកាត់បន្ថយនូវតម្រូវការសមត្ថភាព មួយចំនួននៃកម្លាំងពលកម្ម មានជំនាញ បង្កើននូវសុវត្ថិភាព និងការកាត់បន្ថយនូវពេលវេលា។ ការរីកចម្រើនទាំងនេះ អាចទទួលបានអត្ថប្រយោជន៍ នៅក្នុងស្ថាប័នទាំងមូលធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាព និងប្រសិទ្ធផល។[35]

**១.៤.២.៥ គុណសម្បត្តិនៃបដិវត្តិឧស្សាហកម្ម៤.0**

បច្ចុប្បន្នយើងកំពុងអនុវត្តបដិវត្តឧស្សាហកម្មទី៤.0 ដែលត្រូវបានកំណត់លក្ខណៈដោយការអនុវត្តបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនងទៅកាន់ឧស្សាហកម្ម ហើយត្រូវបានគេស្គាល់ផងដែរថាជាឧស្សាហកម្មទី៤.0។ ប្រព័ន្ធផលិតកម្មដែលមានបច្ចេកវិទ្យាកុំព្យូទ័រ ត្រូវបានពង្រីកដោយការភ្ជាប់បណ្តាញ និងមានឌីជីថលភ្លោះនៅលើអ៊ីនធឺណេត។[36] មុនពេលនៃបដិវត្តឧស្សាហកម្មលេចឡើង ពិភពលោកបានប្រើប្រាស់ ផលិតផលក្នុងទ្រង់ទ្រាយតូច ដោយសារតែផលិតផលត្រូវបានបង្កើតឡើងយឺតៗ និងផលិតដោយដៃ។ រហូតមកដល់ពេលនេះ មនុស្សអាចផលិតទំនិញ និងចូលទៅក្នុងទីផ្សារក្នុងទ្រង់ទ្រាយធំដោយការប្រកួតប្រជែង ហើយអាចរស់នៅក្នុងជីវិតកាន់តែប្រសើរឡើង ដែលផ្តល់នូវផលិតផលជាច្រើនទៀតដូចជាសម្លៀកបំពាក់ គេហដ្ឋានប្រសើរជាងមុននិងរបស់ជាច្រើនទៀតដែលមនុស្សត្រូវការក្នុងជីវិតប្រចាំថ្ងៃនាពេលបច្ចុប្បន្ន។ គុណសម្បត្តិនៃបដិវត្តឧស្សាហកម្ម មានដូចខាងក្រោម៖

បង្កើតឱកាសការងារ៖ បដិវត្តឧស្សាហកម្មបានធ្វើឱ្យមនុស្សកាន់តែច្រើនមានការងារធ្វើ។ កាលពីមុនសម័យនេះ ការងារគឺផ្អែកលើការសិក្សាអប់រំ ប្រពៃណីគ្រួសារ ឬទេពកោសល្យពិសេសដែលនរណាម្នាក់មាន។ នៅពេលដែលរោងចក្រ ត្រូវបានចាប់ផ្តើមសាងសង់នៅជុំវិញពិភពលោក វាអនុញ្ញាតឱ្យមនុស្សអាចរកប្រាក់

---

[35] Z.Stanislous, (2008) " An Empirical Investigation Into the factors Affective thee performance of Small and medium Enterprise in the manufacturing sector of Harare, Zimbabwe".

[36] "Industrial Revolution - From Industry 1.0 to Industry 4.0", https://www.desouttertools.com/industry-4-0/news/503/industrial-revolution-from-industry-1-0-to-industry-4-0, (Accessed date 8 February 2022).

ចំណូលបានតាមរបៀបខុសពីអតីតកាលហើយវាបានផ្តល់ឱ្យមនុស្សជាមធ្យមនូវឱកាសដើម្បីផ្លាស់ប្តូរគោលបំណងរបស់ពួកគេ។

ផលិតផលកាន់តែច្រើនឡើង៖ មុនពេលបដិវត្តឧស្សាហកម្ម ផលិតផលជាច្រើនត្រូវបានបង្កើតឡើងឬផលិតដោយដៃ។ នេះទាមទារការចំណាយពេលវេលាជាក់លាក់ដោយអ្នកបង្កើត ដូច្នេះ ការផលិតទ្រង់ទ្រាយធំស្ទើរតែមិនអាចទៅរួចទេ។ ពោងចក្រមនុស្សតែម្នាក់ផលិតដោយខ្លួនឯង ដែលអនុញ្ញាតឱ្យផលិតផលិតផលកាន់តែប្រសើរឡើង ឬផ្តល់សេវាកម្មឱ្យកាន់តែប្រសើរឡើង និងអនុញ្ញាតឱ្យសហគមន៍លើកកម្ពស់គុណភាពនៃការរស់នៅរបស់ពួកគេតាមពេលវេលា ដោយសារមានលទ្ធភាពប្រើប្រាស់ទំនិញ និងសេវាកម្មកាន់តែច្រើន។[37]

ការវិវត្តឆ្ពោះទៅរកវិធីសាស្ត្រថ្នាំពេទ្យ៖ ភាពជឿនលឿនជាច្រើនដែលនាំទៅដល់ការអភិវឌ្ឍនៃការអនុវត្តផ្នែកវេជ្ជសាស្ត្រទំនើប បានកើតឡើងដោយសារតែការខិតខំប្រឹងប្រែងនៃបដិវត្តឧស្សាហកម្ម។ វាអាចបង្កើតឧបករណ៍ជាច្រើនទៀតដូចជា បំពង់សាកល្បង ស្ពែន និងឧបករណ៍មន្ទីរពិសោធន៍ក្នុងតម្លៃទាប ដូច្នេះមនុស្សកាន់តែច្រើនអាចចូលក្នុងវិស័យនេះ។ នៅពេលដែលបណ្តាញទំនាក់ទំនងមានភាពប្រសើរឡើងនៅទូទាំងពិភពលោក និងអ្នកស្រាវជ្រាវអាចធ្វើការរួមគ្នាដើម្បីស្វែងរកវិធីព្យាបាលថ្មី។ ការអនុវត្តល្អបំផុតថ្មី ត្រូវបានបង្កើតឡើងដោយផ្អែកលើការរកឃើញនៃការងារនេះ ហើយដំណើរការដែលនាំឱ្យមានការកើនឡើងគួរឱ្យកត់សម្គាល់នៃការថែទាំអ្នកជំងឺទូទាំងពិភពលោក។[38]

ការបង្កើតថ្មីផ្នែកបច្ចេកវិទ្យា៖ និន្នាការនេះ នៅតែបន្តកើតមាននាពេលបច្ចុប្បន្ននេះ ជាមួយនឹងសហគ្រិនដែលធ្វើការតតយប់ឈរដើម្បីអភិវឌ្ឍបច្ចេកវិទ្យា និងការច្នៃប្រឌិតថ្មីៗ។ ការបង្កើតបច្ចេកវិទ្យាបានបង្កើនទិន្នផលឧស្សាហកម្ម និងអនុញ្ញាតឱ្យមានការបង្កើតនូវទំនិញថ្មីៗ ដែលធ្វើឱ្យជីវិតមនុស្សកាន់តែប្រសើរឡើងនៅពេលនោះ ហើយថែមទាំងផ្តល់ការងារដល់ប្រជាជនផងដែរ។ វាក៏បាននាំទៅដល់កម្រិតនៃការលើកទឹកចិត្ត និងការអប់រំខ្ពស់ផងដែរ ដែលបណ្តាលឱ្យមានការច្នៃប្រឌិតថ្មីៗជាច្រើនដល់សព្វថ្ងៃនេះ។[39]

បដិវត្តឧស្សាហកម្មទី៤.០ ធ្វើឱ្យប្រជាពលរដ្ឋមានឱកាសបញ្ចេញមតិ ស្វែងរកដំណោះស្រាយរួម រដ្ឋនឹងទទួលបានអំណាចពីបច្ចេកវិទ្យាថ្មី ដើម្បីបង្កើនប្រសិទ្ធភាព ការគ្រប់គ្រងលើប្រជាជន ដោយផ្អែកលើប្រព័ន្ធឃ្លាំមើលជាមួយនឹងសមត្ថភាពនៃការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធឌីជីថល។ ការប្រើប្រាស់បច្ចេកវិទ្យាទំនើប និងជួយឱ្យការគ្រប់គ្រងកាន់តែប្រសើរ ជួយឱ្យរដ្ឋបាលសាធារណៈមានទំនើបកម្មផ្នែកហេដ្ឋចរនាសម្ព័ន្ធ និង

[37] Louise Gaille, "12 Industrial Revolution Pros and Cons", https://vittana.org/12-industrial-revolution-pros-and-cons, (Accessed date 8 February 2022).
[38] "19 biggest pros and cons of Industrial Revolution", https://futureofworking.com/8-biggest-pros-and-cons-of-industrial-revolution/,
[39] History Crunch Writers, "Positive of the Industrial Revolution", https://www.historycrunch.com/positives-of-the-industrial-revolution.html#/,

មុខងារបង្កើនការអនុវត្តន៍វិធានការរួម ការពង្រឹងដំណើរការអភិបាលកិច្ច ការប្រើប្រាស់ប្រព័ន្ធ អេឡិចត្រូនិច ដើម្បីតម្លាភាព គណនេយ្យភាព និងភាពស៊ីចង្វាក់គ្នារវាងរដ្ឋ និងប្រជាជន។

បច្ចេកវិទ្យារបស់បដិវត្តឧស្សាហកម្ម៤.0 ក៏អាចបង្កើនកម្រិតនៃភាពងាយស្រួលដល់មនុស្សផ្ទាល់ចំពោះអ្នកមានលទ្ធភាពប្រើប្រាស់សេវាកម្មឌីជីថល ព្រោះសេវាកម្មជាច្រើន ដូចជាការទិញទំនិញតាមអនឡាញ និងការកក់សំបុត្រយន្តហោះជាដើមនេះ បើតាម(Schwab,2016b)។ លើសពីនេះ ដោយសារទិន្នន័យអនឡាញជាច្រើន បញ្ជូនពីឧបករណ៍ផ្សេងៗ ដែលត្រូវបានតភ្ជាប់ទៅប្រព័ន្ធពពក(Cloud) បញ្ញាសិប្បនិម្មិតនឹងអាចធ្វើការវិភាគ និងព្យាករណ៍ ដើម្បីបង្កើតសេវាវៃឆ្លាតយ៉ាងឆាប់រហ័សសម្រាប់អតិថិជន។ ក្នុងវិស័យផ្សេងជាច្រើនដូចជា វិស័យសុខាភិបាល ដឹកជញ្ជូន សេវាកម្មធានារ៉ាប់រង ហិរញ្ញវត្ថុ និងសេវាសាធារណៈទូទាំងប្រទេស។ ឧស្សាហកម្ម៤.0 នាំមកនូវកាលានុវត្តភាពសេដ្ឋកិច្ចបន្ថែមទៀតដល់វិស័យឧស្សាហកម្មរបស់ប្រទេសនានា ដែលអាចធ្វើការផ្លាស់ប្តូរបច្ចេកវិទ្យា និងប្រព័ន្ធឌីជីថលរបស់ខ្លួន។ គេបានរកឃើញថា បណ្តាប្រទេសទាំងឡាយណា ដែលបានវិនិយោគលើបច្ចេកវិទ្យា អ៊ីនធឺណេតនៅក្នុងឧស្សាហកម្ម ត្រូវបានព្យាករណ៍ថានឹងទទួលបានផលចំណេញបានកាន់តែខ្ពស់ លើកំណើនតម្លៃសេដ្ឋកិច្ចរបស់ខ្លួន។ បើតាមរបាយការណ៍ Accenture and General Electri ក្នុងឆ្នាំ២០១៥ បានបង្ហាញថា ការអភិវឌ្ឍ បច្ចេកវិទ្យាឧស្សាហកម្ម៤.0 នៅក្នុងវិស័យឧស្សាហកម្មផ្សេងៗ អាចផ្តល់កាលានុវត្តភាពសេដ្ឋកិច្ចខ្ពស់ ហើយសហរដ្ឋអាមេរិកទំនងជាប្រទេសដែលទទួលបានអត្ថប្រយោគជ័យច្រើនបំផុតដែលទទួលបានពីការអភិវឌ្ឍនោះ។ បន្ទាប់ពីសហរដ្ឋអាមេរិក គឺប្រទេសចិន អាល្លឺម៉ង់ និងចក្រភពអង់គ្លេស នេះបើតាម(Petrillo, Felice, Cioffi& Zomparelli, 2018)។ សម្រាប់សហគ្រាសតូច និងមធ្យម ក៏នឹងទទួលបាន ឱកាសបង្កើនផលិតភាព និងប្រសិទ្ធភាពពីបច្ចេកវិទ្យាថ្មីៗ ដូចជា ឧបករណ៍ចាប់សញ្ញា(Sensors) និងប្រព័ន្ធវិភាគទិន្នន័យធំៗ ដែលអាចជួយឱ្យមានការយល់ដឹងកាន់តែច្បាស់ដំណើការផលិតកម្ម ជួយពួកគេស្វែងរកជម្រើសដែលត្រូវការពេលវេលា និងធនធានតិចជាងមុន សម្រាប់ផលិតកម្មរបស់ខ្លួន។[40]

កាលានុវត្តភាពនៃបដិវត្តឧស្សាហកម្មទី៤.0 អ្វីក៏ដោយតែងមានគុណសម្បត្តិជាក់ស្តែងបដិវត្តឧស្សាហកម្មទី៤.0 ក៏ដូចគ្នាដែរ។ ការចាប់យកឱកាសមកប្រើប្រាស់ និងទាញផលប្រយោជន៍នៃទំនើបកម្មឌីជីថលថ្មីនេះ បានផ្តល់នូវកាលានុវត្តភាព។ ការលានុវត្តភាពប្រទេសកម្ពុជា បានត្រៀមលក្ខណៈមួយចំនួនដើម្បីចាប់យកឱកាសជាច្រើន ដែលបានមកពីបដិវត្តឧស្សាហកម្មទី៤.0។ បដិវត្តឧស្សាហកម្មទី៤.0 នឹងធ្វើឱ្យចំណេញពេលវេលាច្រើនមានន័យថាអ្នកគ្រប់គ្រងសហគ្រាសផលិតកម្មទាំងអស់ទាំងវិស័យឧស្សាហកម្ម

[40] មជ្ឈមណ្ឌលអភិវឌ្ឍកម្ពុជា (២០២១) ស្វែងយល់ពីបដិវត្តឧស្សាហកម្មទី៤

កសិកម្ម និងវិស័យទេសចរណ៍ គឺមិចាំបាច់ចំណាយពេលវេលាទៅស្វែងរកព័ត៌មានទេ គឺគាត់អាចមានព័ត៌មាន ដោយគ្រាន់តែមានទូរស័ព្ទមួយដែលភ្ជាប់ប្រព័ន្ធអ៊ិនធឺណេត គឺអាចគ្រប់គ្រងទិន្នន័យបាន។ វិស័យឧស្សាហកម្មក៏ដូចគ្នាដែរ និងទទួលបានផលប្រយោជន៍ពីបដិវត្តឧស្សាហកម្មថ្មីនេះកាន់តែខ្ពស់ ព្រោះឧស្សាហកម្មប្រើនូវគ្រឿងម៉ាស៊ីនជំនួសឱ្យកម្លាំងពលកម្ម ដែលធ្វើឱ្យកត្តាផលិតកម្មចំណាយតិច និងផ្តល់ផលចំណេញជាច្រើនដល់ម្ចាស់មូលធន និងវិនិយោគគ្រិន ដែលជាកត្តាទាក់ទាញអ្នកវិនិយោគមកកាន់តែច្រើន នាំឱ្យប្រទេសមានការរីកចម្រើនឆាប់រហ័សលើគ្រប់វិស័យ និងអាចក្លាយជាប្រទេសមួយដែលមានភាពស្ទាត់ជំនាញក្នុងការប្រើប្រាស់គ្រឿងអេឡិចត្រូនិក និងបច្ចេកវិទ្យាឌីជីថល។[41] ឧស្សាហកម្មទី៤.0 បានផ្តល់នូវកាលានុវត្តភាព ដូចជា ១. ការនាំមកនូវភាពជឿនលឿន ផ្នែកបច្ចេកវិទ្យា ដូចជា រ៉ូប៉ូត ការបោះពុម្ព 3D ការចែកចាយសៀវភៅ ឌីជីថលតាមអ៊ិនធឺណេត បញ្ញាសិប្បនិម្មិត បច្ចេកវិទ្យាណាណូ ដែលធ្វើឱ្យផ្លាស់ប្តូររបៀបរបកនៃការរស់នៅជាមួយនឹងភាពច្នៃប្រឌិតថ្មីៗ ដើម្បីលើស្ទួយជីវភាពគ្រួសារ និងសង្គម។ [42]

### ១.៤.២.៥ គុណវិបត្តិនៃបដិវត្តិឧស្សាហកម្ម ៤.0

បដិវត្តឧស្សាហកម្មក៏នាំមកនូវគុណវិបត្តិមួយចំនួនផងដែរ ដែលក្នុងនោះរួមមាន ការកើនឡើងនៃបញ្ញាសិប្បនិម្មិត និងប្រព័ន្ធស្វ័យប្រវត្តិកម្ម នៅក្នុងវិស័យការងារ ដែលអាចជំនួសកម្លាំងពលកម្មរបស់មនុស្ស ហើយអាចនាំឱ្យឈានទៅដល់ការបាត់បង់ការងារ និងនាំឱ្យមានកំណើននៃនិកម្មភាពកាន់តែខ្ពស់ជាងមុខ។ យោងតាមរបាយការណ៍ធនាគាពិភពលោកនៅឆ្នាំ២០១៦ ការងារនៅក្នុងប្រទេសចិន ប្រមាណ ៧៧ភាគរយស្ថិតនៅក្រោមហានិភ័យនៃការជំនួសដោយស្វ័យប្រត្តិកម្ម(City and Oxford Martin School,2016) ទោះបីជាបំលាស់ប្តូរការងាររបស់កម្មករ ពឹងផ្អែកលើសន្ទុះនៃការចាប់យកបច្ចេកវិទ្យា មកប្រើប្រាស់ដោយស្ថាប័នជំនួញ និងសេដ្ឋកិច្ចក៏ដោយ។ កម្មករប្រមាណ៣៧៥លាននាក់នឹងនៅតែត្រូវការផ្លាស់ប្តូរមុខរបរបស់ខ្លួន នៅឆ្នាំ២០៣០ ដដែល(Mckinsey Global Institute, 2017) ។

គុណវិបត្តិនៃបដិវត្តឧស្សាហកម្មទី៤.0 មានមួយចំនួនផងដែរ ជាក់ស្តែងមិនអាចប្រកែកបាននោះ គឺការបាត់បង់ឱកាសការងារមួយចំនួន។ ប្រទេសកម្ពុជា គម្លាតក្នុងការប្រើប្រាស់បច្ចេកវិទ្យា បើធៀបទៅនឹងប្រទេសដែលមានការរីកចម្រើនខាងវិទ្យាសាស្ត្រ តួយ៉ាងប្រទេសសិង្ហបុរី និងចិនជាដើម។ ពាក់ព័ន្ធនឹង សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណេតវិញ វិស័យនេះអាចរងការគំរាមកំហែងដែលប្រទេសលើពិភពលោកព្រួយបារម្ភយ៉ាងខ្លាំង។ បច្ចេកវិទ្យា នឹងទំនើបកម្មឌីជីថល អាចនឹងជំរុញឱ្យមានសង្គ្រាមតាមប្រព័ន្ធអ៊ីនធឺណេត កើតឡើង

---

[41] ទាវ រដ្ឋា , (ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២០) "តើកម្ពុជាត្រៀមខ្លួនដូចម្តេចសម្រាប់បដិវត្តន៍ឧស្សាហកម្មទី ៤"

[42] ហ៊ាប សាហ៊ីប ,(២០២១) "ទស្សនៈសេដ្ឋកិច្ច និងវិទ្យាសាស្ត្រសេដ្ឋកិច្ច" ភ្នំពេញ ទំព័រ ៥០១-៥០២

នៅពេលអនាគត ដោយសារប្រទេសនៅជុំវិញពិភពលោក មានការរីកចម្រើនខាងវិទ្យាសាស្ត្រ ព័ត៌មានវិទ្យា និងប្រព័ន្ធអេឡិចត្រូនិកយ៉ាងខ្លាំងក្លា។[43] បដិវត្តឧស្សាហកម្មវាមានគុណវិបត្តិមួយចំនួនដូចជាស្ថានភាពរស់នៅដ៏អាក្រក់សម្រាប់កម្មករ៖ យោងតាមប្រវត្តិសាស្ត្រនៅពេលដែលទីក្រុងរីកចម្រើនក្នុងអំឡុងបដិវត្តឧស្សាហកម្ម មិនមានលំនៅដ្ឋានគ្រប់គ្រាន់សម្រាប់អ្នករស់នៅថ្មីៗទាំងអស់ ដែលត្រូវបានជាប់គាំងនៅក្នុងតំបន់ ខណៈដែលអ្នកស្រុកជាច្រើនបានផ្លាស់ទៅរស់នៅជាយក្រុង។

ផលប៉ះពាល់បរិស្ថាន៖ បដិវត្តឧស្សាហកម្ម ត្រូវបានដំណើរការដោយការដុតធ្យូងថ្ម ហើយទីក្រុងឧស្សាហកម្មធំៗ បានចាប់ផ្តើមស្រូបជាតិពុលក្នុងបរិមាណដ៏ច្រើនចូលទៅក្នុងបរិយាកាស។ កំហាប់នៃភាគល្អិត នៅទីក្រុងឡុងដ៍បានកើនឡើងយ៉ាងខ្លាំងនៅចន្លោះឆ្នាំ១៧៦០ និង១៨៣០។[44] ការបំពុលនៅទីក្រុង Manchester ពិតជាអាក្រក់ណាស់ នេះបើតាម Hugh Miller បានកត់សម្គាល់ថា "ភាពអាប់អួរនៃបរិយាកាសដែលគ្របសង្កត់វា" ហើយបានពណ៌នាអំពីបំពង់ផ្សែងជាច្រើន ដែលចូលមកក្នុងបរិយាកាស ហើយងងឹតក្នុងផ្សែងអ័ព្ទ។ ជាងនេះទៅទៀត ការបំពុលខាងក្នុងទីក្រុង មានការកើនឡើងភ្លាមៗពីរោងចក្រ និងចំនួនប្រជាជនកើនឡើង នៅពេលដែលកម្មករកាន់តែច្រើន បានផ្លាស់ប្តូរទៅទីក្រុង។[45] ស្ថានភាពរស់នៅក្នុងកន្លែងខ្លះមានទឹកស្អុយ ហើយកាកសំណល់បានជន់លិចផ្លូវ និងទន្លេ។

ពលកម្មកុមារ៖ ខណៈពេលដែលកុមារធ្វើការមុនបដិវត្តឧស្សាហកម្ម កត្តារីកចម្រើនយ៉ាងឆាប់រហ័សបានបង្កើតឱ្យមានតម្រូវការដែលយុវជនក្រីក្រ និងកុមារកំព្រាត្រូវបានចាកចេញពីផ្ទះក្រីក្រនៅទីក្រុងឡុងដ៍ ហើយស្នាក់នៅក្នុងអន្តេវាសិកដ្ឋានរោងម៉ាស៊ីន ខណៈពេលដែលពួកគេធ្វើការច្រើនម៉ោង និងគ្មានការសិក្សាអប់រំ។[46]

ពលករចំណាកស្រុក៖ ឧស្សាហូបនីយកម្មជាធម្មតានាំឱ្យមានការធ្វើចំណាកស្រុករបស់កម្មករទៅកាន់ទីក្រុង ស្វ័យប្រវត្តិកម្ម និងការងារដដែលៗ។ ដោយសារកត្តាទាំងនេះ កម្មកររោងចក្រមានទំនោរបាត់បង់បុគ្គលិកលក្ខណៈរបស់ពួកគេ ការពេញចិត្តនឹងការងារនៅមានកម្រិត និងមានអារម្មណ៍ថាដាច់ឆ្ងាយពីគេ

---

[43] ទាវ រដ្ឋា , (ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២០) "តើកម្ពុជាត្រៀមខ្លួនដូចម្តេចសម្រាប់បដិវត្តន៍ឧស្សាហកម្មទី ៤"

[44] Patrick J.Kiger, "7 Negative Effects of the Industrial Revolution", https://www.history.com/news/industrial-revolution-negative-effects,

[45] "Industrial Revolution", https://corporatefinanceinstitute.com/resources/knowledge/economics/industrial-revolution/,

[46] "Positive and Negative impacts of the Industrial Revolution", https://www.ipl.org/essay/Positive-And-Negative-Impacts-Of-The-Industrial-FJ3CAJW5SQU, (Accessed date 12 February 2022).

ហើយក៏អាចមានបញ្ហាសុខភាពដែលបណ្ដាលមកពីស្ថានភាពការងារដ៏គ្រោះថ្នាក់ ឬកត្តាដែលមាននៅក្នុងការងារ ដូចជាសំឡេង និងភាពកខ្វក់ជាដើម។[47]

បដិវត្តឧស្សាហកម្មទី៤.0 ក៏បានផ្តល់នូវផលអវិជ្ជមានមួយចំនួនហើយអ្វីដែលជាក់ស្តែងមិនអាចប្រកែកបាននោះ គឺការបាត់បង់ឱកាសការងារ។ ឧទាហរណ៍កាលពីមុនគេប្រើមនុស្ស ១០នាក់ តែបន្ទាប់ពីគេប្រើប្រាស់រ៉ូបូតជំនួសកម្លាំងមនុស្ស គេអាចត្រូវការមនុស្សតែ២ ឬ៣នាក់ប៉ុណ្ណោះសម្រាប់ជំនួសគ្រឿងម៉ាស៊ីន និងត្រួតពិនិត្យដំណើរការផលិតកម្ម នេះបើតាម ភារៈ(២០១៩)។ ប្រទេសកម្ពុជា មានគម្លាតក្នុងការប្រើប្រាស់បច្ចេកទេស បើធៀបទៅនឹងប្រទេសដែលមានការរីកចម្រើនខាងវិទ្យាសាស្ត្រ តួយ៉ាងសិង្ហបុរី និងចិន ជាដើម។ ម្យ៉ាងទៀត ពាក់ព័ន្ធនឹងសន្តិសុខតាមប្រព័ន្ធអ៊ិនធឺណេតវិញ វិស័យនេះអាចនឹងរងការគំរាមគំហែងដែលប្រទេសលើពិភពលោកព្រួយបារម្ភយ៉ាងខ្លាំង ព្រោះនៅពេលព័ត៌មានផ្ទាល់ខ្លួន គណនីធនាគារ និងព័ត៌មានផ្សេងៗ ត្រូវបានបញ្ចូលក្នុងប្រព័ន្ធបច្ចេកវិទ្យាទំនើបៗ។ បច្ចេកវិទ្យានិងទំនើបកម្មឌីជីថល អាចនឹងជំរុញឱ្យមានសង្គ្រាមតាមប្រព័ន្ធអ៊ិនធឺណេតកើតឡើងនៅថ្ងៃអនាគតដោយសារប្រទេសជុំវិញពិភពលោកមានការរីកចម្រើនខាងវិទ្យាសាស្ត្រ ព័ត៌មានវិទ្យា និងប្រព័ន្ធអេឡិចត្រូនិកយ៉ាងខ្លាំងក្លា។[48]

លើសពីនេះ ទៀតបដិវត្តឧស្សាហកម្ម៤.0 បានបង្កើតនូវគុណវិបត្តិដល់សង្គម សេដ្ឋកិច្ច រួមមានដូចខាងក្រោម៖

១. ដើមទុនៈ ការផ្លាស់ប្តូរបច្ចេកវិទ្យានានា ក្នុងប្រពន្ធ័ច្រវ៉ាក់ផលិតកម្ម និងត្រូវការវិនិយោគយ៉ាងច្រើនលើបច្ចេកវិទ្យាថ្មី ផ្នែកបញ្ញាសិប្បនិម្មិត បច្ចេកវិទ្យា រ៉ូបូត ដែលធ្វើឱ្យអាជីវកម្មតូចតាចអាចប្រឈមផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ។

២.សន្តិសុខៈ ទិដ្ឋភាពប្រឈមក្នុងការអនុវត្តក្របខណ្ឌបច្ចេកវិទ្យាគឺហានិន័យសន្តិសុខហានិភ័យ ព ត៌មានវិទ្យា។ ការបញ្ចូលពត៌មានតាមអ៊ិនធឺណេតអាចបង្កើតការលេចធ្លាយទិន្នន័យ និងការបំពានសន្តិសុខព ត៌មាន។ ចោរកម្មតាមអ៊ិនធឺណេត ធ្វើឱ្យផលិតករខាតបង់ព្រមទាំងការបំផ្លាញកិត្តិនាមជាដើម។

៣. ភាពឯកជន ទិន្នន័យឯកជន មានសារៈសំខាន់ចំពោះអតិថិជន និងផលិតករប្រសិនបើទិន្នន័យពុំមានតម្លាភាពអាចក្លាយជាបញ្ហាប្រឈមសម្រាប់ភាគីទាំងពីរនៅពេលដែលទិន្នន័យត្រូវបានប្រើខុស។ [49]

---

[47] ANDRIY BLOKHIN, "What are some of the drawbacks of the industrialization?", https://www.investopedia.com/ask/answers/072815/what-are-some-drawbacks-industrialization.asp, (Accessed date 12 February 2022).

[48] តើកម្ពុជាគួរត្រៀមខ្លួនដូចម្តេច សម្រាប់បដិវត្តន៍ឧស្សាហកម្មទី៤?

[49] ហ៊ាប សាហ៊ីប , (២០២១) "ទស្សនៈសេដ្ឋកិច្ច និងវិទ្យាសាស្ត្រសេដ្ឋកិច្ច" ភ្នំពេញ ទំព័រ ៥០៣

អភិបាលកិច្ចសេដ្ឋកិច្ចពិភពលោកមិនគ្រប់គ្រាន់ធ្វើឱ្យពិបាកក្នុងការសម្របខ្លួនទៅនឹងការអភិវឌ្ឍន៍ថ្មី នៅក្នុងសេដ្ឋកិច្ចពិភពលោក។ លោកស្រីគ្រីស្ទីន ថ្មីៗនេះបាននិយាយថា ទីផ្សារដែលកំពុងរីកចម្រើន និងប្រទេសកំពុងអភិវឌ្ឍន៍បានរួមចំណែកដល់ ៨០ភាគរយនៃកំណើនសេដ្ឋកិច្ចពិភពលោករួចហើយ។ ទិដ្ឋភាពសេដ្ឋកិច្ចពិភពលោកបានផ្លាស់ប្តូរយ៉ាងខ្លាំងក្នុងរយៈពេលប៉ុន្មានទសវត្សរ៍កន្លងមកនេះ។ ប្រព័ន្ធអភិបាលកិច្ចសកលមិនបានទទួលយកការផ្លាស់ប្តូរថ្មីទាំងនោះទេ។ ទិដ្ឋភាពឧស្សាហកម្មសកល ក៏កំពុងផ្លាស់ប្តូរដែរ ហើយខ្សែសង្វាក់ឧស្សាហកម្មថ្មី ខ្សែសង្វាក់តម្លៃ និងខ្សែសង្វាក់ផ្គត់ផ្គង់។ ទោះជាយ៉ាងណាក៏ដោយ ច្បាប់ពាណិជ្ជកម្ម និងការវិនិយោគមិនបានរក្សាល្បឿនជាមួយនឹងការវិវឌ្ឍទាំងនេះទេ។ ទីផ្សារហិរញ្ញវត្ថុសកល ត្រូវតែមានភាពធន់នឹងហានិភ័យ ប៉ុន្តែយន្តការអភិបាលកិច្ចហិរញ្ញវត្ថុសកលមិនអាចបំពេញតាមតម្រូវការថ្មី និងមិនអាចដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាព ដូចជាការប្រែប្រួលទីផ្សារហិរញ្ញវត្ថុអន្តរជាតិញឹកញាប់ និងការឡើងនៃពពុះទ្រព្យសកម្មនោះទេ។

ការអភិវឌ្ឍន៍សកលលោកមិនស្មើគ្នា ធ្វើឱ្យមានការលំបាកក្នុងការបំពេញ តាមការរំពឹងទុករបស់មនុស្សសម្រាប់ជីវិតកាន់តែប្រសើរឡើង។ លោកបណ្ឌិត សខ្វ៉ប បដិវត្តឧស្សាហកម្មទី៤.0 ថាបដិវត្តឧស្សាហកម្មនេះនឹងមានផលប៉ះពាល់យ៉ាងទូលំទូលាយដូចជា វិសមភាពដែលកំពុងកើនឡើង ជាពិសេសគម្លាតដែលអាចកើតមានរវាងការត្រឡប់មកវិញនៃដើមទុន និងត្រឡប់មកវិញលើកម្លាំងពលកម្ម។ អ្នកមានបំផុត១ភាគរយនៃចំនួនប្រជាជនពិភពលោកមានទ្រព្យសម្បត្តិច្រើនជា ៩៩ ភាគរយដែលនៅសល់បញ្ចូលគ្នា។ វិសមភាពក្នុងការបែងចែកប្រាក់ចំណូល និងលំហអភិវឌ្ឍន៍មិនស្មើគ្នាកំពុងតែព្រួយបារម្ភ។ មនុស្សជាង៧00លាននាក់នៅលើពិភពលោក នៅតែរស់នៅក្នុងភាពក្រីក្របំផុត។ សម្រាប់គ្រួសារជាច្រើន ការមានផ្ទះកក់ក្តៅ អាហារគ្រប់គ្រាន់ និងការងារមានសុវត្ថិភាពនៅតែជាសុបិនឆ្ងាយ។ នេះគឺជាបញ្ហាប្រឈមដ៏ធំបំផុត ដែលពិភពលោកកំពុងប្រឈមមុខសព្វថ្ងៃ។ វាក៏ជាអ្វីដែលនៅពីក្រោយភាពចលាចលសង្គមនៅក្នុងប្រទេសមួយចំនួនផងដែរ។ បញ្ហាជាមួយនឹងកំណើនសេដ្ឋកិច្ចពិភពលោក អភិបាលកិច្ច និងគំរូអភិវឌ្ឍន៍ពិតមែន ហើយបញ្ហាទាំងនេះត្រូវតែដោះស្រាយ។ ស្ថាបនិកកាកបាទក្រហម ហេនរី ដូណាន់ (Henry Dunant) ធ្លាប់បាននិយាយថា "សត្រូវពិតប្រាកដរបស់យើង មិនមែនជាប្រទេសជិតខាងទេ។ វាគឺជាភាពអត់ឃ្លាន ភាពក្រីក្រ ភាពល្ងង់ខ្លៅ ជំនឿឆ្វេង និងការប្រកាន់ពូជសាសន៍"នេះ បើតាម Xi Jinping ។[50]

[50] Xi Jinping: We must face up to the problems of globalization

## ១.៥.ផលិតផលក្នុងស្រុកសរុប

វិបត្តិសេដ្ឋកិច្ចបានកើតឡើងនៅទសវត្សរ៍ឆ្នាំ១៩៧០ និងឆ្នាំ១៩៨០ បង្កឱ្យមានការធ្លាក់ចុះនូវកំណើនសេដ្ឋកិច្ចពិភពលោក និងបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់សង្គមសម្រាប់ប្រទេសកំពុងការអភិវឌ្ឍ នៅតំបន់អាស៊ីប៉ាស៊ីហ្វិក។ ប្រទេសកូរ៉េខាងត្បូង តៃវ៉ាន់ និងសិ=-ង្ហបុរី គេចផុតពីវិបត្តិនេះ ដោយជោគជ័យ ហើយបានបង្កើតមូលដ្ឋានគ្រឹះសម្រាប់ផ្នែកផលិតឧស្សាហកម្មបែបទំនើប ដូច្នេះហើយទើបប្រទេសទាំងនេះ បង្ហាញឱ្យឃើញពីគំរូការអភិវឌ្ឍសេដ្ឋកិច្ច ដែលមានភាពជោគជ័យបំផុត។ សេដ្ឋកិច្ចពិភពលោក និងការធ្វើពាណិជ្ជកម្មពីអន្តរជាតិមានការធ្លាក់ចុះនៅដើមទសវត្សរ៍ឆ្នាំ១៩៩០ អត្រាកំណើនសេដ្ឋកិច្ចគឺមានកម្រិតខ្ពស់ពី៧ភាគរយទៅ១០ភាគរយសម្រាប់ប្រទេសកូរ៉េខាងត្បូង តៃវ៉ាន់ និងសិង្ហបុរី។ អត្រាកំណើនផលិតផលក្នុងស្រុកសរុប (GDP) របស់បណ្តាប្រទេសនៅតំបន់អាស៊ីប៉ាស៊ីហ្វិក គឺស្ថិតក្នុងកំរិតមធ្យម ៧.៧ភាគរយ ហើយកំណើនសេដ្ឋកិច្ចនៅប្រទេសម៉ាឡេស៊ី និងថៃមានការកើនឡើងដល់៦.៦ភាគរយ នេះបើតាម Litsareva 2004។ ASEAN ត្រូវបានមើលឃើញថាជាបណ្តុំសេដ្ឋកិច្ច វាអាចត្រូវបានគេចាត់ចូលក្នុងចំណោមសេដ្ឋកិច្ចទាំង១០តាមរយៈផលិតផលក្នុងស្រុកសរុប (GDP)។ ផលិតផលក្នុងស្រុកសរុប (GDP) នៅក្នុងប្រទេសជាសមាជិកអាស៊ានសម្រេចបាននូវកំណើនសេដ្ឋកិច្ច ជាមធ្យមរវាង៣.៨ភាគរយ និង៧ភាគរយនៅក្នុងឆ្នាំ១៩៨៩-២០០៩ ហើយកំណើនផលិតផលក្នុងស្រុកសរុប(GDP) ប្រចាំឆ្នាំក្នុងចំណោមប្រទេសឆ្នើមទាំង៥ នៃរដ្ឋជាសមាជិកអាស៊ាន ត្រូវបានកត់ត្រាទុកដោយ IMF នៅត្រឹមអត្រា ៦.៨ភាគរយក្នុងឆ្នាំ២០១០។ ថ្មីៗនេះនាដំណាច់ឆ្នាំ២០១៥ ASEANបានបង្កើតនូវទីផ្សាររួមមួយដោយការបង្កើតនូវ ASEAN Economic Community (AEC)ដែលជាការស្ថាបនានូវសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ដែលមានប្រជាជនប្រមាណ ៦០០លាននាក់និងមានលទ្ធភាពកំណើនធំធេង(Panenungi2011)។

### ១.៥.១ ការប្រើប្រាស់បច្ចេកវិទ្យា( ICT )

បច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាន(ICT) មានទំនាក់ទំនងនឹងកំណើនសេដ្ឋកិច្ចក្នុងប្រទេសអាស៊ាន ក្នុងឆ្នាំ២០០៣ ដល់ឆ្នាំ២០១៨។ ការប្រើប្រាស់ទូរស័ព្ទចល័ត(lnMCT) និងការប្រើប្រាស់ខ្សែទូរស័ព្ទថេរ (lnFT) នៅក្នុងប្រទេសអាស៊ាន មានឥទ្ធិពលវិជ្ជមានយ៉ាងសំខាន់លើកំណើនសេដ្ឋកិច្ចដែលមានកម្រិតសារៈសំខាន់ ១ភាគរយ។ ការប្រើប្រាស់ខ្សែទូរស័ព្ទ(lnFT) គឺជាកត្តាដ៏សំខាន់បំផុតក្នុងចំណោម អថេរឯករាជ្យការប្រើប្រាស់បច្ចេកវិទ្យា(ICT) មានឥទ្ធិពលលើកំណើនសេដ្ឋកិច្ច។ ការកើនឡើងក្នុងការប្រើប្រាស់ខ្សែទូរស័ព្ទថេរជាមធ្យម នាំឱ្យកំណើនសេដ្ឋកិច្ចកើនឡើង។ លទ្ធផលបង្ហាញថា ការប្រើប្រាស់បច្ចេកវិទ្យា(ICT) ជះឥទ្ធិពលដល់កំណើនសេដ្ឋកិច្ចក្នុងប្រទេសអាស៊ាន។ ការអភិវឌ្ឍន៍នៃការប្រើប្រាស់បច្ចេកវិទ្យា(ICT) នៅក្នុងគោលនយោបាយ នាពេលអនាគត ដើម្បីជំរុញកំណើនសេដ្ឋកិច្ចក្នុងប្រទេសអាស៊ាន។ គោលនយោបាយបទប្បញ្ញត្តិមានសារៈសំខាន់ ក្នុងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ដើម្បីជំរុញការប្រើប្រាស់បច្ចេកវិទ្យា(ICT) កម្រិតខ្ពស់ ដើម្បីបង្កើនកំណើនសេដ្ឋ

កិច្ចក្នុងប្រទេស។ កំណើនសេដ្ឋកិច្ចអាស៊ាន អាចត្រូវបានជំរុញ តាមរយៈការអនុវត្តគោលនយោបាយការប្រើប្រាស់បច្ចេកវិទ្យា(ICT) ដើម្បីប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ។ ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋាភិបាល និងការអភិវឌ្ឍន៍គោលនយោបាយដែលជំរុញកំណើននៃការប្រើប្រាស់បច្ចេកវិទ្យា(ICT) នៅប្រទេសអាស៊ាន នឹងលើកកម្ពស់កំណើនសេដ្ឋកិច្ច។

បើតាម Bracken និង Garsombke បានយល់ឃើញថា សហគ្រាសដែលបានប្រើប្រាស់បច្ចេកវិទ្យា នឹងទទួលបានបទពិសោធន៍ នៃការប្រើប្រាស់បច្ចេកវិទ្យាថ្មីមានភាពល្អប្រសើរ និងបង្កើតនូវធាតុចេញនៅក្នុងផលិតកម្មដោយកាត់បន្ថយនូវពេលវេលា ហើយនឹងបង្កើនប្រាក់ចំណេញកាន់តែច្រើនឡើង។ បើតាម Yankelovich Partner អ៊ីនធឺណិតមានឥទ្ធិពលទៅលើអាជីវកម្មដោយចំនួន ៥៧ភាគរយ នៃម្ចាស់អាជីវកម្មទំនងជាបានប្រើប្រាស់អ៊ីនធឺណេតដើម្បីជួយឱ្យអាជីវកម្មមានការអភិវឌ្ឍមួយកម្រិតទៀត។ កាប្រើប្រាស់រួមមាន E-mail Server ដើម្បីរក្សាទុក និងផ្ញើរ E-mail វាគឺជាឧបករណ៍សម្រាប់ធ្វើទីផ្សារ និងការលក់ដើម្បីជំរុញផ្នែកលក់ ការផ្សព្វផ្សាយ និងការធ្វើពាណិជ្ជកម្ម។ ការប្រើប្រាស់បច្ចេកវិទ្យាបានផ្តល់នូវគុណសម្បត្តិជាច្រើនដល់ម្ចាស់សហគ្រាស។ ការដាក់ឱ្យប្រើប្រាស់នូវបច្ចេកវិទ្យាមានប្រៀបមួយកម្រិតជាមួយគូប្រកួតប្រជែងនៅក្នុងការធ្វើអាជីវកម្ម។ ប្រសិនបើគូប្រកួតប្រជែង យើងមានឆន្ទៈក្នុងការប្រើប្រាស់បច្ចេកវិទ្យាថ្មី នឹងទទួលបាននូវគុណសម្បត្តិ នៃការកើនឡើងនៃប្រសិទ្ធភាព និងផលិតភាព។ បច្ចេកវិទ្យាត្រូវបានគេប្រើប្រាស់ក្នុងការបង្កើន សមត្ថភាព និងប្រសិទ្ធភាពអាជីវកម្ម។

បច្ចេកវិទ្យាទំនាក់ទំនងព័ត៌មានបានក្លាយជាកត្តាចាំបាច់បំផុតមួយដើម្បីបន្តដំណើរការរីកលូតលាស់នៅលើសកលលោក ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន(ICT) ក្នុងដំណើរការធ្វើជំនួញ គឺតម្រូវការជាចាំបាច់បើគ្មានការប្រើប្រាស់បច្ចកវិទ្យា(ICT)នេះទេ ការធ្វើជំនួញនឹងប្រឈមមុខយ៉ាងខ្លាំងសម្រាប់ក្រុមហ៊ុននានាធ្វើការប្រកួតប្រជែងក្នុងទីផ្សារលើពិភពលោក។ បើតាម Frempong នៅឆ្នាំ២០០៧ បានឱ្យដឹងទៀតថា ហេតុផលគឺថាការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន(ICT) កំពុងវិវឌ្ឍនៅជុំវិញសកម្មភាពទាំងអស់ក្នុងទីផ្សារសកលលោកខណៈដែលបច្ចេកវិទ្យាព័ត៌មាន(ICT) មានតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលដំណើរការធ្វើជំនួញប្រកបដោយប្រសិទ្ធភាពខ្ពស់។

### ១.៥.២ កំណើនការនាំចេញបច្ចេកវិទ្យាខ្ពស់

កំណើន GDP វិស័យបច្ចេកវិទ្យានៃប្រទេសកម្ពុជា ចាប់ពីឆ្នាំ2011 ($7,198,370.00) ដល់ឆ្នាំ2013($73,018,956.00) មានការកើនឡើងខ្លាំង ហើយធ្លាក់ចុះវិញនៅឆ្នាំ2014 ($31,192,962.00) ហើយក៏កើនឡើងជាលំដាប់រហូតដល់ឆ្នាំ2017($177,204,852.00)និងធ្លាក់ចុះរហូតដល់ឆ្នាំ2020 ($102,244,706.89)។ កំណើនGDP វិស័យបច្ចេកវិទ្យានៃប្រទេសអាល្លឺម៉ង់ ចាប់ពីឆ្នាំ2011) $203, 237,045,(896.00 ដល់ឆ្នាំ2014

$216,297,040, 017.0បានកើនឡើងតាមលំដាប់ ហើយធ្លាក់ចុះវិញបន្តិចនៅឆ្នាំ2015($199,797,306,303.00) ឡើងវិញបន្តិចនៅឆ្នាំ2016 ($206,133 ,813 ,845.00) និងធ្លាក់ចុះវិញនៅឆ្នាំ2017 ($195,752,362,801.00) ហើយក៏កើនឡើងវិញទៀតនៅឆ្នាំ 2018 ($210, 082,307,180.00) ហើយក៏បន្តធ្លាក់ចុះរហូតដល់ឆ្នាំ 2020 $180,663,902, 528.00ចំណែក ឯកំណើន GDP វិស័យបច្ចេកវិទ្យា នៃប្រទេសសិង្ហបុរី បានកើនឡើងចាប់ពីឆ្នាំ 2011 ($132,291 ,714,560.00) ដល់ឆ្នាំ2014 ($145,601,846,763.00) ហើយចុះមកវិញបន្តិចរហូតដល់ឆ្នាំ2016 ($135,616,252, 594.00) និងកើនឡើងវិញរហូតដល់ឆ្នាំ 2018 ($155,446,548,683.00), ចុះវិញបន្តិចនៅឆ្នាំ 2019 ($150,958,791,008.00) ហើយក៏កើនមកវិញបន្តិចនៅឆ្នាំ 2020 ($161,271,294, 760.00)។ កំណើន GDP វិស័យបច្ចេកវិទ្យា នៃប្រទេសជប៉ុន មានការធ្លាក់ចុះជាលំដាប់ ចាប់ពីឆ្នាំ 2011 ($133,518 ,227,403.00) រហូតដល់ឆ្នាំ 2015 ($98,537,259,154.00) ហើយបានកើនឡើងបន្តិចវិញរហូតដល់ឆ្នាំ 2018 ($111,010, 395,630.00) និងចុះវិញបន្តបន្ទាប់រហូតដល់ឆ្នាំ 2020 ($102,966, 232, 360. 00)។ ខុសគ្នាពី កំណើន GDP វិស័យបច្ចេកវិទ្យា នៃប្រទេសវៀតណាម ដែលចាប់ពីឆ្នាំ 2011 ($11,706, 749,291.00) រហូតដល់ឆ្នាំ 2020 ($101,537,104,671.00) មានការកើនឡើងជាលំដាប់។ កំណើន GDP វិស័យបច្ចេកវិទ្យា នៃប្រទេសប្រទេស ចិន ចាប់ពីឆ្នាំ 2011 ($540,194,662,418.00) ដល់ឆ្នាំ 2015 ($652,237,382,663.00) មានការកើនឡើង បន្តិច ហើយធ្លាក់ចុះវិញនៅឆ្នាំ 2016 ($594,551, 851, 891.00) ហើយបានកើនឡើងរហូតដល់ឆ្នាំ 2018 ($731,890,595,214.00) និងធ្លាក់ចុះបន្តិចមកវិញនៅឆ្នាំ2019($715,843,469,845.00)ហើយក៏កើនឡើង បន្តិចមកវិញផងដែរនៅឆ្នាំ2020 ($757,723 ,684,192.00)។ ចំណែកឯ កំណើន GDP វិស័យបច្ចេកវិទ្យា នៃ ប្រទេសថៃឡង់ មានការកើនឡើងតាមលំដាប់ ចាប់ពីឆ្នាំ2011 ($36,167,465,191.00) ដល់ឆ្នាំ 2018 ($44,795,081,987.00) និងចុះវិញបន្តិចនៅឆ្នាំ2019 ($40,263,648,711.00) ហើយកើនឡើងវិញនៅ ឆ្នាំ2020($45,968,349,192.00)។ កំណើន GDP វិស័យបច្ចេកវិទ្យា នៃប្រទេសកូរ៉េ ចាប់ពីឆ្នាំ 2011 ($133,473,672,851.00) ដល់ឆ្នាំ 2012 ($130,689,572,360.00) បានធ្លាក់ចុះបន្តិចបន្តួច ហើយកើនឡើង វិញរហូតដល់ឆ្នាំ 2014 ($149,059,893,806.00) និងធ្លាក់ចុះបន្តិចវិញរហូតដល់ឆ្នាំ2016 ($135,914,291, 176.00) ហើយបន្ទាមកមានការកើនឡើងវិញរហូតដល់ 2018 ($192,789,656,676.00), ចុះវិញនៅឆ្នាំ 2019 ($153,561,173,548.00) និងកើនមកវិញនៅឆ្នាំ 2020 ($163,988,797,604.00)។

រូបភាពទី១.៥.២ការរួមចំណែកនៃវិស័យបច្ចេកវិទ្យា GDP នៃប្រទេសនីមួយៗ




យោងតាមការវិភាគ Pearson Correlation Coefficient លទ្ធផលបានបង្ហាញថា ចាប់តាំងពីឆ្នាំ 2011 ដល់ឆ្នាំ2020 កំណើន GDP វិស័យបច្ចេកវិទ្យាខ្ពស់នៃប្រទេសកម្ពុជា ($r = 0.771; p < 0.01$) ប្រទេសសិង្ហបុរី($r = 0.836; p < 0.01$) ប្រទេសវៀតណាម ($r = 0.995; p < 0.001$) ប្រទេសចិន ($r = 0.855; p < 0.01$) ប្រទេសថៃឡង់($r = 0.867; p < 0.001$) និងប្រទេសកូរ៉េ ($r = 0.705; p < 0.05$) មានការកើនឡើង ដែលផ្ទុយពីប្រទេសជប៉ុន ($r = -0.705; p < 0.05$) ដែលមានការធ្លាក់ចុះជាលំដាប់។ ចំណែកឯកំណើន GDP វិស័យបច្ចេកវិទ្យាខ្ពស់នៃប្រទេសអាល្លឺម៉ង់ ពុំមានការកើនឡើង ឬធ្លាក់ចុះនោះទេ($p > 0.05$) ។

# ជំពូកទី២៖

# ស្ថានភាពទូទៅ នៃគោលនយោបាយ

# អភិវឌ្ឍន៍ប្រទេសកម្ពុជា

# ជំពូកទី២

# ស្ថានភាពទូទៅ នៃគោលនយោបាយអភិវឌ្ឍន៍ប្រទេសកម្ពុជា

## ២.១ គោលនយោបាយអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល

បដិវត្តន៍ឧស្សាហ៍កម្មទី៤ មានឥទ្ធិពលយ៉ាងខ្លាំងសម្រាប់ប្រជាជនកម្ពុជា ក៏ដូចជាការប្រកួតប្រជែងសេដ្ឋកិច្ច និងពាណិជ្ជកម្មក្នុងក្របខណ្ឌជាតិ និងអន្តរជាតិ។ ប្រសិនបើមិនមានការត្រៀមខ្លួនឱ្យបានគ្រប់ជ្រុងជ្រោយជាមុន សម្រាប់ ទទួលយក និងក្តាប់យកកាលានុវត្តភាពនាំមកដោយបដិវត្តន៍ថ្មីនេះ កម្ពុជាអាចជួបនឹងការខាតបង់ប្រយោជន៍យ៉ាងច្រើន។ ទន្ទឹមនេះ ធនធានមនុស្ស កម្លាំងពលកម្ម គំនិតច្នៃប្រឌិតថ្មីៗ និងនវានុវត្តន៍ក្នុងការប្រើប្រាស់បច្ចេកវិទ្យាគឺជាកត្តាចម្បង ដែលកម្ពុជាកំពុងត្រូវការជាចាំបាច់នាពេលបច្ចុប្បន្ន។ ដោយសារកម្ពុជាជាប្រទេសដែលមានសក្តានុពលយុវជនខ្ពស់ ដូចនេះ យុវជនកម្ពុជា កំពុងក្លាយជាតួអង្គដ៏សំខាន់មួយនៅក្នុងសម័យបដិវត្តន៍ឧស្សាហកម្មទំនើបនេះ។ យ៉ាងណាក្តី ដើម្បីកម្ពុជាអាច ចាប់យក និងប្រើប្រាស់បដិវត្តន៍ឧស្សាហកម្មទី៤នេះបានដោយរលូន តម្រូវឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ក្នុងនោះ តួអង្គបីសំខាន់ៗ ដែលនឹងត្រូវលើកយកមកពិភាក្សាអំពីតួនាទី និងចំណែកចូលរួមមិនខ្វះរបស់ពួកគាត់ រួមមានប្រជាពលរដ្ឋ វិស័យឯកជន និងរាជរដ្ឋាភិបាល។ ខ្លឹមសារក្នុងអត្ថបទនេះ បង្ហាញពីធាតុចូលគន្លឹះដែលបានពីគ្រប់ភាគីពាក់ព័ន្ធនានារួម បញ្ចូលគ្នា ក្នុងន័យធ្វើយ៉ាងណាបង្កើតមានកិច្ចពិភាក្សាមួយអំពី "បដិវត្តន៍ឧស្សាហ៍កម្មទី៤ នៅកម្ពុជា"។

### ២.១.១ គោលនយោបាយរបស់ប្រទេសកម្ពុជា

គោលនយោបាយរបស់ប្រទេសកម្ពុជា៖ រាជរដ្ឋាភិបាលកម្ពុជា បានអនុវត្តផែនការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរយៈពេល៥ឆ្នាំចំនួន៣ SEDP ឆ្នាំ១៩៩៦-២០០០ និង២០០១-២០០៥ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ(២០០៦-២០១០) ជាមួយយុទ្ធសាស្ត្រកាត់បន្ថយ"ភាពក្រីក្រថ្នាក់ជាតិនិងគោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជា(CMDGs)។ គោលដៅអភិវឌ្ឍសំខាន់ៗ មិនត្រឹមរួមមានការកាត់បន្ថយភាពក្រីក្រយ៉ាងឆាប់រហ័ស តាមរយៈការសំរេចបាននូវ(CMDGs) និងការធ្វើសមាហរណកម្មកម្ពុជា ទៅក្នុងសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក (RGC,២០០៥) ក្នុងឆ្នាំ២០០៤ រាជរដ្ឋាភិបាលកម្ពុជា បានអនុម័ត"យុទ្ធសាស្ត្រចតុកោណ"ដែលមាន"អភិបាលកិច្ចល្អជាស្នូលរបស់ខ្លួនរួមជាមួយសមាសធាតុសំខាន់ៗ បួនគឺ: ១.សន្តិភាព សណ្តាប់ធ្នាប់នយោបាយនិងសង្គម ២.ការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងពិភពលោក ៣.ភាពជាដៃគូក្នុងការអភិវឌ្ឍ និង ៤.បរិស្ថានម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានអំណោយផល"។

### ២.១.២ ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា

ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជាគឺជំរុញកែប្រែនិងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជាឧស្សាហកម្មអតិពលកម្មឈានទៅឧស្សាហកម្មផ្អែកជំនាញត្រឹមឆ្នាំ២០២៥ តាមរយៈការតភ្ជាប់ទៅនឹងខ្សែ

ចង្វាក់តម្លៃសកលសមាហរណកម្មទៅក្នុងបណ្តាញផលិតកម្មតំបន់ និងការអភិវឌ្ឍផលិតកម្មប្រទាក់ក្រឡាទន្ទឹមនឹងការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាពឧស្សាហកម្មក្នុងស្រុក ហើយបន្តឈានទៅអភិវឌ្ឍឧស្សាហកម្មទំនើបដែលផ្អែកជាសំខាន់ ទៅលើមូលដ្ឋានបច្ចេកវិទ្យា និងចំណេះដឹង។ ការសម្រេចនូវចក្ខុវិស័យនេះ និងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ការទ្រទ្រង់ និងលើកម្ពស់កំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព ការបង្កើតការងារ ការបង្កើតតម្លៃបន្ថែមនៅក្នុងសេដ្ឋកិច្ច និងបង្កើនប្រាក់ចំណូល។ ដើម្បីសម្រេចបាននូវចក្ខុវិស័យខាងលើ"គោលនយោបាយអភិវឌ្ឍឧស្សាហកម្ម"រាជរដ្ឋាភិបាល កំណត់នូវគោលដៅចំនួនបី ទី១ បង្កើនចំណែកនៃ ផ.ស.ស ឱ្យបានដល់៣០ភាគរយ នៅឆ្នាំ២០២៥ (២៤,១ភាគរយនៃផ.ស.ស នៅក្នុងឆ្នាំ២០១៣) ដែលវិស័យកម្មន្តសាល ត្រូវកើនឡើងពី១៥,៥ភាគរយនៃផសស នៅឆ្នាំ២០១៣ដល់២០ភាគរយនៅឆ្នាំ២០២៥) ទី២ ជំរុញពិពិធកម្មមុខទំនិញដោយបង្កើតការនាំចេញទំនិញកម្មន្តសាល មិនមែនជាវាយនភណ្ឌឱ្យបាន១៥ភាគរយ នៃបរិមាណនាំចេញសរុបនៅក្នុងឆ្នាំ២០២៥ និងទី៣ កំណត់គោលដៅឆ្នាំ២០២៥ ឱ្យសហគ្រាសធុនតូច និងមធ្យមចំនួន ៨០ភាគរយ និងសហគ្រាសធុនមធ្យមចំនួន ៩៥ភាគរយ ត្រូវបានចុះបញ្ជីជាផ្លូវការ ហើយសហគ្រាសធុនតូចចំនួន ៥០ភាគរយ និងសហគ្រាសធុនមធ្យមចំនួន ៧០ភាគរយ មានបញ្ជីគណនេយ្យត្រឹមត្រូវ។

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយជាតិស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយឆ្នាំ២០១៦-២០២៦ ដើម្បីជំរុញការអភិវឌ្ឍខ្សែចង្វាក់ផលិតកម្មជាទំនិញ ឬសេវាកម្មនៅតាម ភូមិឋានឬសហគមន៍ទាំងការផលិតកែច្នៃ និងវេចខ្ចប់។ ដោយបានដាក់ចេញនូវយុទ្ធសាស្ត្រការអភិវឌ្ឍក្របខ័ណ្ឌ ច្បាប់ និងយន្តការកសាងផែនទីផលិតផល ភូមិមួយ ផលិតផលមួយ ជំរុញការអភិឌ្ឍស្ថាប័ន និងធនធានមនុស្សផ្លាស់ប្តូរផ្នត់គំនិតឱ្យកាន់តែល្អប្រសើរឡើង លើកកម្ពស់ការយល់ដឹង និងបទពិសោធន៍នានា និងគ្រប់ផ្នែកពាក់ព័ន្ធអភិវឌ្ឍសមត្ថភាពស្រាវជ្រាវ និងអភិវឌ្ឍផលិតផល ការអភិវឌ្ឍសមត្ថភាពក្នុងការផលិតនូវផលិតផលកសិកម្ម ឧស្សាហកម្ម និងសិប្បកម្ម និងសេវាកម្ម លើកកម្ពស់គុណភាពផលិតផលតាមស្តង់ដារភូមិមួយផលិតផលមួយ ការស្វែងរកប្រភពហិរញ្ញប្បទាន ឬឥណទាន លើកកម្ពស់ការអភិវឌ្ឍទីផ្សារ និងការគ្រប់គ្រងអាជីវកម្ម បង្កើតចងក្រងពង្រឹងនិងពង្រីកសមាគម សហគមន៍ជំរុញចលនាភូមិមួយ ផលិតផលមួយ លើកកម្ពស់ការចូលរួមរបស់យុវជនស្ត្រី និងជំរុញការអភិវឌ្ឍប្រកបដោយចីរភាពដោយបានដាក់ចេញផែនការសកម្មភាពដើម្បីសម្រេចយុទ្ធសាស្ត្រត្រូវយកចិត្តទុកដាក់ទៅលើសកម្មភាពមួយចំនួន ដូចជាការបង្កើតយន្តការ ការបង្កើតក្របខ័ណ្ឌគតិយុត្ត ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបណ្តុះបណ្តាលធនធានមនុស្ស។

ដើម្បីចូលរួមចំណែកក្នុងការអនុវត្តប្រកបដោយភាពជោគជ័យនូវរបៀបវារៈគោលនយោបាយយុទ្ធសាស្ត្រ និងឆ្លើយតបទៅនឹងបញ្ហាប្រឈម រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយជាតិស្តីពីមុខរបរ

និងការងារឆ្នាំ២០១៥-២០២៥ សំដៅបង្កើតឱកាសការងារ និងលើកកម្ពស់ផលិតភាពការងារ ជំរុញការអភិវឌ្ឍជំនាញធនធានមនុស្ស និងពង្រឹងអភិបាលកិច្ចទីផ្សារការងារ។ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយស្តីអំពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ គោលដៅចម្បងនៃគោលនយោបាយនេះ គឺសំដៅជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ គឺជាជំហ៊ានដំបូងដ៏សំខាន់សម្រាប់ការជំរុញផលិតកម្ម និងការនាំចេញផលិតផល។

## ២.២យុទ្ធសាស្ត្រជាតិឆ្នាំ២០០៦-២០១០

នៅក្នុងផែនការយុទ្ធសាស្ត្រ ដើម្បីជំរុញល្បឿនដល់សហគ្រាសធុនតូច និងមធ្យម និងអនុវត្តនូវវិធានការណ៍មួយចំនួន ដូចជា ដើម្បីឱ្យសហគ្រាសធុនតូច និងមធ្យម មីក្រូសហគ្រាសដំណើរការក្នុងបរិយាសធុរកិច្ចមួយមានផលចំណេញ និងបង្កើនលទ្ធភាពទទួលបានហិរញ្ញវត្ថុរយៈពេលវែង និងមធ្យមកាត់បន្ថយនីតិវិធីនៃការចុះបញ្ជីក្រុមហ៊ុននៃការចាប់ផ្តើមសហគ្រាសធុនតូច និងមធ្យម បង្កើតស្ថាប័នស្តង់ដារជាតិ ស្ថាប័នផលិតភាពដើម្បីជួយធានាគុណភាពនៃផលិតផលក្នុងស្រុក និងបង្កើន ផលិតភាព ជំរុញការគាំទ្រប្រឹក្សាយោបល់ដល់សហគ្រាសធុនតូច និងមធ្យម ដើម្បីជួយអភិវឌ្ឍបច្ចេកវិទ្យាទំនើប កែលម្អគុណភាពផលិតផល ការគ្រប់គ្រង និងការស្វែងរកទីផ្សារ និងជំរុញការបណ្តុះបណ្តាលវិជ្ជា ជីវៈនិងពង្រឹងក្របខ័ណ្ឌច្បាប់។ ការលើកស្ទួយសហគ្រាសធុនតូច និងមធ្យមក្នុងដំណើរការកែច្នៃព្រមទាំងបង្កើតកាងារ បង្កើននូវទំនាក់ទំនងល្អជាមួយវិស័យពាណិជ្ជកម្ម កាងារដែលគ្រោងទុក និងផ្តោតទៅលើទិដ្ឋភាពសំខាន់បីមានដូចជាៈ (១).ក្របខ័ណ្ឌច្បាប់ និងកែសម្រួលឱ្យប្រសើរឡើងនូវការកំណត់នីតិវិធី អធិការកិច្ច និងការបង្ហាញភស្តុតាង ផលិតផលសម្រាប់ការនាំចូល និងនាំចេញ សម្រួលការធ្វើអាជីវកម្មតាមរយៈការគ្រប់គ្រងហានិភ័យការបើកទូលាយនូវការចុះបញ្ជីពាណិជ្ជកម្មតាមអ៊ិនធឺណេត ឬប្រព័ន្ធព័ត៌ មានវិទ្យា។ (២).ការផ្តល់នូវហិរញ្ញប្បទាន ការបង្កើតក្រុមហ៊ុនធ្វើភតិសន្យា ការចំណាត់ថ្នាក់ក្រុមហ៊ុន និងការពង្រឹងអភិបាលកិច្ច និងរបាយការណ៍ហិរញ្ញវត្ថុ។ (៣).សកម្មភាពគាំទ្រសហគ្រាសធុនតូច និងមធ្យម ពោលគឺបង្កើតសេវាអភិវឌ្ឍពាណិជ្ជកម្ម ព្រមទាំងធ្វើការឧបត្ថម្ភទុនសម្រាប់សហគ្រាសធុនតូច និងមធ្យមនូវការនាំចេញ និងការបញ្ចូលច្រវ៉ាក់តម្លៃសកល។

នៅក្នុងយុទ្ធសាស្ត្រសម្រាប់នីតិកាលទី៥ នៃរដ្ឋសភា នៅក្នុងវិស័យសហគ្រាសធុនតូច និងមធ្យម (SMEs) គោលដៅ និងចក្ខុវិស័យជំរុញឧស្សាហូបនីយកម្មកម្ពុជា តាមរយៈការបង្កើតតម្លៃបន្ថែមដល់សេដ្ឋកិច្ចនៅក្នុងវិស័យឧស្សាហកម្ម បង្កើតការងារ និងភាពសម្បូបែបនៃផលិតផលប្រកបដោយគុណភាព។ នៅក្នុង "យុទ្ធសាស្ត្រចតុកោណ" ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា នៅត្រង់ចំណុច ចតុកោណទី ៣. ការអភិវឌ្ឍវិស័យឯកជន និងការងារ មុំទី១. ការពង្រឹងវិស័យឯកជន និងការជំរុញការវិនិយោគ និងធុរកិច្ច មុំទី ២. ការអភិវឌ្ឍឧស្សាហកម្ម និងសហគ្រាសធុនតូច និងមធ្យម មុំទី ៣. ការអភិវឌ្ឍទីផ្សារ និងការងារ

មុំទី ៤. ការអភិវឌ្ឍវិស័យធនាគារ និងហិរញ្ញវត្ថុ។ នៅក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា ការអភិវឌ្ឍសេដ្ឋកិច្ច រាជរដ្ឋាភិបាល មានវិធានការ និងគោលនយោបាយសំខាន់ៗដូចជា ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ភាពជាដៃគូក្នុងការអភិវឌ្ឍវិស័យកសិកម្ម ដីធ្លី និងសំណង់ ឧស្សាហកម្ម សិប្បកម្ម ហេដ្ឋារចនា សម្ព័ន្ធរូបវន្ត ដូចជា ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ធនធានទឹក ទឹកស្អាត ថាមពល បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ពាណិជ្ជកម្ម ការអភិវឌ្ឍវិស័យឯកជន និងការទាក់ទាញការវិនិយោគ។

នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា នៅក្នុងចតុកោណទី២ ការធ្វើពិពិធកម្មសេដ្ឋកិច្ច។ ការធ្វើពិពិធកម្មសេដ្ឋកិច្ច ផ្តោតលើអាទិភាពចំនួន៤ ដែលមានភាពប្រទាក់ក្រឡាគ្នាយ៉ាងជិតស្និត និងបំពេញឱ្យគ្នាទៅវិញទៅមកគឺ (១) ការកែលម្អប្រពន្ធ័ឡូជីស្ទិក ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល (២) ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ច គន្លឹះ និងថ្មីៗ (៣) ការរៀបចំខ្លួន សម្រាប់សេដ្ឋកិច្ចឌីជីថល និងឆ្លើយតបទៅនិងបដិវត្តន៍ឧស្សាហកម្មទី៤ (៤) ការជំរុញការអភិឌ្ឍវិស័យហិរញ្ញវត្ថុ និងធនាគារ។

មុំទី១ ការកែលម្អប្រព័ន្ធឡូជីស្ទីក ការលើកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល

រាជរដ្ឋាភិបាលក្នុងនីតិកាលទី៦ ផ្តោតអាទិភាពលើទី ១-អនុមតិ និងអនុវត្តផែនការមេ សម្រាប់វិស័យដឹកជញ្ជូន ពហុមធ្យោបាយ និងឡូជីស្ទិក ដើម្បីបង្កើនល្បឿនសមាហរណកម្មការតភ្ជាប់ប៉ូលសេដ្ឋកិច្ចសំខាន់ៗ និងអភិវឌ្ឍរបៀងសេដ្ឋកិច្ចគន្លឹះ ឱ្យកាន់តែមានលក្ខណៈប្រកួតប្រជែងខ្ពស់ នៅក្នុងតំបន់ និងពិភពលោក។

ទី២-ការបន្តបង្កើនថវិការវិនិយោគ និងគៀងគរហិរញ្ញប្បទាន ដើម្បីស្តារកសាងនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ រូបវន្ត ទាំងផ្លូវគោក ស្ពាន ផ្លូវដែក ផ្លូវទឹក និងផ្លូវអាកាសព្រមទាំងផ្លូវល្បឿនលឿន សំដៅឆ្លើយតបឱ្យបានទាំងបរិមាណនិងគុណភាពសុវត្ថិភាព និងភាពធន់មាំទៅនឹងតម្រូវការនៃការអភិវឌ្ឍប្រទេសដែលកិច្ចការនេះត្រូវដើរទន្ទឹមគ្នាជាមួយនឹងការពង្រឹងការសម្របសម្រួលយន្តការស្ថាប័នឱ្យកាន់តែប្រសើរឡើង។

ទី៣- ការបន្តបញ្ចុះថ្លៃអគ្គីសនី ពង្រីកបណ្តាញគ្របដណ្តប់ និងបង្កើនស្ថិរភាពអគ្គីសនីដោយសាងសង់អនុស្ថានីយ៍ បន្ថែមឱ្យដល់តំបន់ប៉ូលសេដ្ឋកិច្ច និងតំបន់សក្តានុពលសេដ្ឋកិច្ចខ្ពស់។

ទី៤- ការបន្តការអភិវឌ្ឍការតភ្ជាប់ផ្នែកឌីជីថល តាមរយៈការពង្រឹង និងពង្រីកហេដ្ឋារនាសម្ព័ន្ធខ្សែកាប្លិ៍អុបទិកជាបណ្តាញចែកចាយ។ ហេដ្ឋារនាសម្ព័ន្ធខ្សែកាប្លិ៍អុបទិកឆ្អឹងខ្នង និងខ្សែកាប្លិ៍អុបទិកក្រោមបាត សមុទ្រព្រមទាំងហេដ្ឋារចនាសម្ពន្ធ័ទូរស័ព្ទចល័ត ប្រកបដោយគុណភាព មានលក្ខណៈទំនើបទាន់សម័យ មានថ្លៃប្រកួតប្រជែង និងមានសេវាគ្របដណ្តប់ទូរទាំងប្រទេស។

ទី៥- ការពង្រឹងសមត្ថភាពស្ថាប័ន ក្នុងការធ្វើផែនការ ការរៀបចំថវិការ ការអនុវត្តន៍ និងការត្រួត ពិនិត្យវាយតម្លៃគម្រោង។

មុំទី- ២ ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ច គន្លឹះ និងថ្មីៗ

រាជរដ្ឋាភិបាល ក្នុងនីតិកាលទី៦ ផ្តោតអាទិភាពលើទី១ ការបន្តជំរុញការអនុវត្តន៍ គោលនយោបាយអភិវឌ្ឍឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥ -២០២៥ ។ ទី២ រៀបចំ និងអនុវត្តយុទ្ធសាស្រ្តការអភិវឌ្ឍវិស័យកាត់ដេរ និងផលិតស្បែកជើង ដើម្បីបង្កើនភាពប្រកួតប្រជែង បង្កើតតម្លៃបន្ថែម បង្កើតឧស្សាហកម្មគាំទ្រ និងអភិវឌ្ឍខ្សែច្រវ៉ាក់តម្លៃ។ ទី៣ ការបន្តជំរុញកិច្ចដំណើរការ និងទាក់ទាញការវិនិយោគ នៅតាមតំបន់សេដ្ឋកិច្ចពិសេស ដើម្បីកសាងមូលដ្ឋានឧស្សាហកម្ម រួមទាំងការកែច្នៃកសិផល ការផ្គុំ និងការដំឡើង ការផលិតគ្រឿងសង្ហារឹម សម្ភារប្រើប្រាស់ក្នុងលំនៅឋាន ការផលិតវត្ថុអនុស្សាវរីយ៍បម្រើឱ្យវិស័យទេសចរណ៍ជាដើម។ ទី៤ ការរៀបចំផែនការមេអភិវឌ្ឍវិស័យទេសចរណ៍ ដោយផ្តោតលើការធ្វើពិពិធកម្មផលិតផល និងគោលដៅទេសចរណ៍ ការទាក់ទាញភ្ញៀវចំណាយខ្ពស់ និងកាលើកទឹកចិត្តឧស្សាហកម្មគាំទ្រវិស័យទេសចរណ៍។

មុំទី៣-ការរៀបចំខ្លួន សម្រាប់សេដ្ឋកិច្ចឌីជីថល និងឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤.០។ បដិវត្តន៍ឧស្សាហកម្ម បានធ្វើឱ្យមានការផ្លាស់ប្តូរយ៉ាងខ្លាំង នូវស្ថានភាពសង្គម សេដ្ឋកិច្ចសកល ដោយសារនវានុវត្តន៍បច្ចេកវិទ្យា ហើយកំពុងស្ថិតក្នុងដំណាក់កាលផ្លាស់ប្តូរថ្មីមួយទៀត គឺបដិវត្តន៍ឧស្សាហកម្មទី៤.០។

### ២.២.១ រាជរដ្ឋាភិបាលក្នុងនីតិកាលទី៦

រាជរដ្ឋាភិបាលក្នុងនីតិកាលទី៦ ផ្តោតអាទិភាពលើទី១- ការរៀបចំ និងអនុវត្តន៍ក្របខណ្ឌយុទ្ធសាស្រ្តសេដ្ឋកិច្ចឌីជីថល រយៈពេលវែង និងដាក់វិស័យឌីជីថល ជាអនុវិស័យនៅក្នុងប្រពន្ធគណនេយ្យជាតិ។ ទី២- ការបន្តធ្វើបច្ចុប្បន្នភាព និងអនុវត្តន៍គោលនយោបាយអភិវឌ្ឍវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងពត៌មាន ផែនការមេ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។ ទី៣-ការបន្តពង្រឹង និងពង្រីកការអភិវឌ្ឍហេដ្ឋារចនាសម្ពន្ធ័គាំទ្រចាំបាច់ រួមមានហេដ្ឋារចនាសម្ពន្ធ័បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។ ហេដ្ឋារចនាសម្ព័ន្ធប្រៃសណីយ៍ និងដឹកជញ្ជូនបញ្ញើរហ័សក្នុងស្រុក ព្រមទាំងឡជីស្ទីក ហេដ្ឋារចនាសម្ព័ន្ធ ទូរទាត់ការសងប្រាក់ អេឡិចត្រូចនិច។ ទី៤-ការជំរុញ និងការបង្កើតមូលដ្ឋានគតិយុត្តគាំទ្រដល់ការអភិវឌ្ឍ វិស័យឌីជីថល និងសន្តិសុខព័ត៌មាន ច្បាប់ស្តីពីពាណិជ្ជកម្មតាមអេឡិចត្រូនិច ច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន។ ទី៥-ការអភិវឌ្ឍជំនាញ និងការអប់រំ ការបណ្តុះបណ្តាល ដោយផ្តោតលើការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ឱ្យបានទូលាយ និងបញ្ចូលការប្រើប្រាស់ និងការយល់ដឹងអំពីបច្ចេកវិទ្យាឌីជីថលទៅក្នុងកម្មវិធីសិក្សា ស្របតាមតម្រូវការទីផ្សារការងារ រួមទាំងការបង្កើតយន្តការភាពជាដៃគូរវាងធុរកិច្ច និងគ្រឹះស្ថានអប់រំ និងគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបង្កើតកម្មវិធីអភិវឌ្ឍន៍ និងបណ្តុះបណ្តាលជំនាញឌីជីថលថ្មីៗ។ ទី៦- ការអភិវឌ្ឍសហគ្រិនភាព និងប្រពន្ធ័

អេកូឡូស៊ីឌីជីថល ដែលជាបរិស្ថានអំណោយផល ដល់ការបង្កើតធុរកិច្ចថ្មីៗ ការជំរុញការប្រើប្រាស់ប្រពន្ធ័ឌីជីថលក្នុងធុរកិច្ច និងបង្កើតយន្តការសហប្រតិបត្តិការសហគ្រិន ភាព ក្នុងក្របខណ្ឌរាជរដ្ឋាភិបាល ឬ ភាពជាដៃគូរជាមួយវិស័យឯកជន។

ក្នុងក្របខ័ណ្ឌជាតិ ការវិនិយោគលើវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលមានយុទ្ធសាស្ត្រ និងគោលនយោបាយត្រឹមត្រូវ ក៏នឹងជួយឱ្យសម្រេចបាននូវយុទ្ធសាស្ត្រអភិវឌ្ឍនានារបស់រដ្ឋាភិបាល ឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០សំដៅធ្វើឱ្យកម្ពុជាបានក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០ និងក្នុងក្របខណ្ឌ័អន្តរជាតិ គឺការសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាព។ គោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្របច្ចេកវិទ្យានវានុវត្តន៍ឆ្នាំ២០២០-២០២៣ ដែលមានចក្ខុវិស័យប្រទេសកម្ពុជាមានសក្តានុពលភាពផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាកម្លាំងជវភាពនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចប្រកបដោយបរិយាបន្ន និងចីរភាព ធ្វើឱ្យសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។គោលនយោបាយនេះមានគោលបំណងពង្រឹងមូលដ្ឋានគ្រឹះ និងកែលម្អបរិយាកាសនៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីអភិវឌ្ឍប្រកបដោយចីរភាព និងលើកកម្ពស់គុណភាពជីវិតកាន់តែប្រសើរនិងអភិវឌ្ឍប្រពន្ធ័អេកូនវានុវត្តន៍នៅគ្រប់កម្រិតនិងគ្រប់វិស័យ។ ផែនទីបង្ហាញផ្លូវវិទ្យាស្រ្តា បច្ចេកវិទ្យា និងនវានុវត្តន៍២០៣០ បានដាក់ចេញនូវសសរស្តម្ភចំនួន៥ ដូចខាងក្រោម៖ សសរស្តម្ភ១ អភិបាលកិច្ច ក្រសួងមានតួនាទីសំខាន់ក្នុងការដឹកនាំ និងសម្របសម្រួលគោលនយោបាយ វ ប ន។ ក ជ វ ប ន មានតួចនាទីកំណត់ទិសដៅគោលនយោបាយជាតិស្តីពី វ ប ន។ ការវិនិយោគរួមគ្នារវាងស្ថាប័នសាធារណៈ និងឯកជនទៅលើវិស័យ វ ប ន ត្រូវមានចំនួន ១ ភាគរយ នៃ ផ.ស.ស ត្រឹមឆ្នាំ២០៣០។ ហិរញ្ញប្បទានសាធារណៈសម្រាប់សកម្មភាពស្រាវជ្រាវ និងនវានុវត្តន៍ផ្តោតសំខាន់ទៅលើការឈានសម្រេចបានសមិទ្ធផលនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។

សសរស្តម្ភ២ ការអប់រំ បង្កើនសមាមាត្រនៃចំនួននិស្សិតបញ្ចប់ការសិក្សាក្នុងជំនាញស្ទែម យ៉ាងហោចណាស់ ៥០ភាគរយ ត្រឹមឆ្នាំ២០៣០។ កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត នឹងត្រូវរៀបចំឡើងដោយមានការសហការជាមួយវិស័យឯកជន នៅមុនឆ្នាំ២០២៤។ វេទិការបច្ចេកវិទ្យា នឹងត្រូវបង្កើតឡើង នៅតាមសាកលវិទ្យាល័យ និងគ្រឹះស្ថាន(TVET) ពីវេត។ សារមន្ទីរវិទ្យាសាស្ត្រចំនួន២ នៅ ទូទាំងប្រទេសត្រឹមឆ្នាំ២០៣០ ក្នុងនោះមួយនៅភ្នំពេញ ត្រឹមឆ្នាំ២០២៣។ ព្រឹត្តិការណ៍នវានុវត្តន៍ចំនួន ២០ ឬ វេទិការនវានុវត្តន៍ចំនួន២០ត្រឹមឆ្នាំ២០៣០។ បណ្ណាល័យវិទ្យាសាស្ត្រចំនួន៣ នឹងបើកឱ្យដំណើរការនៅក្នុងប្រទេសនៅត្រឹមឆ្នាំ២០៣០ ក្នុងនោះ ១ នៅភ្នំពេញត្រឹមឆ្នាំ២០២៣។

សសរស្តម្ភ៣ ការស្រាវជ្រាវ មានដូចជា អនុម័តរបៀបវារៈស្រាវជ្រាវជាតិរយៈពេល៥ឆ្នាំដោយកំណត់ទិសដៅនៅក្នុងដែនស្រាវជ្រាវ។ បង្កើតមូលនិធិស្រាវជ្រាវជាតិឱ្យបាន ត្រឹមឆ្នាំ២០២៣។ បង្កើនការចំណាយទៅ

លើការស្រាវជ្រាវ និងអភិវឌ្ឍន៍ដល់១ភាគរយ ត្រឹមឆ្នាំ២០២៣។ បង្កើនចំនួនអ្នកស្រាវជ្រាវក្នុងវិស័យសាធារណៈដល់ ៧០០ក្នុង១លាននាក់ត្រឹមឆ្នាំ២០៣០។ បង្កើនអត្ថបទបោះផ្សាយនៅក្នុង ទស្សនាវដ្ដីអន្តរជាតិ១៥០០ ដោយអ្នកវិទ្យាសាស្ត្រខ្មែរ ត្រឹមឆ្នាំ២០៣០។ សាកលវិទ្យាល័យស្រាវជ្រាវមជ្ឈមណ្ឌលស្រាវជ្រាវឆ្នើមចំនួន៧ នឹងត្រូវរៀបចំឡើង ត្រឹមឆ្នាំ២០២៥។

សសរស្តម្ភ៤ កិច្ចសហការ សាកលវិទ្យាល័យចំនួន៥ បង្កើតការិយាល័យភ្ជាប់ទំនាក់ទំនងសាកលវិទ្យាល័យ និងសហគ្រាសត្រឹមឆ្នាំ២០២៣ និង៥០ភាគរយ នៃសាកលវិទ្យាល័យទូទាំងប្រទេស ត្រឹមឆ្នាំ២០៣០។ កម្មសិក្សាចុះតាមរោងចក្រសហគ្រាសត្រូវបានបញ្ចូលនៅក្នុងកម្មវិធីសិក្សាត្រឹមឆ្នាំ២០៣០។ គោលនយោបាយសួន ឬបណ្ដុំ វ.ប.ន ត្រូវបានអនុម័តត្រឹមឆ្នាំ២០២២ ដែល ៣ នឹងដាក់ឱ្យសាកល្បងត្រឹមឆ្នាំ២០២៣ និងដំណើរការពេញលេញ ត្រឹមឆ្នាំ២០២៥។

### ២.២.២.ចំណូល-ចំណាយរបស់រដ្ឋាភិបាល

ការចំណាយរបស់រដ្ឋាភិបាល អាចបង្កើនកំណើនសេដ្ឋកិច្ច តាមរយៈគោលនយោបាយសារពើពន្ធជាមួយនឹងការបែងចែកចំណាយរបស់រដ្ឋាភិបាល ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធដែលប្រជាជនត្រូវការក៏ដូចជាគោលនយោបាយក្នុងការអភិវឌ្ឍ។ Moudud(១៩៩៩)បានបញ្ជាក់ថាការចំណាយរបស់រដ្ឋាភិបាលអាចត្រូវបានបែងចែកទៅជាការចំណាយលើការប្រើប្រាស់(ការចំណាយលើទំនិញ និងសេវាកម្ម)និងការចំណាយលើការវិនិយោគសាធារណៈដូចជាការចំណាយលើហេដ្ឋារចនាសម្ព័ន្ធការអប់រំសុខភាពសាធារណៈ និងការអភិវឌ្ឍការស្រាវជ្រាវព្រមទាំង ការចំណាយមួយចំនួនទៀត ដែលជំរុញកំណើនសេដ្ឋកិច្ច។ ការសិក្សាជាក់ស្តែងមួយចំនួនបានរកឃើញថា ការកើនឡើងនៃការវិនិយោគសាធារណៈពិតជាបានកាត់បន្ថយការចំណាយធុរៈកិច្ច និងបង្កើនផលចំណេញសេដ្ឋកិច្ច រយៈពេលវែងបានយ៉ាងច្រើន។

កត្តានៃការចំណាយរបស់រដ្ឋាភិបាលគឺមានសារៈសំខាន់ ក្នុងការធ្វើឱ្យមានកំណើន ផ.ស.ស សម្រាប់មនុស្សម្នាក់។ ការចំណាយរបស់រដ្ឋាភិបាលចំនួន១ភាគរយនឹងជួយបង្កើនកំណើនបង្កើនកំណើនផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់0.0៧ភាគរយ។ ការចំណាយរបស់រដ្ឋាភិបាលនឹងបង្កើនកំណើនសេដ្ឋកិច្ចផងដែរ។ Enache(២០០៩) បានរកឃើញថាគោលនយោបាយសារពើពន្ធអាចជួយបង្កើនកំណើនផលិតផលក្នុងស្រុកសរុប ដែលធ្វើឱ្យរដ្ឋាភិបាលមានលទ្ធភាពបង្កើនការចំណាយទៅលើ វិស័យផលិតភាព។

ក្របខ័ណ្ឌថវិកាឆ្នាំ២០១៨ ឈរលើគោលការណ៍ខាងលើ ក៏ដូចជា ក្នុងក្របខ័ណ្ឌនៃកំណើនសេដ្ឋកិច្ចដែលត្រូវបានគ្រោងក្នុងរង្វង់ ៧,០ភាគរយ ព្រមជាមួយនឹងសេណារីយ៉ូចំណូលដែលមានលក្ខណៈសុទិដ្ឋិនិយម និងដោយឈរលើមូលដ្ឋាននៃលទ្ធផលល្អប្រសើរ ក្នុងការអនុវត្តចំណូល ជាពិសេសចំណូលគយ និងចំណូលពន្ធដារឆ្នាំ២០១៦និងឆ្នាំ២០១៧ដែលក្របខ័ណ្ឌថវិកាឆ្នាំ២០១៨ត្រូវបានរៀបចំឡើងក្រោមការកំណត់ដូចតទៅ៖

ចំណូលក្នុងប្រទេស ថវិការដ្ឋ ឬថវិកាជាតិ ត្រូវបានគ្រោងចំនួន១៨ ៥៨៧ ០០៣លានរៀល ស្មើនឹង ១៨,៧៥ភាគរយនៃ ផ.ស.ស និងមានកំណើន១១,៩ភាគរយ ធៀបនឹងច្បាប់ឆ្នាំ២០១៧ ចំណែកឯ ចំណាយសរុបថវិការដ្ឋ ឬថវិកាជាតិ ត្រូវបានគ្រោងចំនួន២៤ ៣៧៥ ១០២លានរៀល ស្មើនឹង ២៤,៥៩ភាគរយនៃ ផសស និងមានកំណើន១៥,២ភាគរយ ធៀបនឹងច្បាប់ឆ្នាំ២០១៧។ ជាលទ្ធផល អតិរេកថវិកាចរន្ត អាចរក្សាបានក្នុងកម្រិតប្រមាណ២,៨៨ភាគរយនៃ ផ.ស.ស នៅឆ្នាំ២០១៨ និងមានឱនភាពថវិកាសរុបស្មើនឹង ៥,៨៤ភាគរយនៃ ផ.ស.ស ស្របតាមគោលនយោបាយថវិកាប្រយ័ត្នប្រយែងរបស់រាជរដ្ឋាភិបាល។

ក្នុងក្របខ័ណ្ឌនៃគោលដៅខាងលើ រាជរដ្ឋាភិបាលបានបង្កើនចំណូលសរុបថវិការដ្ឋ ឬចំណូលសរុបថវិកាជាតិឱ្យស្មើនឹង ២៣ ៣៨៣ ៩៤២ លានរៀល ក្នុងនោះចំណូលចរន្តថ្នាក់ជាតិឱ្យស្មើនឹង ១៧ ៤៦០ ០០៦ លានរៀល (ដែលរួមមានចំណូលសារពើពន្ធ ១៥ ០៧៥ ៥៦២ លានរៀល និងចំណូលមិនមែនសារពើពន្ធ ២ ៣៨៤ ៤៤៤លានរៀល)។ ដោយឡែក សម្រាប់ចំណូលមូលធនថវិការដ្ឋ ត្រូវបានគ្រោងចំនួន ៤ ៩៧៧ ១៣២ លានរៀល ត្រូវជា ៥.0ភាគរយ នៃ ផ.ស.ស គឺមានកំណើន ៦,៣ភាគរយ ធៀបនឹងច្បាប់ឆ្នាំ២០១៧។

ទន្ទឹមនេះ រាជរដ្ឋាភិបាលបានសម្រេចលុបកម្រៃគ្រប់គ្រងការនាំចេញ(Export Management Fee) ដែលមានថវិកាចំនួនប្រមាណ ៨២៥៤២ លានរៀល សមមូលនឹងប្រមាណជាង ២០លានដុល្លារអាមេរិកក្នុងគោលបំណង៖ (ទី១)-បង្កើនការទាក់ទាញនូវការវិនិយោគថ្មីបន្ថែមទៀតនៅកម្ពុជា ដើម្បីរួមចំណែកបន្តលើកស្ទួយកំណើនសេដ្ឋកិច្ច និងបង្កើតការងារកាន់តែច្រើនជូនពលករកម្ពុជា និង (ទី២)-ដើម្បីជួយសម្រួលដល់ម្ចាស់រោងចក្រ/សហគ្រាស ឱ្យមានលទ្ធភាពគ្រប់គ្រាន់ក្នុងការដំឡើងប្រាក់ឈ្នួលអប្បបរមា (ផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង)ឱ្យបានដល់ ១៧០ដុល្លារអាមេរិក នៅឆ្នាំ២០១៨ ជូនកម្មករនិយោជិតម្នាក់ៗ។

សម្រាប់ឆ្នាំ២០១៨ ចំណាយសរុបថវិការដ្ឋ ឬចំណាយសរុបថវិកាជាតិ ត្រូវបានគ្រោងចំនួន២៤ ៣៧៥ ១០២ លានរៀល ត្រូវជា ២៤,៥៩ភាគរយ នៃ ផ.ស.ស គឺមានកំណើន ១៥,២ភាគរយ ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧។ ដែលក្នុងនោះ (១)-ចំណាយចរន្តថវិការដ្ឋមានចំនួន១៥ ៩៤៥ ៤១៨ លានរៀល ត្រូវជា១៦,០៩ភាគរយ នៃផ.ស.ស គឺមានកំណើន ១៥,៦ភាគរយ ធៀបនឹងច្បាប់ឆ្នាំ២០១៧ និង(២)-ចំណាយមូលធនថវិការដ្ឋមានចំនួន ៨៤២៩ ៦៨៤លានរៀល ត្រូវជា ៨,៥ភាគរយ នៃផ.ស.ស គឺមានកំណើន ១៤,៦ភាគរយ ធៀបនឹងច្បាប់ឆ្នាំ២០១៨។

ថវិកាឆ្នាំ២០១៨ មានទិសដៅជាយុទ្ធសាស្ត្រកំណត់ចំណាយថវិកាថ្នាក់ជាតិ ឱ្យស្ថិតក្នុងកម្រិតចំនួន ២៣ ៤២៨ លានរៀល ត្រូវជា ២៣,៦៤ភាគរយនៃផ.ស.ស គឺមានកំណើន១៦,១ភាគរយ ធៀបនឹងច្បាប់ឆ្នាំ ២០១៧ ដែលក្នុងនោះចំណាយចរន្តថ្នាក់ជាតិ មានចំនួន១៥ ២១៨ ១៦៦លានរៀល និងចំណាយមូលធនថ្នាក់ជាតិ មានចំនួន ៨ ២១០ ១៣២លានរៀល។

ច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ត្រូវបានរៀបចំឡើងក្នុងបរិការណ៍ ដែលរាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា។ ថវិការឆ្នាំ២០១៩ ត្រូវបានរៀបចំឡើងដោយឈរលើគោលការណ៍គ្រឹះជាយុទ្ធសាស្ត្រសំខាន់ចំនួន៤ ដែលក្នុងនោះ រួមមាន (១)ធានាឱ្យបានកំណើនសេដ្ឋកិច្ច ក្នុងអត្រាមធ្យមប្រចាំឆ្នាំក្នុងរង្វង់ ៧ភាគរយ ប្រកបដោយចីរភាព និងធន់នឹងវិបត្តិ តាមរយៈការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចថ្មីៗ ដោយទូលំទូលាយ និងមានភាពប្រកួតប្រជែង ជាមួយនឹងការថែរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការគ្រប់គ្រងអត្រាអតិផរណានៅទាប ការធាស្ថិរភាពអត្រាប្តូរប្រាក់ ការខិតខំបង្កើនទុនបម្រុងជាប្រចាំ និងការគ្រប់គ្រងបំណុលសាធារណៈដោយគត់ម៉ត់ (២)បង្កើតការងារឱ្យបានកាន់តែច្រើន ទាំងបរិមាណ និងគុណភាពជូនដល់ប្រជាជនកម្ពុជា ជាពិសេសសម្រាប់ស្រទាប់យុវជន តាមរយៈការផ្តល់ព័ត៌មានទីផ្សារការងារ ការកែលម្អលក្ខខណ្ឌការងារ ការលើកម្ពស់សកម្មភាពធុរកិច្ច និងការជំរុញការវិនិយោគទាំងក្នុងប្រទេស និងក្រៅប្រទេស (៣)សម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ ឱ្យស្ថិតនៅក្នុងអត្រាទាបជាង១០ភាគរយ (៤) បន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ចនៃស្ថាបន័រដ្ឋទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យបាននូវប្រសិទ្ធិភាព និងស័ក្តសិទ្ធិភាពនៃសេវាសាធារណៈសំដៅបំរើប្រជាជនឱ្យបានកាន់តែប្រសើរឡើងក៏ដូចជាការលើកកម្ពស់បរិយាកាសធុរកិច្ចនិងបរិយាកាសអំណោយផលសម្រាប់ការ វិនិយោគ។

ក្នុងក្របខណ្ឌនៃកំណើនសេដ្ឋកិច្ច ដែលត្រូវបានគ្រោងក្នុងរង្វង់៧១ភាគរយ ព្រមជាមួយនឹងសេណារីយ៉ូ ចំណូលដែលមានលក្ខណៈសុទិដ្ឋនិយម និងសម្រេចបានគោលដៅនៃអាទិភាពគោលនយោ បាយដូចបានគួសបញ្ជាក់ខាងលើ ច្បាប់ស្តីអំពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ បានកំណត់ក្របខណ្ឌថវិការឆ្នាំ២០១៩ ដូចខាងក្រោម:

១. ចំណាយសរុបនៃថវិការស្មើនឹង ២៤,៧២ភាគរយ នៃផ.ស.ស

២. ចំណូលក្នុងប្រទេសថវិការដ្ឋត្រូវសម្រេចឱ្យបានស្មើនឹង ១៩,២៨ភាគរយ នៃផ.ស.ស

៣. អតិរេកចរន្តត្រូវរក្សាឱ្យបានក្នុងកម្រិតបរិមាណ ២,៨១ភាគរយនៃផ.ស.ស ។

៤. ឱនភាពថវិការសរុបត្រូវបានកាត់បន្ថយឱ្យនៅត្រឹមកម្រិតប្រមាណ -៥,៤៥ ភាគរយ នៃផ.ស.ស

ការអនុវត្តន៍ការប្រមូលចំណូលថវិការ ក្នុងក្របខណ្ឌនៃគោលដៅខាងលើ រាជរដ្ឋាបាភិបាលត្រូវបង្កើនចំណូល ក្នុងប្រទេសថវិការជាតិឱ្យស្មើនឹង ១៨,០ភាគរយនៃ ផ.ស.ស គឺស្មើនឹង ១៩ ៧៨៦ ២៦០លានរៀល ដែលមានកំណើន ១២,២ភាគរយ ធៀបនឹងច្បាប់ឆ្នាំ២០១៨ តាមគោលដៅនេះ៖

ក. ចំណូលចរន្តថ្នាក់ជាតិ ត្រូវសម្រេចឱ្យបានចំនួន ១៩ ៥៩៣ ១១១ លានរៀល ត្រូវជា ១៧,៨៣ភាគរយ នៃ ផ.ស.ស គឺមានកំណើន ១២,២ភាគរយ ធៀបនឹងឆ្នាំ២០១៨ ដែលក្នុងនេះ

ខ. ចំណូលសារពើពន្ធ ត្រូវសម្រេចឱ្យបានចំនួន ១៦ ៨៧៩ ០០០ លានរៀល ត្រូវជា ១៥,៣៦ភាគរយ នៃ ផ.ស.ស គឺមានកំណើន ១២,០ភាគរយ ធៀបនឹងច្បាប់ឆ្នាំ២០១៨។

គ. ចំណូលគយ និងរដ្ឋាករ ត្រូវបានគ្រោងចំនួន ៩ ០៩៤ ០០០លានរៀល ត្រូវជា៨២,៨ភាគរយ នៃផ.ស.ស គឺមានកំណើន ៩,២ភាគរយ ធៀបនឹងឆ្នាំ២០១៨។

ឃ. ចំណូលពន្ធដារ ត្រូវបានគ្រោងចំនួន ៧ ៧៨៥ ០០០លានរៀលត្រូវជា៧០,៨ភាគរយនៃ ផ.ស.ស គឺមានកំណើន ១៥,៤ភាគរយ ធៀបនឹងច្បាប់ឆ្នាំ២០១៨។

ង. ចំណូលមិនមែនសារពើពន្ធ ត្រូវបានគ្រោងចំនួន ២ ៧១៤ ១១១លានរៀល ត្រូវជា ២,៤៧ភាគរយនៃ ផ.ស.ស គឺមានកំណើន ១៣,៨ភាគរយ ធៀបនឹងច្បាប់ឆ្នាំ២០១៨ ក្នុងនោះ

ឆ .ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងទៀត ថ្នាក់ជាតិ ត្រូវបានគ្រោងចំនួន ២ ៣៩១ ៥៥៥ លានរៀល មានកំណើន ១៣,០ភាគរយ ធៀបនឹងច្បាប់ឆ្នាំ២០១៨។

១. ចំណូលមូលធន ត្រូវបានគ្រោងចំនួន ៥ ៧៦៦ ៩១៧លានរៀល ត្រូវជា ៥២,៥ភាគរយ នៃ ផ.ស.ស គឺមានកំណើន ១៥,៩ភាគរយ ធៀបនឹងច្បាប់ឆ្នាំ២០១៨ ដែលក្នុងនោះ

២. ចំណូលមូលធនក្នុងស្រុក ដែលជាចំណូលមានប្រភពមកពីការសងត្រឡប់មកវិញនូវប្រាក់ដើមពីសហគ្រាសសាធារណៈរបស់រដ្ឋ ត្រូវសម្រេចឱ្យបានចំនួន ១៩៣ ១៤៩លានរៀល ត្រូវជា ០,១៨ភាគរយ នៃ ផ.ស.ស គឺមានកំណើន ៧,២ភាគរយ ធៀបនឹងឆ្នាំ២០១៨។

៣. ចំណូលមូលធនក្រៅប្រទេស ត្រូវសម្រេចឱ្យបានចំនួន៥ ៥៧៣ ៧៦៨លានរៀល ត្រូវជា ៥០,៧ភាគរយនៃ ផ.ស.ស គឺមានកមណើន ១៦,២ភាគរយ ធៀបនឹងឆ្នាំ២០១៨។

ការអនុវត្តចំណាយចរិការ រាជរដ្ឋាភិបាលនឹងត្រូវការចំណាយចរិការសរុបចំនួន២៧ ១៦៤ ៩៩៦ លានរៀល ត្រូវជា ២៤,៧២ភាគរយនៃ ផ.ស.ស មានកំណើន១១,៤ភាគរយ គឺកើនឡើង ០,១៨ ពិន្ទុភាគរយ នៃផ.ស.ស ធៀបជាមួយនឹងច្បាប់ ស្តីពីហិរញ្ញវត្ថុឆ្នាំ២០១៨។ ចំណាយចរន្តចរិការថ្នាក់ជាតិ មានចំនួន ១៦ ៨២៧ ២៨០ លានរៀល ត្រូវជា ១៥,៣១ភាគរយ នៃ ផ.ស.ស គឺមានកំណើន ១០,៦ភាគរយ ធៀបនឹងច្បាប់ឆ្នាំ២០១៨។ ចំណាយមូលធនថ្នាក់ជាតិត្រូវបានគ្រោង ៨ ៩៣៧ ៧៤៨លានរៀន មានសមាមាត្រស្មើនឹង ៣៤,៧ភាគរយ នៃ ចំណាយចរិការជាតិសរុប ត្រូវជា ៨,១៣ភាគរយនៃ ផ.ស.ស មានកំណើន ៨,៩ភាគរយ ធៀបនឹងច្បាប់ឆ្នាំ ២០១៨។

ប្រទេសកម្ពុជា បានបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការជំរុញចំណូលពន្ធតាមរយៈ ការអនុវត្តយុទ្ធសាស្ត្រជំរុញ ការប្រមូលប្រាក់ចំណូល ឆ្នាំ២០១៤-២០១៨។ យុទ្ធសាស្ត្រនេះសង្កត់ធ្ងន់ ទៅលើការពង្រឹងរដ្ឋបាលពន្ធដាររួមមានការធ្វើឱ្យ ប្រសើរឡើងនូវការអនុវត្តពន្ធនាំចូល ការខិតខំប្រឹងប្រែងប្រឆាំង ការគេចពន្ធ ការប្រមូល

បំណុលនិងការពង្រឹងការគោរពច្បាប់ពន្ធដារ ដោយផ្តោតលើសវនកម្មពន្ធនិងសេវាកម្មអ្នកជាប់ពន្ធ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ រួមជាមួយនឹងកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស បានជួយបង្កើនប្រាក់ចំណូលពន្ធដល់ប្រហែល ១៧ភាគរយនៃ ផ.ស.ស ក្នុងឆ្នាំ២០១៨ មានត្រឹមតែប្រមាណ១០ភាគរយប៉ុណ្ណោះដែលកាលពីក្នុងឆ្នាំ ២០១០។

នៅក្នុងប្រទេសកម្ពុជា សកម្មភាពសេដ្ឋកិច្ចគឺត្រូវបានចូលរួមចំណែកដោយសហគ្រាសធុនតូច និងមធ្យម បើទោះបីជាកំណើនសេដ្ឋកិច្ចដ៏ឆាប់រហ័សក្នុងមួយទសវត្សរ៍ចុងក្រោយនេះ ប៉ុន្តែផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់នៅមានកម្រិតទាប៣០៨ដុល្លាអាមេរិក។ នៅក្នុងវិស័យដ៏សំខាន់ទាំងបីវិស័យៈ កសិកម្ម ឧស្សាហកម្ម និងសេវាកម្ម ហើយ វិស័យឧស្សាហកម្មមានសក្តានុពលភាគច្រើនបំផុត។ នៅឆ្នាំ២០០៣ វិស័យឧស្សាហកម្មបានកើនឡើង នៅក្នុងចំណែកដ៏សំខាន់ស្មើនឹង ២៧,៧ភាគរយនៃផលិតផលក្នុងស្រុកសរុប (GDP)។ នៅក្នុងវិស័យកាត់ដេរ វាយនភណ្ឌនិងស្បែកជើង មាន១២,៥ភាគរយ នៃផលិតផលក្នុងស្រុកសរុបអំឡុងឆ្នាំ១៩៩៤ ដល់ឆ្នាំ២០០២ បានកើនឡើងជាង ៥៧៩លានដុល្លារអាមេរិក នៅក្នុងការវិនិយោគទ្រព្យសកម្ម។ វិស័យកសិកម្ម និងវិស័យសេវាកម្ម គឺជាផ្នែកមួយដ៏ធំបំផុតសម្រាប់ផលិតផលក្នុងស្រុកសរុប(GDP) និងការងារ។ នៅក្នុងឆ្នាំ២០០៣ វិស័យកសិកម្មមានចំនួន៣៦ភាគរយ នៃផលិតផលក្នុងស្រុក ខណៈពេលដែលវិស័យសេវាកម្មមានចំនួន ៣៦,២ភាគរយ នេះបើតាមធនាគារអភិវឌ្ឍន៍អាស៊ី(ADB)។ វិស័យឧស្សាហកម្ម និង វិស័យសេវាកម្មជាមូលដ្ឋានដ៏ចម្បង ដែលត្រូវបានគាំទ្រ ក្នុងការនាំចេញផលិតផលសម្លៀកបំពាក់ទៅកាន់ទីផ្សារសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប និងកំណើននៃភ្ញៀវទេសចរណ៍មកទស្សនាប្រទេសកម្ពុជា ជាពិសេសប្រាសាទអង្គរវត្ត។ ខណៈពេលដែលការចែករំលែកនៃវិស័យកសិកម្មដល់សេដ្ឋកិច្ចជារួមត្រូវបានថយចុះ ចំណែកវិស័យឧស្សាហកម្ម និងសេវាកម្ម ត្រូវបានរីកលូតលាស់ ហើយនិងមានសារៈសំខាន់នៅក្នុងវិស័យសេដ្ឋកិច្ច។ នៅក្នុងឆ្នាំ២០០៦ ភាគរយនៃវិស័យឧស្សាហកម្មនៅក្នុងសេដ្ឋកិច្ចប្រទេសកម្ពុជា បានកើនឡើងពី ១៧,៩ភាគរយ នៅក្នុងឆ្នាំ១៩៩៨ ដល់២៧,៧ភាគរយ នៅក្នុងឆ្នាំ២០០៤ ខណៈពេលដែលវិស័យសេវាកម្មបានកើនឡើងពី ៣៥,0ភាគរយ ទៅ ៣៦,២ភាគរយ។ សហគ្រាសធុនតូច និងមធ្យម (រួមទាំងខ្នាតតូច) ដែលមានចំនួន ៩៩ភាគរយ បានប្រើប្រាស់ការងារ ៤៥ភាគរយ ពីទីផ្សារកម្លាំងពលកម្មនេះ នេះបើតាម(ADB)។

តារាង ២.២.២ ការបែងចែកក្រុមហ៊ុន ឬសហគ្រាស

| ភាគរយគិតជាចំនួនសហគ្រាស | | | | | |
|---|---|---|---|---|---|
| | តូច | មធ្យម | ធំ | សរុប | ភាគរយនៃ GDP |
| ឧស្សាហកម្មផលិត | ៤.៣ | ១.៧ | ២.៧ | ៨.៨ | ២៨.២ |
| ពាណិជ្ជកម្ម | ២៣.៣ | ៤.៥ | ១.0 | ២៨.៨ | ១៤.៥ |

| | | | | | |
|---|---|---|---|---|---|
| ទេសចរណ៍ | ១៨.៤ | ៩.៧ | ០.៤ | ២៨.៥ | ៧.០ |
| ផ្សេងៗ | ២៥.២ | ៩.៧ | ២.៨ | ៣៧.៨ | ៥០.៣ |
| សរុប | ៧១.២ | ២១.៨ | ៧.០ | ១០០ | ១០០.០ |

*ប្រភព: ហង់ ជួនណារ៉ុន សេដ្ឋកិច្ចកម្ពុជា ទំព័រ២៥០, ធនាគារពិភពលោក និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ។ បរិយាកាសវិនិយោគល្អប្រសើរដើម្បីកំណើនប្រកបដោយចេរភាព នៅក្នុងប្រទេសកម្ពុជា។ សេចក្តីព្រាងសម្រាប់ពិភាក្សាថ្ងៃទី០៩ កុម្ភៈឆ្នាំ២០០៩។ ការបែងចែកដោយផ្អែកលើការប៉ាន់ស្មាន។*

តាមរយៈ តារាងខាងលើ យើងអាចមើលឃើញថា មានសហគ្រាស ឬក្រុមហ៊ុននៅកម្ពុជាតែ ៧ភាគរយប៉ុណ្ណោះ ដែលអាចចាត់ថាជាសហគ្រាសធំ ហើយ២១.៨ភាគរយទៀត ជាសហគ្រាសខ្នាត មធ្យម។ សហគ្រាសឯកជនភាគច្រើនលើសលុប ៧១.២ភាគរយ ជាសហគ្រាស ឬក្រុមហ៊ុនខ្នាតតូច ហើយដែលសហគ្រាសចំនួន ២៨.៨ ភាគរយ ស្ថិតនៅក្នុងវិស័យពាណិជ្ជកម្ម និង២៤.៥ ភាគរយ ស្ថិតនៅក្នុងវិស័យទេសចរណ៍។ មានតែសហគ្រាស ៨.៨ភាគរយប៉ុណ្ណោះ ជាសហគ្រាសស្ថិតនៅក្នុងឧស្សាហកម្ម។ ក្នុងចំណោមអាជីវកម្ម ដែលបានចុះបញ្ជីជិតពាក់កណ្តាល៤៨.២ភាគរយ ស្ថិតនៅក្នុងផ្នែកពាណិជ្ជកម្ម បន្ទាប់មកគឺសេវាកម្ម ៤៥.៤ភាគរយ កម្មន្តសាលនិងសំណង់ ៥.៤ ភាគរយ និងធនធានធម្មជាតិ១ភាគរយ។ អាជីវកម្មទាំងនោះ នៅក្នុងវិស័យពាណិជ្ជកម្មមានតែ ១ភាគរយ ប៉ុណ្ណោះ នៃសហគ្រាសទាំងនោះ ជាអាជីវកម្មលក់ដុំ ចំណែកឯ ៦៤ភាគរយទៀត ស្ថិតនៅក្នុងផ្នែកលក់រាយហើយ ៣៥ភាគរយទៀត ហាងលក់ចាប់ហួយ និងអាជីវកម្មគ្រឿងទេស។ នៅក្នុងវិស័យសេវាកម្ម ដែលជាឧស្សាហកម្មធំបំផុតទី២ សេវាកម្មម្ហូបអាហារ មានរហូតទៅដល់៤៨ ភាគរយនៃសហគ្រាស។ សហគ្រាសមីក្រូមានចំនួន ៩៧ភាគរយ នៃអាជីវកម្មទាំងអស់ដែលបានចុះបញ្ជី។ អាជីវកម្មតែ២ ភាគរយប៉ុណ្ណោះ គឺជាសហគ្រាសខ្នាតតូច ហើយតិចជាង ១ភាគរយ នៃចំនួនសរុបសហគ្រាសធុនមធ្យម និងធំ។ អាជីវកម្មនៅកម្ពុជា គឺនៅថ្មីនៅឡើយ ដែលមានអាជីវកម្មតែ ១៥ ភាគរយ ប៉ុណ្ណោះ បានដំណើការជាង១០ឆ្នាំ។ អាជីវកម្មភាគច្រើន ៦៤ភាគរយទើបតែដំណើរការមិនដល់៥ឆ្នាំផង ចំណែកឯ ៣១ភាគរយ ទៀតដំណើរការរយៈពេលតិចជាង២ឆ្នាំ។ ដោយសារតែអាជីវកម្មភាគច្រើន នៅក្នុងប្រទេសកម្ពុជា មានទំហំតូច ប្រើប្រាស់បុគ្គលិកតិច និងគ្រប់គ្រងជា លក្ខណៈគ្រួសារ ធ្វើឱ្យអាជីវកម្មជាង ៩៩ភាគរយ ផ្តោតការយកចិត្តទុកដាក់តែទីផ្សារក្នុងស្រុក មានតែក្រុមហ៊ុន១ភាគរយប៉ុណ្ណោះក្នុងចំណោមសហគ្រាសទាំងអស់ដែលផ្តោតទៅលើទីផ្សារអន្តរជាតិនិងទីផ្សារក្នុងស្រុក។

សេដ្ឋកិច្ចកម្ពុជានៅក្នុងឆ្នាំ២០២០ ត្រូវបានប៉ាន់ស្មានថា នឹងមានកំណើនអវិជ្ជមាន ១.៩ភាគរយ ដែលជាអត្រាមិនធ្លាប់មានកន្លងមក ដែលតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ កំណើនសេដ្ឋកិច្ចគ្រោងសម្រេចឱ្យបានក្នុងអត្រា ៦.៥ភាគរយ ដោយសារការរីករាលដាលយ៉ាងលឿននៃជំងឺកូវីដ១៩ និងរុញច្រានប្រទេសជាច្រើន ជាពិសេសបណ្តាប្រទេសជាដៃគូពាណិជ្ជកម្មសំខាន់ៗ របស់កម្ពុជាប្រឈមនឹងកំណើនអវិជ្ជមា

ន។ តាមការព្យាករណ៍កំណើនសេដ្ឋកិច្ចនៅឆ្នាំ២០២១ ត្រូវបានរំពឹងថា អាចនឹងងើបឡើងវិញមកអត្រាកំណើន ៣.៥ភាគរយ ដោយសារការរំពឹងទុកនៃការងើបឡើងវិញយឺតនៃសកម្មភាពសេដ្ឋកិច្ច។ កំណើននេះ ត្រូវបានគាំទ្រ ដោយកំណើននៃវិស័យកសិកម្មប្រមាណ១៦ភាគរយ ដោយ សារការកើនឡើងវិញក្នុងកម្រិតទាបនៃអនុវិស័យ កាត់ដេរ និងអនុវិស័យសំណង់។[51]

## ២.៣.ការប្រើប្រាស់បច្ចេកវិទ្យារបស់សហគ្រាសតាមកម្រិតនៃភាពចាស់ទុំ

### ២.៣.១ បដិវត្តឧស្សាហកម្មទី៤.0 នៅកម្ពុជា

ក្នុងពេលបច្ចុប្បន្ននេះ កម្ពុជាបាននិងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំង ដើម្បីធ្វើឱ្យមានសន្ទុះនៃការលើក កម្ពស់ចំណេះដឹងលើបដិវត្តន៍ឧស្សាហកម្មទី៤ និងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលនៅក្នុងប្រទេស ជាពិសេសគេ ឃើញមានគំនិតផ្តួចផ្តើមជាច្រើនពីវិស័យឯកជន ក្នុងការលើកទឹកចិត្តសហគ្រិនវ័យក្មេងឱ្យបង្កើតអាជីវកម្មឌីជីថ លផ្ទាល់ខ្លួននៅក្នុងប្រទេស។ រាជរដ្ឋាភិបាលក៏បានព្យាយាមជួយដល់វិស័យឌីជីថល តាមរយៈការដាក់ចេញ គោលនយោបាយ និងការផ្តល់មូលនិធិសហគ្រិនភាពដែលមានតម្លៃស្មើនឹង៥លានដុល្លារអាមេរិក ដើម្បីគាំទ្រ អាជីវកម្មឌីជីថល។ នៅក្នុងមជ្ឈដ្ឋានសាធារណៈវិញ និន្នាការនេះត្រូវបានអង្គការក្រៅរដ្ឋាភិបាល និងវេទិកា សង្គមស៊ីវិល ជួយជម្រុញឱ្យមានការផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងអំពីឧស្សាហកម្ម៤.0 ព្រមទាំងផ្តួច ផ្តើមឱ្យមានការពិភាក្សាក្នុងចំណោមបញ្ញាវ័ន្ត អ្នកបង្កើតគោលនយោបាយ និងអ្នកជំនាញ។ សន្តិសុខឌីជីថលក៏ ជាផ្នែកអាទិភាពមួយ ដែលបានកំណត់ដោយ នាយករដ្ឋមន្ត្រីកម្ពុជា ផ្ទាល់ដើម្បីធានាឱ្យបាននូវបរិស្ថានឌីជីថល ដែលមានសុវត្ថិភាពពេញលេញ និងគ្រប់ជ្រុងជ្រោយ។ ដូច្នេះ គោលនយោបាយពាក់ព័ន្ធ បទប្បញ្ញត្តិ និងស្តង់ដារ បទដ្ឋានគតិយុត្ត កំពុងត្រូវបានបង្កើតជាបន្តបន្ទាប់ ហើយអនុវត្តដើម្បីការពារសន្តិសុខរបស់ទិន្នន័យ និងការ សម្ងាត់ ការជួញដូរតាមអេឡិចត្រូនិច និងសន្តិសុខលើប្រព័ន្ធអ៊ីនធឺណិត។ យោងតាមប្រសាសន៍របស់រដ្ឋមន្ត្រី សេដ្ឋកិច្ច និងហិរញ្ញវត្ថុ លោកអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន កម្ពុជាត្រូវការពេលយ៉ាងហោចណាស់មួយ ទសវត្សរ៍ ដើម្បីចាប់យកការផ្លាស់ប្តូរឌីជីថលដែលពេញលេញមួយ។ ក្នុងការសម្រេចគោលបំណងនេះ ភាគីពាក់ ព័ន្ធទាំងអស់ត្រូវយល់ដឹងអំពីនិន្នាការ និងចាត់វិធានការចាំបាច់ ដើម្បីត្រៀមខ្លួនឱ្យបានរួចជាស្រេចសម្រាប់ការ មកដល់នៃបដិវត្តន៍ឧស្សាហកម្មទី៤។ ដើម្បីចូលរួមចំណែកក្នុងដំណើរកម្ពុជាក្នុងការត្រៀមខ្លួន ដើម្បីសម្របខ្លួន

[51] ហាង់ ជួនណារ៉ុន សេដ្ឋកិច្ចកម្ពុជា ទំព័រ២៥០, ធនាគារពិភពលោក និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ។ បរិយាកាសវិនិយោគល្អប្រសើ ដើម្បីកំណើនប្រកបដោយចេរភាព នៅក្នុងប្រទេសកម្ពុជា។ សេចក្តីព្រាងសម្រាប់ពិភាក្សាថ្ងៃទី០៩ កុម្ភៈឆ្នាំ២០០៩។ ការបែងចែកដោយ ផ្អែកលើការប៉ាន់ស្មាន។

និងទាញយកផលប្រយោជន៍ជាអតិបរមាពីបដិវត្តន៍ឧស្សាហកម្មទី៤ មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា បានបង្កើតឡើងកម្មវិធីកិច្ចសន្ទនាពិសេសមួយដែលមានឈ្មោះថា កម្ពុជាឧស្សាហកម្ម៤.០។[52]

### ២.៣.២ វិស័យកម្មន្តសាល

បច្ចេកវិទ្យាដែលប្រើប្រាស់ក្នុងវិស័យកម្មន្តសាល ត្រូវបានពិនិត្យអង្កេតដោយធៀបនឹងរយៈពេលដំណើរការរបស់សហគ្រាសដូចមានបង្ហាញក្នុងរូបភាពទី១៩ ការចាប់យកច្ចេកវិទ្យាក្នុងចំណោមសហគ្រាសមានលក្ខណៈវិជ្ជមានក្នុងចំណោមសហគ្រាសដែលដំណើរការលើសពីប្រាំឆ្នាំ ជាក់ស្តែង បច្ចេកវិទ្យាឈានមុខចំនួនបីជាអាទិ៍ ប្រព័ន្ធកំណត់ទីតាំងតាមពេលជាក់លាក់ ទំនាក់ទំនងផ្ទាល់រវាងម៉ាស៊ីននិងម៉ាស៊ីន និងបច្ចេកវិទ្យាបន្ថែមទិន្នន័យលើ រូបភាពប្រត្យក្ស/បច្ចេកវិទ្យារូបភាពប្រត្យក្សនិម្មិត (AR/VR) ជាដើមកំពុងតែត្រូវបានប្រើប្រាស់ដោយសហគ្រាស។

ម្យ៉ាងវិញទៀត សហគ្រាសដែលដំណើរការចន្លោះពីបីទៅប្រាំឆ្នាំបានចាប់យកបច្ចេកវិទ្យាផ្សេងៗដូចជា៖ បច្ចេកវិទ្យាឧបករណ៍ចាប់សញ្ញា ប្រព័ន្ធត្រួតពិនិត្យឡូស៊ិកដោយប្រើកម្មវិធី ឧបករណ៍ចល័ត បច្ចេកវិទ្យាដាក់ស្លាកសញ្ញា ម៉ីនធីណិតនៃវត្ថុ បច្ចេកវិទ្យាពពក ទិន្នន័យទំហំធំ និងដំណើរការនៃការផលិតវត្ថុដោយបន្ថែមម្តងមួយស្រទាប់ៗ។ ជាការកត់សម្គាល់ ការចាប់យកបច្ចេកវិទ្យាទាំងបីដូចបានរៀបរាប់ខាងលើមិនសូវជាមានលក្ខណៈលេចធ្លោប៉ុន្មានទេ បើធៀបជាមួយនឹងសហគ្រាសដែលមានភាពចាស់ទុំជាង។ តាមពិត បច្ចេកវិទ្យាទាំងបីនេះមានសក្តានុពលខ្លាំងសម្រាប់ សហគ្រាសក្នុងវិស័យកម្មន្តសាលដើម្បីបានផលប្រយោជន៍ដោយចីរភាព។

ដោយដាក់បញ្ចូលប្រព័ន្ធត្រួតពិនិត្យឡូស៊ិកដោយប្រើកម្មវិធី បច្ចេកវិទ្យាចាប់សញ្ញា និងប្រព័ន្ធកំណត់ទីតាំង តាមពេលជាក់លាក់ សហគ្រាសកម្មន្តសាលអាចធ្វើការសម្រេចចិត្តដោយសន្សំសំចៃនិងសាមញ្ញ និងជំរុញ




[52] កិច្ចសន្ទនា កម្ពុជាឧស្សាហកម្ម ៤.០

សមត្ថភាព ទំនាក់ទំនងរវាងម៉ាស៊ីននិងម៉ាស៊ីន (Laghari et al., ២០២១)។ លើសពីនេះទៅទៀត ការអនុវត្តប្រព័ន្ធកំណត់ទីតាំង តាមពេលជាក់លាក់ផ្តល់នូវគុណសម្បត្តិជាច្រើនជាអាទិ៍៖ ការកាត់បន្ថយថ្លៃដើម កាត់បន្ថយកំហុសដែលបង្កដោយ មនុស្ស និងសមត្ថភាពក្នុងការតាមដានរកបញ្ហាដើម្បីដោះស្រាយនៅនឹងកន្លែង (Rácz-Szabó et al., ២០២០)។ផ្ទុយមកវិញ សហគ្រាសដែលដំណើរការតិចជាង ឬស្មើពីរឆ្នាំមានលទ្ធភាពតិចតួចក្នុងការចាប់យកបច្ចេកវិទ្យា បើធៀបនឹងសហគ្រាសដែលដំណើរលើសពីពីរឆ្នាំ។ ជាការកត់ចំណាំ សហគ្រាសដែលដំណើរការចន្លោះពីបីទៅប្រាំឆ្នាំ និងលើសពីប្រាំឆ្នាំ មានលទ្ធភាពក្នុងការចាប់យកបច្ចេកវិទ្យាជាងសហគ្រាសដែលទើបតែដំណើរការ។ ហេតុដូច្នេះការយកចិត្តទុកដាក់តាមរយៈការគាំទ្រផ្សេងៗជាកិច្ចការចាំបាច់មួយ ព្រោះថាសហគ្រាសថ្មីៗភាគច្រើនដើរតួនាទីយ៉ាង សំខាន់ក្នុងដំណើរការនវានុវត្តន៍និងការអភិវឌ្ឍនូវផលិតផលថ្មី និង/ឬធ្វើឱ្យប្រសើរឡើងនូវបច្ចេកទេសផលិតកម្ម។

តារាងទី២.៣.២៖ ការប្រើប្រាស់បច្ចេកវិទ្យាធៀបនឹងសហគ្រាសដែលដំណើរការក្នុងវិស័យកម្មន្តសាល

សហគ្រាសដែលមានភាពចាស់ទុំអាចចាប់យកស្ទើរតែគ្រប់ប្រភេទនៃបច្ចេកវិទ្យា និងទាមទារគុណវុឌ្ឍខ្ពស់ន បុគ្គលិកដើម្បីដោះស្រាយបញ្ហាផ្សេងៗក្នុងខ្សែច្រវាក់ផលិតកម្មដែលប្រើបច្ចេកវិទ្យា។ ការអភិវឌ្ឍធនធានមនុស្សតាមរយៈការផ្ទេរបច្ចេកវិទ្យា ឬទទួលយកនិស្សិតបញ្ចប់ការសិក្សាដែលទទួលបានការបណ្តុះបណ្តាលល្អពីសាកលវិទ្យាល័យ ឬសាលាអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ(ជីវ៉េត) ជាមូលដ្ឋានកិច្ចការចម្បងមួយដើម្បីសម្រេចបាន នវានុវត្តន៍ឧស្សាហកម្ម។ សហគ្រាសដែលដំណើរការតិចជាង ឬស្មើនឹងពីរឆ្នាំ និងចន្លោះពីបីទៅប្រាំឆ្នាំ គួរតែចាប់ យកឱ្យបានលឿននូវបច្ចេកវិទ្យាថ្មីៗ ជាងនេះទៅទៀត សហគ្រាសទាំងនោះគួរសហការឱ្យបានលឿនជាមួយ វិស័យអប់រំ ដើម្បីចាប់យកឱ្យទាន់ពេលនូវបច្ចេកវិទ្យាផ្សេងៗ ការវិនិយោគលើបច្ចេកវិទ្យាចម្បងៗដូចជាប្រព័ន្ធ កំណត់ទីតាំងតាមពេលជាក់លាក់ និងទំនាក់ទំនងរវាងម៉ាស៊ីននិងម៉ាស៊ីន ជាភារកិច្ចចាំបាច់ត្រូវអនុវត្តមួយសម្រាប់សហគ្រាសដែលទើបតែដំណើរការ។[53]

### ២.៣.៣វិស័យកាត់ដេរកម្ពុជា

ជាក់ស្តែង នៅឆ្នាំ២០២១ វិស័យកាត់ដេរកើនឡើងក្នុងរង្វង់ ១៥% បន្ទាប់ពីធ្លាក់ចុះក្នុងរង្វង់ ១០% ឆ្នាំ២០២០។ ក្នុងនោះ ការនាំចេញទៅកាន់សហរដ្ឋអាមេរិក រក្សាបានកំណើនខ្ពស់រង្វង់ ៣៥% ធៀបនឹងអត្រា ៣,៦% ក្នុងឆ្នាំ២០២០។ ចំពោះការនាំចូលវត្ថុធាតុដើម មានកំណើនខ្ពស់ដែរក្នុងអត្រា ២៤,៣% ឆ្នាំ២០២១ ធៀបនឹងអត្រាដក ១៣,៤% ក្នុងឆ្នាំ២០២០ ដែលនេះឆ្លុះបញ្ចាំងពីនិន្នាការនាំចេញផលិតផលកាត់ដេរនាពេលខាងមុខ។ ចំណែកការនាំចេញផលិតមិនមែនកាត់ដេរ ក៏មានការកើនឡើងខ្ពស់ផងដែរ។ ក្នុងនោះផលិតផល

[53] ចម ប្រសិទ្ធ(ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣)"ឧស្សាហូបនីយកម្ម៖ចាប់យកភាពឈានទៅមុខនៃបច្ចេកវិទ្យាសម្រាប់សហគ្រាស"ទំព័រទី២៤

ដែលមានតម្លៃបន្ថែមខ្ពស់មានដូចជា គ្រឿងសង្ហារឹម បន្ទះសូឡា គ្រឿងបង្គុំអេឡិចត្រូនិក កង់ខ្សែភ្លើង និងខ្សែអុបទិចជាដើម។ ឯកឧត្តម ឈាង វណ្ណារិទ្ធ បានគូសបញ្ជាក់ថា នៅឆ្នាំ២០២១ ការនាំចេញផលិតផលមិនមែនកាត់ដេរ កើនឡើងក្នុងអត្រា ៤១% ធៀបនឹង ២៦%ក្នុងឆ្នាំ២០២០។ទន្ទឹមនឹងនេះ វិនិយោគក្នុងអនុវិស័យនេះ ក៏មានការកើនឡើងពី ៥៤០លានដុល្លារ ក្នុងឆ្នាំ២០២០ ទៅ ៧២០ លានដុល្លារ ឆ្នាំ២០២១។ សម្រាប់ឆ្នាំ២០២២ វិស័យនេះ ត្រូវបានព្យាករណ៍ថា នឹងបន្តមានកំណើនរឹងមាំក្នុងអត្រា ១២.២% ដោយសារការបន្តកើនឡើងនៃតម្រូវការខាងក្រៅ និងកើនឡើងនៃអ្នកវិនិយោគមកកាន់កម្ពុជា និងការផ្លាស់ប្តូរចង្វាក់ផលិតកម្ម គ្រប់គ្រងតំបន់ រួមផ្សំនឹងការដាក់ចេញច្បាប់វិនិយោគថ្មី និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដែលនឹងជួយបង្កើនបរិយាកាសសេដ្ឋកិច្ចឱ្យកាន់តែមានភាពទាក់ទាញប្រសើរជាងមុខ។

សូមបញ្ជាក់ថា នៅឆ្នាំ២០២១ ចំណូលពីការនាំចេញផលិតផលមិនមែនកាត់ដេរវិញមានជាង ៤៣ពាន់លានដុល្លារ ដែលផលិតផលទាំងនោះរួមមានគ្រឿងបន្លាស់រថយន្ត ផលិតផលឧស្សាហកម្ម គ្រឿងបំណែកអេឡិចត្រូនិក បន្ទះសូឡា គ្រឿងបង្គុំអេឡិចត្រូនិក កង់ខ្សែភ្លើង និងខ្សែអុបទិច។ ចំណែកការនាំចេញផលិតផលកាត់ដេររបស់កម្ពុជា មានទំហំទឹកប្រាក់សរុបជាង ១១ពាន់លានដុល្លារ មានការកើនឡើងចំនួន១៥% បើប្រៀបនឹងឆ្នាំ២០២០។[54]វិស័យផលិតកម្មនៅកម្ពុជាត្រូវបានត្រួតត្រាដោយការផលិតសម្លៀកបំពាក់ និងស្បែកជើងដែលមានចំនួន ៧៤% នៃការនាំចេញទំនិញប្រចាំឆ្នាំ។ យោងតាមអគ្គនាយកដ្ឋានគយ និងរដ្ឋាករក្រោមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបាន ឱ្យដឹង ថាព្រះរាជាណាចក្រកម្ពុជាបាននាំចេញ នូវផលិតផលសម្លៀកបំពាក់ និងស្បែកជើងដែលមានតម្លៃជិត ៨ ពាន់លានដុល្លារក្នុងរយៈពេល ៩ ខែដំបូងនៃឆ្នាំ ២០១៩ ពោលគឺកើនឡើង ១៣ % បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៨ ។ ភាគច្រើននៃការនាំចេញ ទាំងនេះត្រូវបានដឹកនាំនៅ ផ្សារអឺរ៉ុប តែមួយសហរដ្ឋអាមេរិក និងជប៉ុន។

គិតមកដល់ពេលបច្ចុប្បន្ន កម្ពុជាមានរោងចក្រកាត់ដេរសរុប ១ ៣២៦រោងចក្រ នៅទូទាំងប្រទេស ដែលបានបង្កើតឱកាសការងាររាប់សែនកន្លែងសម្រាប់ប្រជាជនកម្ពុជា។ ក្នុងនោះ រាជធានីភ្នំពេញ បានទាក់ទាញការវិនិយោគច្រើនជាងគេ ដែលបានក្តោបក្តាប់រហូតជាង ៥០% នៃបរិមាណរោងចក្រកាត់ដេរសរុប បន្ទាប់មកនៅខេត្តកំពង់ស្ពឺ និងខេត្តកណ្តាល។ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានចាត់ទុកវត្តមានរបស់រោងចក្រកាត់ដេរ នៅក្នុងប្រទេសកម្ពុជា បានដើរតួនាទីយ៉ាងសំខាន់ក្នុងកិច្ចការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម នៅកម្ពុជា។ នេះបើតាមការអះអាងរបស់សម្តេចតេជោ ហ៊ុន សែន។ការបន្តរីកចម្រើនគឺដោយសារគោលនយោបាយសេដ្ឋកិច្ចបើកទូលាយ

[54] https://economy.ams.com.kh/economic/news/cambodias-garment-sector-to-grow-by-8-1-in-2022/តាមរបាយការណ៍ពីអគ្គនាយកគយ និងរដ្ឋាការកម្ពុជា

របស់កម្ពុជា ទីតាំងភូមិសាស្ត្រអំណោយផល និងកម្លាំងពលកម្មដ៏សម្បូរបែប ដែលនៅតែបន្តទាក់ទាញការវិនិយោគនៅក្នុងវិស័យនេះ។ នៅដើមឆ្នាំនេះប្រាក់ឈ្នួលអប្បបរមាសម្រាប់វិស័យនេះមានតម្លៃ ១៥៣ ដុល្លារក្នុងមួយខែ ដែលនឹងកើនឡើងដល់ ១៨២ ដុល្លារនៅចុងឆ្នាំនេះ។ បម្រែបម្រួល នេះនឹងធ្វើឱ្យប្រាក់ឈ្នួលអប្បបរមានៅកម្ពុជាខ្ពស់ជាងប្រទេសនានាដូចជា៖ ប្រទេសបង់ក្លាដេស ដែលសេដ្ឋកិច្ចរបស់ប្រទេសនេះពឹងផ្អែកយ៉ាងខ្លាំងលើ ឧស្សាហកម្មផលិតសំលៀកបំពាក់។ ដោយមិនគិតពីការកែទម្រង់នាពេលថ្មីៗនេះ ប្រាក់ឈ្នួលសម្រាប់កម្មករនិយោជិតកាត់ដេរ នៅតែមានតុល្យភាពសម្រាប់វិស័យឧស្សាហកម្ម និងប្រទេស ទាំងមូល ប៉ុន្តែការព្យាយាមបង្កើនប្រាក់ឈ្នួល និងឱកាសសម្រាប់កម្មករនិយោជិត ដែលនេះអាចធ្វើឱ្យលែងមានតុល្យភាពសេដ្ឋកិច្ចនៃទីផ្សារ។នេះមានន័យថា ប្រសិនបើតម្លៃនៃការផលិតកើនឡើងខ្ពស់ពេកនៅក្នុងប្រទេសកម្ពុជា ការផលិតខ្នាតធំនឹងមើលទៅទីផ្សារថ្មី ដែលជាកន្លែង ដែលតម្លៃពលកម្មទាបជាង ។[55]

ក្រាហ្វិកទី ២.៣.២ យោងតាមអគ្គនាយកដ្ឋានគយ និងរដ្ឋាករក្រោមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា

### ២.៣.៤ ឧស្សាហកម្មសំណង់

ឧស្សាហកម្មសំណង់ នៅកម្ពុជាត្រូវបាន គេមើលឃើញថាមានកំណើនថេរ ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ។ ជាមួយ នឹងកំណើនផលិតផលក្នុងស្រុកសរុប ៧.៥ %។ ជាលទ្ធផលធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងអាស៊ានរំពឹងថាកំណើនផលិតផលក្នុងស្រុកសរុប ៧ % នឹងបន្តសម្រាប់ប្រទេសកម្ពុជា។ ធនាគារពិភពលោករំពឹង ថាវិស័យសំណង់រីកចម្រើនរបស់កម្ពុជា នឹងចូលរួមចំណែកយ៉ាងសំខាន់ដល់




[55] យោងតាមអគ្គនាយកដ្ឋានគយ និងរដ្ឋាករក្រោមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា https://www.realestate.com.kh/km/investment-guide/core-industries/

កំណើននេះ។ ស័យសំណង់បានទាក់ទាញវិនិយោគិនបរទេសជាច្រើន ក្នុងនោះប្រមាណ ៩០% នៃការវិនិយោគដោយផ្ទាល់ពីបរទេស (FDI) គឺវិនិយោគិនតំបន់អាស៊ី។ ប្រទេសដែលចូលរួមចំណែកក្នុងវិស័យសំណង់ភាគច្រើនគឺ ប្រទេសចិន ជប៉ុន កូរ៉េ តៃវ៉ាន់ សិង្ហបុរី និងហុងកុង។ ប្រទេសចិនបានចូលរួមចំណែក ៤០% នៃ FDIs ក្នុងឆមាសទី ១ នៃឆ្នាំ ២០១៩ ។ វិនិយោគិនបរទេសផ្តោតជាពិសេសទៅលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធដោយមានការវិនិយោគធំៗពីរដ្ឋាភិបាលចិន ព្រមទាំងធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី។ គេរំពឹងទុកថាទុនវិនិយោគពីបរទេសសរុបនៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធនៅចន្លោះឆ្នាំ ២០១៣ និង ២០២២ នឹងស្ថិតនៅចន្លោះពី ១៤ ពាន់លាន ទៅ ១៦ ពាន់លានដុល្លារ។ សកម្មភាពសំណង់របស់ប្រទេសកម្ពុជាទំនងជានឹងបន្តកើនឡើងក្នុងអត្រាដូចគ្នា។ រដ្ឋាភិបាល និងវិនិយោគិនបរទេសកំពុងផ្តល់ អាទិភាពដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជាមួយវិស័យសំណង់ឯកជន។ លើសពីនេះទៀតតម្រូវការសម្រាប់ការអភិវឌ្ឍន៍អចលនទ្រព្យ ជាពិសេស ការអភិវឌ្ឍបុរីនៅតែមានកម្រិតខ្ពស់នៅទូទាំងប្រទេសកម្ពុជា ដោយសារតែចំនួនប្រជាពលរដ្ឋកំពុងកើនឡើងយ៉ាងឆាប់រហ័សនៅតាមទីក្រុង។[56]

### ២.៣.៥ វិស័យពាណិជ្ជកម្មនិងសេវាកម្ម

សហគ្រាសភាគច្រើនដែលដំណើរការលើសពីប្រាំឆ្នាំ មានបទពិសោធន៍ក្នុងការប្រើប្រាស់គ្រប់ប្រភេទនៃបច្ចេកវិទ្យា ក្នុងវិស័យពាណិជ្ជកម្មនិងសេវាកម្ម ដូចមានបង្ហាញក្នុងរូបភាពទី២០។ ផ្ទុយមកវិញ សហគ្រាសដែលដំណើរការតិចជាងប្រាំឆ្នាំ មានចំនួនតិចតួចបំផុតក្នុងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ។ សហគ្រាសតែងតែយល់មិន




[56] យោងតាមរបាយការណ៍ របស់ធនាគារពិភពលោក នៅខែឧសភាឆ្នាំ ២០១៩ ប្រទេសកម្ពុជាបានកើន លើសតួលេខដែលបានព្យាករនៅក្នុង កំណើនប្រចាំឆ្នាំសម្រាប់ឆ្នាំ ២០១៨ https://www.realestate.com.kh/km/investment-guide/core-industries/

គ្រប់គ្រាន់ ផលចំណេញពីការវិនិយោគលើបច្ចេកវិទ្យានៅមានកម្រិតទាបដែលធ្វើឱ្យសហគ្រាសមិនមានចេតនាក្នុងការវិនិយោគបន្ត (Passerini et al., ២០១២; Passerini, K., Tarabishy, A. E., & Patten, K, ២០១៤) ។ជាថ្មីម្តងទៀត សហគ្រាសដែលទើបតែដំណើរការគួរផ្តល់ការយកចិត្តទុកដាក់ខ្ពស់លើការវិនិយោគដើម្បី បច្ចេកវិទ្យា

តារាងទី២.៣.២៖ការប្រើប្រាស់បច្ចេកវិទ្យាធៀបនឹងសហគ្រាសដែលដំណើរការក្នុងវិស័យពាណិជ្ជកម្មនិងសេវាកម្ម

ឈានមុខក្នុងទម្រង់ជាកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នអប់រំ បណ្តុះបណ្តាល ឬធុរកិច្ចដែលមានសណ្ឋានបច្ចេកវិទ្យាស្រដៀងគ្នាក្នុងគោលដៅបង្កើនជំនាញដល់បុគ្គលិករបស់ខ្លួន។[57]

### ២.៣.៦ ដីជួល ដីសម្បទាន ឬដីឯកជន

លក្ខណៈនៃការប្រើប្រាស់ដីជាកត្តាសំខាន់មួយដើម្បីស្វែងយល់ពីស្ថានភាពអាជីវកម្មរបស់សហគ្រាសចំពោះវិស័យដែលត្រូវបានសិក្សាទាំងបី។ ការប្រើប្រាស់ដីរបស់សហគ្រាសនៅប្រទេសកម្ពុជាមានបីប្រភេទ រួមមាន ដីជួល ដីសម្បទាន និងដីឯកជន។ ដីជួល សំដៅដល់លក្ខខណ្ឌដែលម្ចាស់អចលទ្រព្យជួលទៅនីតិបុគ្គលណាមួយ។ ការជួលនេះមានពីរប្រភេទ គឺការជួលតាមកិច្ចសន្យាដែលមិនកំណត់ និងការជួលតាមកិច្ចសន្យាដែលមានពេល កំណត់ច្បាស់លាស់។ ការជួលតាមកិច្ចសន្យាដែលមានពេលកំណត់ច្បាស់លាស់រួមមានការជួលជាកុងត្រាប និង ការជួលជារយៈពេលយូររហូតដល់ដប់ប្រាំឆ្នាំ ឬលើសនេះ។ ដីសម្បទាន សំដៅដល់សិទ្ធិស្របច្បាប់ផ្តល់ដោយអជ្ញាធរ មានសមត្ថកិច្ចដោយមានឯកសារគតិយុត្តត្រឹមត្រូវតាមច្បាប់ភូមិបាលដែលបញ្ជាក់ពីការកាន់កាប់ដីរបស់នីតិបុគ្គល ឬ ក្រុមនៃនីតិបុគ្គល។ ដីសម្បទានត្រូវមានលក្ខណៈឆ្លើយតបនឹងតម្រូវការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។ ដីសម្បទាន ដែល ឆ្លើយតបនឹងគោលបំណងអភិវឌ្ឍន៍របស់សង្គម អាចឱ្យអ្នកទទួលកម្មសិទ្ធិកសាងសំណង់លំនៅដ្ឋាន និង/ឬដាំដុះ ដំណាំសម្រាប់ចិញ្ចឹមជីវិត។ ដីឯកជនសំដៅដល់ដីដែលត្រូវបានទិញដោយនីតិបុគ្គល ឬម្ចាស់របស់សហគ្រាស។ ជនបរទេសណាដែលកាន់អត្តសញ្ញាណប័ណ្ណក្លែងបន្លំដើម្បីទទួលបានសិទ្ធិជាម្ចាស់ដីក្នុងប្រទេសកម្ពុជា នឹងត្រូវទទួល ទណ្ឌកម្មដូចមានចែងក្នុងមាត្រាទី២៥១ នៃច្បាប់ភូមិបាល។ បើមានករណីនេះ ទ្រព្យសម្បត្តិនេះនឹងត្រូវរឹបអូសជា ទ្រព្យសម្បត្តិរដ្ឋ។ សហគ្រាសណាមួយដែលចុះឈ្មោះក្នុងប្រទេសកម្ពុជា និងមានភាគហ៊ុនរបស់ជនជាតិខ្មែរ ៥១.0% ឬលើសពីនេះនឹងត្រូវទទួលស្គាល់ជាម្ចាស់ដីតាមច្បាប់ភូមិបាលរបស់ប្រទេសកម្ពុជា (RGC, ២០០១, ២០០៣)។ដូចបង្ហាញក្នុងរូបភាពទី២១ ការបែងចែកការប្រើប្រាស់ដីក្នុងវិស័យកសិកម្មមាន ៤៦.៧% ប្រតិបត្តិការលើ ដីជួល ៣៦.៧% លើដីឯកជន និង ១0.0% លើដីសម្បទាន។ នៅក្នុងវិស័យពាណិជ្ជកម្មនិងសេវាកម្ម ការបែងចែក២៦ការប្រើប្រាស់ដីថ្មីបង្ហាញថា អាជីវកម្មភាគច្រើនពឹងផ្អែកលើដីជួល ដែលមានចំនួនប្រហែល ៦៦.៧% នៃវិស័យនេះ។ មួយចំណែកតូចនៃផ្នែកអាជីវកម្ម

---

[57]ចម ប្រសិទ្ធ(ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣)“ឧស្សាហូបនីយកម្ម៖ចាប់យកភាពឈានទៅមុខនៃបច្ចេកវិទ្យាសម្រាប់សហគ្រាស”ទំព័រទី២៥

ប្រហែល ១៩.៤% មានដីឯកជនផ្ទាល់ខ្លួន។ អាជីវកម្មដែលនៅសល់ ១៣.៩% ទៀត ដំណើរការលើដីក្រោមទម្រង់ផ្សេងទៀត។ ផ្ទុយទៅវិញ ការបែងចែកការប្រើប្រាស់ដីក្នុងវិស័យកម្មន្តសាល បង្ហាញចំណែកខុសគ្នាគួរឱ្យកត់សម្គាល់ ក្នុងនោះមានក្រុមហ៊ុនប្រមាណ ៥២.៩% កំពុងប្រតិបត្តិការលើដីឯកជន របស់ពួកគេ និងជិតពាក់កណ្តាលនៃក្រុមហ៊ុនសរុប គឺប្រហែល ៤៧.១% ប្រើប្រាស់ដីជួលសម្រាប់ប្រតិបត្តិការរបស់ ពួកគេ។

ដី គឺជាកត្តាសំខាន់មួយសម្រាប់សហគ្រាសក្នុងការចាប់យកបច្ចេកវិទ្យា។ ដីមិនត្រឹមតែជាទីតាំងជាក់ស្តែង សម្រាប់ការធ្វើអាជីវកម្មប៉ុណ្ណោះទេ ប៉ុន្តែក៏ជាទ្រព្យសម្បត្តិដែលអាចបម្លែងបានសម្រាប់ការដាក់បញ្ចាំក្នុងការទទួល បានឥណទានហិរញ្ញវត្ថុផងដែរ។ ការកាន់កាប់ដីធ្លីផ្តល់អត្ថប្រយោជន៍មួយចំនួន រួមមានការគ្រប់គ្រងពេញលេញលើ និងសមត្ថភាពក្នុងការធ្វើការសម្រេចចិត្តវិនិយោគរយៈពេលវែងដោយផ្អែកលើភាពប្រាកដប្រជការប្រើប្រាស់ដីធ្លីនោះ។ ទោះជាយ៉ាងណាក៏ដោយ ការទិញដីពិតជាមានបញ្ហាប្រឈម ជាពិសេសសម្រាប់ម្ចាស់សហគ្រាសថ្មី ព្រោះ ត្រូវការដើមទុនច្រើន។ ដំណោះស្រាយផ្សេងទៀត ដូចដែលបានបង្ហាញក្នុងរូបភាពទី២១ សហគ្រាសអាចដំណើរ ការលើដីជួល ក្នុងលក្ខខណ្ឌកំណត់ដែលការគ្រប់គ្រងមានកម្រិត និងប្រឈមមុខនឹងហានិភ័យដែលអាចកើតមាន មួយចំនួនដូចជារយៈពេលជួល ថ្លៃជួល ឬការដាក់កម្រិតលើការប្រើប្រាស់ដី។ កត្តាទាំងនេះអាចនាំមកនូវភាពមិន ច្បាស់លាស់ និងហានិភ័យសម្រាប់សហគ្រាស ដែលបង្កជាបញ្ហាប្រឈមក្នុងការរៀបចំផែនការ និងការវិនិយោគលើ ការចាប់យកបច្ចេកវិទ្យាប្រកបដោយទំនុកចិត្តក្នុងប្រតិបត្តិការរបស់ពួកគេ។ ម្យ៉ាងវិញទៀត សហគ្រាសដែលកំពុងប្រតិបត្តិការលើដីសម្បទាន ដែលជាដីផ្តល់ដោយរដ្ឋាភិបាល ឬអង្គភាពចំណុះសម្រាប់គោលបំណងជាក់លាក់ អាច មានទិដ្ឋភាពនៃការចាប់យកបច្ចេកវិទ្យាខុសគ្នា។ ក្នុងករណីខ្លះសម្បទានអាចផ្តល់មកជាមួយនឹងកាតព្វកិច្ចជាក់លាក់ ឬការរឹតត្បិតដែលកំណត់ដោយអង្គភាពផ្តល់នោះ។

អាស្រ័យហេតុនេះ សេដ្ឋកិច្ចអន្តរកាលអាចចាត់វិធានការជាក់លាក់មួយចំនួន ក្នុងការបង្កើតលក្ខខណ្ឌអំណោយផល ដើម្បីលើកទឹកចិត្តដល់សកម្មភាពសហគ្រិន និងកំណើនសហគ្រាសធុនតូច និងមធ្យម នៅក្នុងវិស័យ នានានៃសេដ្ឋកិច្ច។ វិធានការនេះអាចរួមបញ្ចូលការបង្កើតចង្កោមអាជីវកម្មដូចជា សួន វ.ប.ន. តំបន់សេដ្ឋកិច្ច ពិសេស (SEZs) បណ្តុំឧស្សាហកម្ម និងបណ្តុំសហគ្រាសធុនតូច និងមធ្យម ដែលអាចជំរុញទំនាក់ទំនងនិងបណ្តាញ សម្រាប់កិច្ចសហប្រតិបត្តិការ និងការលើកកម្ពស់ប្រសិទ្ធភាពធនធាន (Nguyen et al ., ២០០៨) ។ បន្ថែមពីនេះ អគ្គនាយកដ្ឋាន វ.ប.ន. បានទទួលភារកិច្ចពីរាជរដ្ឋាភិបាល តាមរយៈលិខិតលេខ ៩៣ សជណ.ឧប គួរត្រៀមខ្លួនជា មុនដើម្បីផ្តល់ក្របខណ្ឌគតិយុត្ត និងលិខិតូបករណ៍ ដែលគាំទ្រ និងលើកទឹកចិត្តដល់សហគ្រាសធុនតូច និងមធ្យម ក្នុងផ្នែកកម្មន្តសាល ដែលកំពុងប្រតិបត្តិការក្នុងចង្កោមសហគ្រាសធុនតូច និងមធ្យម សួន វ.ប.ន. ឬសួនបច្ចេកវិទ្យាខ្ពស់។ លើសពីនេះ ពាណិជ្ជកម្មនិងសេវាកម្មគួរតែត្រូវបានផ្សារភ្ជាប់គ្នាឱ្យកាន់តែជិតស្និទ្ធ ដែលបង្កើនប្រសិទ្ធភាព សេវាកម្មឱ្យកាន់តែប្រសើរឡើង។ តាមរយៈសមាហរណកម្មសកម្មភាព

ពាណិជ្ជកម្មនិងសេវាកម្មទាំងនេះ អាជីវកម្ម អាចបង្កើនរំហូរប្រតិបត្តិការ ផ្តល់បទពិសោធន៍កាន់តែប្រសើរឡើងសម្រាប់អតិថិជន និងទទួលបានប្រសិទ្ធភាព កាន់តែខ្ពស់។[58]

រូបភាពទី២.៣.៦៖ ការប្រើប្រាស់ដីសហគ្រាស




[58] ចម ប្រសិទ្ធ(ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣)“ឧស្សាហូបនីយកម្មៈចាប់យកភាពឈានទៅមុខនៃបច្ចេកវិទ្យាសម្រាប់សហគ្រាស” ទំព័រទី២៥

# ជំពូកទី៣

# ការពិភាក្សាលើ អភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងសម័យឧស្សាហកម្ម៤.0

# ជំពូកទី៣
# ការពិភាក្សាលើ អភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងសម័យឧស្សាហកម្ម៤.0

គោលនយោបាយរបស់រដ្ឋាភិបាលប្រទេសដែលមានការអភិវឌ្ឍលឿន ត្រូវតែស្របគ្នាជាមួយនឹងនិន្នាការពិភពលោក ជាពិសេសការបង្កើនតម្លៃឧស្សាហកម្មបច្ចេកវិទ្យាជាន់ខ្ពស់ ជាមួយនឹងផលប្រយោជន៍សំខាន់ៗដោយការកាត់បន្ថយនូវតួនាទីរបស់រដ្ឋាភិបាល ឧស្សាហកម្មដែលពឹងផ្អែកលើធនធានផ្សេងៗ។ កត្តាសំខាន់សម្រាប់កំណើនសេដ្ឋកិច្ចកំពុងបង្កើតឱ្យមានលក្ខខណ្ឌសម្រាប់ប្រទេសសេដ្ឋកិច្ចពឹងផ្អែកលើចំណេះដឹង តាមរយៈតួនាទីនៃការផលិត ចែកចាយ និងការប្រើប្រាស់ចំណេះដឹង និងព័ត៌មាន។ បណ្ដាប្រទេសដែលមានការអភិវឌ្ឍលឿនបំផុត រដ្ឋាភិបាលជាអ្នកធានានៃកំណើនសេដ្ឋកិច្ច និងសង្គម។ រដ្ឋាភិបាលបានជំរុញ និងលើកទឹកចិត្តឱ្យមានការបង្កើត និងអភិវឌ្ឍផ្នែកវិទ្យាសាស្ត្រ និងផ្នែកបច្ចេកវិទ្យា និងបង្កើតឱ្យមានលក្ខខណ្ឌអំណោយផលសម្រាប់អ្នកចូលរួមក្នុងដំណើរការនៃការធ្វើនវានុវត្តន៍។

## ៣.១ ទំនាក់ទំនងរវាងឧស្សាហកម្ម និងផលិតផលក្នុងស្រុកសរុប




រូបភាពទី៣.២.២ ការវិភាគ Simple Linear Regressionនៃវិស័យឧស្សាកម្មដោយផ្អែកលើកំណើន (GDP)

ការវិភាគ Simple Linear Regression បានបង្ហាញឱ្យឃើញថា វិស័យឧស្សាហកម្មមានឥទ្ធិពលលើកំណើន GDP ជាអត្ថន័យដោយស្ថិតិ ដោយ $F = 2680.62$, $p < 0.001$ ហើយវិស័យឧស្សាហកម្មអាចពន្យល់អំពីកំណើន GDP បាន 97.2%។ ប្រសិនបើវិស័យឧស្សាហកម្មកើនឡើង១ឯកតា វានឹងធ្វើឱ្យកំណើន GDP

កើនឡើង 3.881% (t=51.775, P< 0.001)។ Simple Linear Regression Model: កំណើន GDP = -2476.79 + 3.881 (ឧស្សាហកម្ម*)

## ៣.២ ទំនាក់ទំនងនៃពាណិជ្ជកម្ម និងផលិតផលក្នុងស្រុកសរុប




តារាងទី ៣.១.១ ការវិភាគ Simple Linear Regression នៃវិស័យពាណិជ្ជកម្ម ដោយផ្អែកលើកំណើន GDP

ការវិភាគ Simple Linear Regression បានបង្ហាញឱ្យឃើញថា វិស័យពាណិជ្ជកម្មមានឥទ្ធិពលលើកំណើន GDP ជាអត្ថន័យដោយស្ថិតិ ដោយ F = 92.641, p < 0.001 ហើយវិស័យពាណិជ្ជកម្មអាចពន្យល់អំពីកំណើន GDP ៥៤.៣ភាគរយ។ ហេតុដូច្នេះ ប្រសិនបើវិស័យពាណិជ្ជកម្ម ឯកតានោះវានឹងធ្វើឱ្យកំណើន GDP កើនឡើង 0.249% (t = 9.625; p < 0.001)។ Simple Linear Regression Model: កំណើន GDP = 14970.473 + 0.249 (ពាណិជ្ជកម្ម)។

## ៣.៣ ការវិភាគទំនាក់ទំនងនៃកំណើន GDP ក្នុងការនាំចេញ ប្រទេសកម្ពុជា

៣.៣ ការវិភាគ Regression នៃការនាំចេញនៃប្រទេសកម្ពុជា




ក្រាហ្វិក ទី ៣.៣ តម្លៃនៃការនាំចេញសរុបនៃប្រទេសកម្ពុជា ទៅកាន់ប្រទេសផ្សេងៗ

តម្លៃការនាំចេញសរុបនៃប្រទេសកម្ពុជា ទៅកាន់ទេសផ្សេងៗ ចាប់ពីឆ្នាំ 2000 (1,368.31 US$ million) រហូតដល់ឆ្នាំ2013 (9,248.47 US$ million) មានការកើនឡើងជាលំដាប់គួរឱ្យកត់សម្គាល់ ប៉ុន្តែធ្លាក់ចុះមកវិញបន្តិចនៅឆ្នាំ 2014 (6,881.79 US$ million) និងកើនឡើងវិញជាបន្តបន្ទាប់រហូតដល់ឆ្នាំ 2018 (12,412.22 US$ million)។ យោងតាមការវិភាគ Pearson Correlation Coefficient លទ្ធផលបាន បង្ហាញថា ចាប់តាំងពីឆ្នាំ 2000 ដល់ 2018 តម្លៃការនាំចេញនៃប្រទេសកម្ពុជា ទៅកាន់ប្រទេសផ្សេងៗ ($r = 0.972$; $p < 0.001$) មានការកើនឡើងជាលំដាប់ (ក្រាហ្វិកទី៤.៣.៣) ។

តារាងទី ៣.៣ ការវិភាគ Linear Regression តម្លៃការនាំចេញសរុបនៃប្រទេសកម្ពុជា ទៅកាន់ប្រទេសផ្សេងៗ

| Model | Unstandardized Coefficients | | Standardized Coefficients | t | Sig. |
|---|---|---|---|---|---|
| | B | Std. Error | Beta | | |
| (Constant) | -1178387.235 | 69049.476 | | -17.066 | 0.000 |
| year | 589.367 | 34.370 | 0.972 | 17.148 | 0.000 |

$R^2 = 0.945$, SEE = 820.5712; F = 294.045, p = 0.000

Linear Regression Model: កំណើន GDP តម្លៃការនាំចេញសរុបនៃប្រទេសកម្ពុជា ទៅកាន់ទេសផ្សេងៗ

=-1178387.235 + 589.367 ឆ្នាំ

ការវិភាគ Linear Regression បានបង្ហាញឱ្យឃើញថា ឆ្នាំមានឥទ្ធិពលលើតម្លៃការនាំចេញសរុបនៃប្រទេសកម្ពុជាទៅកាន់ទេសផ្សេងៗ ជាអត្ថន័យដោយស្ថិតិ ដោយ F = 294.045, p < 0.001 ហើយឆ្នាំអាចពន្យល់អំពីតម្លៃការនាំចេញសរុបនៃប្រទេសកម្ពុជាទៅកាន់ប្រទេសផ្សេងៗ94.5ភាគរយ។ ហេតុដូច្នេះ ជារៀងរាល់ឆ្នាំតម្លៃការនាំចេញសរុបនៃប្រទេសកម្ពុជាទៅកាន់ប្រទេសផ្សេងៗនឹងកើនឡើង589.367US$ million (t = 17.148, P < 0.001។

## ៣.៤ ការវិភាគ Regression នៃកំណើន GDP ក្នុងការនាំចូល ប្រទេសកម្ពុជា




ក្រាហ្វិកទី ៣.៣. តម្លៃនៃការនាំចូលសរុបនៃប្រទេសកម្ពុជា ទៅកាន់ប្រទេសផ្សេង

តម្លៃការនាំចូលសរុបនៃប្រទេសកម្ពុជាពីប្រទេសផ្សេងៗ ចាប់ពីឆ្នាំ2000(1,412.46US$ million) រហូតដល់ឆ្នាំ2008 (4,421.72 US$ million) មានការកើនឡើងបន្តិចបន្តួចជាលំដាប់ និងថយចុះបន្តិចមកវិញនៅឆ្នាំ2009 (3, .899US$ million) រហូតមកមានការកើនឡើងជាលំដាប់ឆ្នាំ២០១៨ (19,264.44 US$ million)។ យោងតាមការវិភាគ Pearson Correlation Coefficient លទ្ធផលបានបង្ហាញថា ចាប់តាំងពីឆ្នាំ 2000 ដល់ 2018 តម្លៃការនាំចូលនៃប្រទេសកម្ពុជាទៅកាន់ប្រទេសផ្សេងៗ (r = 0.928; p < 0.001) មានការកើនឡើងជាលំដាប់។

តារាងទី៣.៤ ការវិភាគ Linear Regression តម្លៃការនាំចូលសរុបនៃប្រទេសកម្ពុជា ទៅកាន់ទេសផ្សេងៗ

| Model | Unstandardized Coefficients | | Standardized Coefficients | t | Sig. |
|---|---|---|---|---|---|
| | B | Std. Error | Beta | | |
| (Constant) | -1754806.856 | 171490.319 | | -10.233 | 0.000 |
| Year | 876.684 | 85.361 | 0.928 | 10.270 | 0.000 |

$R^2$ = 0.861, SEE = 2037.9592; F = 105.48, p = 0.000

Linear Regression Model: កំណើន GDP តម្លៃការនាំចូលសរុបនៃប្រទេសកម្ពុជា ទៅកាន់ទេសផ្សេងៗ = ( -1754806.856) + 876.684 ឆ្នាំ

ការវិភាគ Linear Regression បានបង្ហាញឱ្យឃើញថា ឆ្នាំមានឥទ្ធិពលលើតម្លៃការនាំចូលសរុបនៃប្រទេសកម្ពុជាទៅកាន់ទេសផ្សេងៗ ជាអត្ថន័យដោយស្ថិតិ ដោយ F = 294.045, P=0.0001 អាចពន្យល់អំពីតម្លៃនៃការនាំចូលសរុបនៃប្រទេសកម្ពុជា ទៅកាន់ប្រទេសផ្សេងៗ 94.5 ។ ហេតុដូចនេះ ជារៀងរាល់ឆ្នាំ តម្លៃនៃការនាំចេញសរុបនៃប្រទេសកម្ពុជា ទៅកាន់ប្រទេសផ្សេងៗនឹងកើនឡើង 876.684 US$ million (t = 10.270, p <0.0001។

## ៣.៥ ការវិភាគទំនាក់ទំនងនៃកំណើនGDPផលិតផលក្នុងស្រុកសរុប

តារាងទី ៣.៥ ការវិភាគ Pearson correlation coefficient ដោយផ្អែកលើកំណើន GDP

| អថេរឯករាជ្យ | Pearson's correlation (*r*) | *p*-value |
|---|---|---|
| ពាណិជ្ជកម្ម | 0.737 | 0.000*** |
| FDI | 0.044 | 0.697 |
| ឧស្សាហកម្ម | 0.986 | 0.000*** |
| បច្ចេកវិទ្យា | -0.001 | 0.990 |

សម្គាល់: ទំនាក់ទំនងជាអត្ថន័យក្នុងកម្រិត *$p$ < 0.05, **$p$ < 0.01, ***$p$ < 0.001

យោងតាមការវិភាគ Pearson Correlation Coefficient លទ្ធផលបានបង្ហាញថា កំណើន GDP មានទំនាក់ទំនងខ្ពស់ ជាអត្ថន័យដោយស្ថិតិ ជាមួយនឹងវិស័យពាណិជ្ជកម្ម (r = 0.737; p < 0.001) និង Industry (r = 0.986; p < 0.001)។ ដូច្នេះ ការរីកចម្រើននៃវិស័យពាណិជ្ជកម្ម និងឧស្សាហកម្ម បានធ្វើឱ្យកំណើន GDP កើនឡើង។ យ៉ាងណាមិញ វិស័យ Foreign Direct Investment (FDI) និងវិស័យ បច្ចេកវិទ្យា មិនមានទំនាក់

ទំនងជាអត្ថន័យដោយស្ថិតិនោះទេជាមួយនឹងកំណើន GDP ($p > 0.05$)។ ដូច្នេះ វិស័យ Foreign Direct Investment (FDI) និងវិស័យបច្ចេកវិទ្យា មិនមែនជាកត្តាដែលធ្វើឱ្យមានកំណើនផលិតផលក្នុងស្រុកសរុប (GDP) នោះទេ។

តារាងទី ៣.៥ ការវិភាគ Multiple Regression ដោយផ្អែកលើកំណើន (GDP)

| | Model | Unstandardized Coefficients | | Standardized Coefficients | t | p-value |
|---|---|---|---|---|---|---|
| | | B | Std. Error | Beta | | |
| | Constant | -1635.699 | 466.824 | | -3.504 | 0.001 |
| | ពាណិជ្ជកម្ម | 0.054 | 0.006 | 0.160 | 9.056 | 0.000 |
| | ឧស្សាហកម្ម | 3.469 | 0.069 | 0.881 | 49.935 | 0.000 |

$R^2 = 0.986$, SEE = 2530.03461, F = 2773.227, p = 0.000

Multiple Regression Model: កំណើន GDP =( -1635.699) + 0.054 ពាណិជ្ជកម្ម + (3.469*ឧស្សាហកម្ម)

ការវិភាគ Multiple Regression បានបង្ហាញឱ្យឃើញថា វិស័យពាណិជ្ជកម្ម និងវិស័យឧស្សាហកម្ម មានឥទ្ធិពលលើកំណើន GDP ជាអត្ថន័យដោយស្ថិតិ ដោយ F = 2773.227, $p < 0.001$ ហើយវិស័យពាណិជ្ជកម្ម និងវិស័យឧស្សាហកម្មអាចពន្យល់អំពីកំណើន GDP បាន 98.6% ។

ហេតុដូច្នេះ ប្រសិនបើវិស័យពាណិជ្ជកម្មកើនឡើង១ឯកតា វានឹងធ្វើឱ្យកំណើន GDP កើនឡើង 0.054% ($t = 9.056$; $p < 0.001$) ហើយបើវិស័យឧស្សាហកម្មកើនឡើង១ឯកតា វានឹងធ្វើឱ្យកំណើន GDP កើនឡើង 3.469% ($t = 49.935$; $p < 0.001$)។

៣.៦ ការវិភាគ Regression នៃកំណើន GDP វិស័យបច្ចេកវិទ្យាខ្ពស់ប្រទេសកម្ពុជា




តារាងទី ៣.៦ ការវិភាគ Linear Regression នៃកំណើន GDP វិស័យបច្ចេកវិទ្យាខ្ពស់ប្រទេសកម្ពុជា

| Model | Unstandardized Coefficients | | Standardized Coefficients | t | Sig. |
|---|---|---|---|---|---|
| | B | Std. Error | Beta | | |
| (Constant) | -34438969670.014 | 10090417903.142 | | -3.413 | 0.009 |
| Year | 17137789.321 | 5006404.196 | 0.771 | 3.423 | 0.009 |

$R^2$ = 0.594, SEE = 45472924.31; F = 11.718, p = 0.009

Linear Regression Model: កំណើន GDP វិស័យបច្ចេកវិទ្យាខ្ពស់ប្រទេសកម្ពុជា= (-34438969670.014)+ 17137789.321 ឆ្នាំ

ការវិភាគ Linear Regression បានបង្ហាញឱ្យឃើញថា ឆ្នាំមានឥទ្ធិពលលើកំណើន GDP វិស័យបច្ចេកទេសខ្ពស់ប្រទេសកម្ពុជា ជាអត្ថន័យដោយស្ថិតិ ដោយ F=11.718, P=0.009 ហើយឆ្នាំអាចពន្យល់អំពីកំណើន GDP វិស័យបច្ចេកទេសខ្ពស់ប្រទេសកម្ពុជា 59.4 ។ ហេតុដូច្នេះ ជារៀងរាល់ឆ្នាំកំណើន %GDP វិស័យបច្ចេកទេសខ្ពស់ប្រទេសកម្ពុជានឹងកើនឡើង17137789.321ឯកតា T= 3.423, P< 0.009) តារាងទី ៣.៦ ។

តារាងទី ៣.៦ ការវិភាគទំនាក់ទំនងរវាង GDP, Trade, FDI, Industry និង Technology

**Correlations**

| | | GDP | Trade | FDI | Indusrty | Technology |
|---|---|---|---|---|---|---|
| GDP | Pearson Correlation | 1 | .737** | .044 | .986** | -.001 |
| | Sig. (2-tailed) | | .000 | .697 | .000 | .990 |
| | N | 80 | 80 | 80 | 80 | 80 |
| Trade | Pearson Correlation | .737** | 1 | .093 | .655** | -.052 |
| | Sig. (2-tailed) | .000 | | .412 | .000 | .648 |
| | N | 80 | 80 | 80 | 80 | 80 |
| FDI | Pearson Correlation | .044 | .093 | 1 | .059 | .916** |
| | Sig. (2-tailed) | .697 | .412 | | .600 | .000 |
| | N | 80 | 80 | 80 | 80 | 80 |
| Indusrty | Pearson Correlation | .986** | .655** | .059 | 1 | .052 |
| | Sig. (2-tailed) | .000 | .000 | .600 | | .645 |
| | N | 80 | 80 | 80 | 80 | 80 |
| Technology | Pearson Correlation | -.001 | -.052 | .916** | .052 | 1 |
| | Sig. (2-tailed) | .990 | .648 | .000 | .645 | |
| | N | 80 | 80 | 80 | 80 | 80 |

**. Correlation is significant at the 0.01 level (2-tailed).

យោងតាមការវិភាគ Pearson Correlation Coefficient លទ្ធផលបានបង្ហាញថា កំណើនផលិតផលក្នុងស្រុកសរុប (GDP) មានទំនាក់ទំនងខ្ពស់ ជាអត្ថន័យដោយស្ថិតិ ជាមួយនឹងណាណិជ្ជកម្ម (Trade) ដោយតម្លៃ ($r = 0.737$; $p < 0.001$) និងឧស្សាហកម្ម (Industry) ដោយតម្លៃ ($r = 0.986$; $p < 0.001$)។ ដូច្នេះការរីកចំរើននៃវិស័យពាណិជ្ជកម្ម និងឧស្សាហកម្ម ធ្វើឱ្យកំណើនផលិតផលក្នុងស្រុកសរុប GDP កើនឡើង។ យ៉ាងណាមិញ វិស័យការវិនិយោគផ្ទាល់ពីបរទេស(FDI) និងវិស័យបច្ចេកវិទ្យា មិនមានទំនាក់ទំនងជាអត្ថន័យដោយស្ថិតិនោះទេជាមួយនឹងកំណើន GDP) $p > 0.05$)។ ដូច្នេះ វិស័យ (FDI) និងវិស័យបច្ចេកវិទ្យាមិនមែនជាកត្តាដែលធ្វើឱ្យមានកំណើនផលិតផលក្នុងស្រុក(GDP)នោះទេ។[59]

[59] https://opendevelopmentcambodia.net/km/news/cambodias-banking-industry-sees-three-percent-gdp-growth-last-year-despite-pandemic-38-5-billion-in-deposits/

# សេចក្តីសន្និដ្ឋាន
# និង
# អនុសាសន៍

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១.សេចក្តីសន្និដ្ឋាន

លទ្ធផលនៃការស្រាវជ្រាវនេះ ក៏បានរកឃើញផងដែរថា សាកលូបនីយកម្មអភិវឌ្ឍសេដ្ឋកិច្ច បដិវត្ត ឧស្សាហកម្ម៤.០ នៅប្រទេសកំពុងអភិវឌ្ឍន៍ និងអភិវឌ្ឍន៍ ជាពិសេសប្រទេសកម្ពុជាមានទំនាក់ទំនងរវាងអថេរចំនួនពីរ មានដូចជា ពាណិជ្ជកម្ម(Trade) និងឧស្សាហកម្ម(Industry) មានទំនាក់ទំនងនឹងផលិតផលក្នុងស្រុកសរុប(GDP) ជាលក្ខណៈ។ ស្ថិតិនៅកម្រិត ០.៥ភាគរយនៃសារៈសំខាន់ និងកម្រិតនៃទំនុកចិត្ត៩៥ភាគរយ។ ប៉ុន្តែចំពោះអថេរផ្សេងទៀត ដូចជា ការវិនិយោគផ្ទាល់ពីបរទេស(FDI) និងបច្ចេកវិទ្យា(Technology) មិនមានទំនាក់ទំនងនឹងផលិតផលក្នុងស្រុកសរុប(GDP) នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងអភិវឌ្ឍន៍ ជាពិសេសប្រទេសកម្ពុជា ជាលក្ខណៈស្ថិតិនោះទេ។ ការរីកចំរើនវិស័យពាណិជ្ជកម្ម និងវិស័យឧស្សាហកម្ម ធ្វើឱ្យកំណើនផលិតផលក្នុងស្រុកសរុប(GDP) ហើយការវិនិយោគបរទេស(FDI) និងបច្ចេកវិទ្យា(Technology) មិនមែនជាកត្តាដែលធ្វើឱ្យកើនឡើង ផលិតផលក្នុងស្រុកសរុប(GDP) នោះទេ។

## ២ អនុសាសន៍

បានរកឃើញថា បដិវត្តឧស្សាហកម្ម ៤.០ នៅប្រទេសកម្ពុជា មានទំនាក់ទំនងរវាងជាមួយកត្តាពាណិជ្ជកម្ម (Trade) និងឧស្សាហកម្ម(Industry) ដែលមានទំនាក់ទំនងនឹងផលិតផលក្នុងស្រុកសរុប(GDP) ការវិនិយោគផ្ទាល់ពីបរទេស(FDI) គួរផ្អែកលើសក្តានុពលច្បាប់វិនិយោគថ្មីដែលមានភាពទាក់ទាញ គោលនយោបាយលើកទឹកចិត្តដែលរាជរដ្ឋាភិបាលបានផ្តល់ទីផ្សារសក្តានុពលដែលមានដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស (FDI) ឱ្យបានកាន់តែច្រើន។គួរខិតខំប្រើប្រាស់ឱ្យអស់លទ្ធភាពនូវសក្តានុពលធនធានធម្មជាតិ ភូមិសាស្ត្រ និងធនធានមនុស្សដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស (FDI) បន្ថែមទៀត។ គួរប្រើប្រាស់ឱ្យអស់លទ្ធភាពនូវបណ្តាកាលានុវត្តភាពដែលទទួលបានពីភាពអនុគ្រោះពាណិជ្ជកម្ម កិច្ចព្រមព្រៀងពាណិជ្ជកម្មនានា ដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស (FDI) បន្ថែមទៀត។ពិតប្រាកដមែន។លទ្ធផលនៃការស្រាវជ្រាវនេះ ក៏បានរកឃើញផងដែរថា ស្ថានភាពសាកលូបនីយកម្មក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៅប្រទេសកម្ពុជា ត្រូវបានរកឃើញថា សាកលូបនីយកម្មធ្វើឱ្យមានកំណើន កម្រិតបង្គួរ នូវកត្តាមួយចំនួនដូចជា កំណើនសេដ្ឋកិច្ច ផលិតផលក្នុងស្រុក ការវិនិយោគផ្ទាល់ពីបរទេស ការនាំចេញ នាំចូល ឧស្សាហកម្ម ។ករណីសិក្សាប្រទេសកម្ពុជា: ឧស្សាហកម្ម (Industry)គួរមានគោលនយោបាយលើកទឹកចិត្តបណ្តាសហគ្រាស រោងចក្រ ឧស្សាហកម្ម ដែលមានការប្រើប្រាស់ផ្ទេរបច្ចេកវិទ្យាថ្មីៗ និងនវានុវត្តខ្ពស់ទាំងការវិនិយោគដោយផ្ទាល់ពីបរទេស (FDI) និងការវិនិយោគក្នុងស្រុក។

- ករណីសិក្សាប្រទេសកម្ពុជា: ពាណិជ្ជកម្ម(Trade)គួរបង្កើនការធ្វើពិពិធកម្មទីផ្សារអន្តរជាតិសក្តានុពលថ្មីៗ បន្ថែមទៀត។ គួរប្រើប្រាស់ឱ្យអស់លទ្ធភាពនូវបណ្តាកាលានុវត្តភាពដែលទទួលបានពីភាពអនុគ្រោះន

ប្រព័ន្ធពាណិជ្ជកម្ម និងកិច្ចព្រមព្រៀងពាណិជ្ជកម្មនានា។ពង្រឹងអភិបាលកិច្ចស្ថាប័នសាធារណៈលើកកម្ពស់គុណភាពសេវាសាធារណៈសម្រួលការធ្វើពាណិជ្ជកម្ម ជាពិសេសលើកទឹកចិត្តពាណិជ្ជកម្ម/សេវាកម្មនាំចេញ។គួរប្រើប្រាស់ឱ្យអស់លទ្ធភាពចំពោះឧត្តមភាពប្រៀបធៀបដែលយើងមាន ដើម្បីបង្កើនឧត្តមភាពប្រកួតប្រជែងក្នុងការធ្វើពាណិជ្ជកម្មអន្តរជាតិ។

- ការវិនិយោគផ្ទាល់ពីបរទេស(FDI)គួរតែផ្តោតយកចិត្តទុកដាក់ទៅលើកត្តាមួយចំនួនដូចជា ការកើនឡើងនៃការវិនិយោគផ្ទាល់ពីបរទេស ការជំរុញកំណើនសេដ្ឋកិច្ច ការប្រកួតប្រជែង និងការអភិវឌ្ឍបច្ចេកវិទ្យា។

ករណីសិក្សាប្រទេសកម្ពុជា: ការវិនិយោគផ្ទាល់ពីបរទេស(FDI) គួរផ្អែកលើសក្តានុពលច្បាប់វិនិយោគថ្មីដែលមានភាពទាក់ទាញ គោលនយោបាយលើកទឹកចិត្តដែលរាជរដ្ឋាភិបាលបានផ្តល់ទីផ្សារសក្តានុពលដែលមានដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស (FDI) ឱ្យបានកាន់តែច្រើន។គួរខិតខំប្រើប្រាស់ឱ្យអស់លទ្ធភាពនូវសក្តានុពលធនធានធម្មជាតិ ភូមិសាស្ត្រ និងធនធានមនុស្សដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស (FDI) បន្ថែមទៀត។ គួរប្រើប្រាស់ឱ្យអស់លទ្ធភាពនូវបណ្តាកាលានុវត្តភាពដែលទទួលបានពីភាពអនុគ្រោះពាណិជ្ជកម្ម កិច្ចព្រមព្រៀងពាណិជ្ជកម្មនានា ដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស (FDI) បន្ថែមទៀត។

- ជំរុញការប្រើប្រាស់បច្ចេកវិទ្យា លើកកម្ពស់ផលិតភាព និងភាពប្រកួតប្រជែងខ្ពស់ក្នុងផលិតកម្ម(Smart Factories, Smart Industry,...)។ គួរតែចាប់យកនូវសក្តានុពលក្នុងការអភិវឌ្ឍសេដ្ឋកិច្ចដោយឈរលើថ្នាលបច្ចេកវិទ្យា(Technology Platform)។ពង្រឹងសុខភាពនិងធ្វើទំនើបកម្មបណ្តាមូលដ្ឋានសេដ្ឋកិច្ចដែលមានស្រាប់ជាអាទិ៍ វិស័យកសិកម្ម ឧស្សាហកម្ម សំណង់ ។ធ្វើទំនើបកម្មប្រព័ន្ធដឹកជញ្ជូន និងភស្តុភារកម្ម(Logistic) ដែលធានាបានភាពទាន់ពេល ចំណាយទាប ងាយទទួលបាន និងប្រកបដោយគុណភាព។

ការកសាងធនធានមនុស្ស និងកម្លាំងពលកម្មជំនាញគួរត្រូវបានជំរុញឱ្យបានខ្លាំងក្លា ដើម្បីបង្កើនផលិតភាពគុណភាពក្នុងឧស្សាហកម្មជាពិសេសការកសាងឯកទេសកម្មចំពោះវិស័យសក្តានុពលមួយចំនួន។ គួរមានការគាំទ្រឱ្យបានកាន់តែទូលំទូលាយខ្លាំងក្លាចំពោះគោលនយោបាយអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាពិសេសការងារស្រាវជ្រាវ និងអភិវឌ្ឍ(R&D)។

# ឯកសារយោង

# ១.បណ្ណាល័យសាស្ត្រជាភាសាជាតិ


1. គាត ឈន់, អូន ពន្ធ័មុន្នីរ័ត្ន និងវង្សី វិស្សុត, (ខែមករា ឆ្នាំ១៩៩៩). "គ្រប់គ្រងបញ្ហាប្រឈម និងសកលភាវូបនីយកម្ម"
2. តាន់ មុន្នីវិសាល "បដិវត្តឧស្សាហកម្មទី៤ (ឧស្សាហកម្ម៤.0)" លេខទី៣ ថ្ងៃទី ៤ខែមិថុនា ឆ្នាំ២០១៩ ទំព័រ១-២
3. ស៊ុំ សុចិន្តា "២០១០" ប្រវត្តិគំនិតសេដ្ឋកិច្ច សាកលវិទ្យាល័យជាតិគ្រប់គ្រង បោះពុម្ពលើកទី៤
4. តួនាទីរបស់ការអភិវឌ្ឍនវិស័យឯកជនសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន និងការធ្វើសមាហរណកម្មហិរញ្ញវត្ថុ ៖ទស្សនវិស័យរបស់ អាស៊ាន
5. និត កុសល, (ថ្ងៃទី៨ ខែឧសភាឆ្នាំ២០២) "តើកម្ពុជាគួរត្រៀមខ្លួនដូចម្ដេចសម្រាប់បដិវត្តន៍ឧស្សាកម្មទី៤
6. ហ៊ាប សាហ៊ីប "ទស្សនៈសេដ្ឋកិច្ច និងវិទ្យាសាស្ត្រសេដ្ឋកិច្ច" ភ្នំពេញ ឆ្នាំ២០២១ ទំព័រ៤៩៤-៤៩៥
7. តាន់ មុន្នីវិសាល (ថ្ងៃទី៤ ខែមិថុនាឆ្នាំ២០១៩) "បដិវត្តន៍ឧស្សាហកម្មទី៤ (ឧស្សាហកម្ម៤.0)". វ៉ុល ១ លេខទី៣
8. និត កុសល, (ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២០) "តើកម្ពុជា គួរត្រៀមខ្លួន ដូចម្ដេចសម្រាប់បដិវត្តន៍ឧស្សាកម្មទី៤"
9. ហ៊ាប សាហ៊ីប, (២០២១) "ទស្សនៈសេដ្ឋកិច្ច និងវិទ្យាសាស្ត្រសេដ្ឋកិច្ច" ភ្នំពេញ ទំព័រ ៤៩៥-៥០៥
10. តាន់ មុន្នីវិសាល, (ថ្ងៃទី៤ ខែមិថុនាឆ្នាំ២០១៩) "បដិវត្តន៍ឧស្សាហកម្មទី៤ (ឧស្សាហកម្ម ៤.0)" វ៉ុល ១ លេខទី៣
11. តាន់ មុន្នីវិសាល,(ថ្ងៃទី៤ខែមិថុនាឆ្នាំ២០១៩) "បដិវត្តន៍ឧស្សាហកម្មទី ៤(ឧស្សាហកម្ម ៤.0)"វ៉ុល១លេខទី៣
12. ជា ចំរើន, សួន ឱសថ, (២០១០) " មគ្គុទ្ទេស៍នៃភាពជាអ្នកដឹកនាំ និងកិច្ចចាត់ចែងការ" ភ្នំពេញ, ទំព័រ ៣៥-៥៧
13. មជ្ឈមណ្ឌលអភិវឌ្ឍកម្ពុជា (២០២១) ស្វែងយល់ពីបដិវត្តឧស្សាហកម្មទី៤
14. ទាវ រដ្ឋា , (ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២០) "តើកម្ពុជាត្រៀមខ្លួនដូចម្ដេចសម្រាប់បដិវត្តន៍ឧស្សាហកម្មទី ៤"
15. ហ៊ាប សាហ៊ីប ,(២០២១) "ទស្សនៈសេដ្ឋកិច្ច និងវិទ្យាសាស្ត្រសេដ្ឋកិច្ច" ភ្នំពេញ ទំព័រ ៥០១-៥០២
16. តើកម្ពុជាគួរត្រៀមខ្លួនដូចម្ដេច សម្រាប់បដិវត្តន៍ឧស្សហកម្មទី៤?
17. ហ៊ាប សាហ៊ីប , (២០២១) "ទស្សនៈសេដ្ឋកិច្ច និងវិទ្យាសាស្ត្រសេដ្ឋកិច្ច" ភ្នំពេញ ទំព័រ ៥០៣
18. ចម ប្រសិទ្ធ(ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣)«‹ឧស្សាហូបនីយកម្ម៖ចាប់យកភាពឈានទៅមុខនៃបច្ចេកវិទ្យាសម្រាប់សហគ្រាស›»ទំព័រទី២៥
19. យោងតាមរបាយការណ៍ របស់ធនាគារពិភពលោក នៅខែឧសភាឆ្នាំ ២០១៩ ប្រទេសកម្ពុជាបានកើន លើសតួលេខដែលបានព្យាករនៅក្នុងកំណើនប្រចាំឆ្នាំសម្រាប់ឆ្នាំ២០១៨

## ២.បណ្ណាល័យសាស្ត្រជាភាសាអង់គ្លេស


1. Bairoch, P. & Kozul-Wright, et all, (1996). "Globalization Myths: Some historical reflections on integration, industrialization and growth in the world economy".

2. Gundlach, E. & Nunnenkamp, et all, (1994). "Globalisation of Production and Markets", Kiel Institute, Germany

3. Hay, C. & Marsh, D. (2000). "Introduction: Demystifying Globalization in Demystifying Globalization".

4. Hirst, P.Q. & Thompson, G. (1996). "Globalisation in Question, Polity", Cambridge.Savina Gygli & Florian Haelg, et all., ( 2019 ) . "The KOF Globalisation Index"

5. Fischer, Stanley. (2003). "Globalization and Its Challenges ." American Economic Review, 93(2):1-30

6. Deluna Roperto Jr and Chelly, Antiquisa, (2014). "Economic Growth Financial and Trade Globalization in the Philippines: A Vector Autoregressive Analyis".

7. Vjollca V. Hasani, (2012). "Significance of globalization in economic development", Case of Kosovo.

8. Hae S Kim, (June 04, 2014). "Patterns of Economic Development in the World"

9. Vjollca V. Hasani, (2012)."Significance of globalization in economic development", Case of Kosovo

10. Muhammad Akram Ch, Muhammad Asim Faheem, et all,(2011)."Globalization and its Impacts on the World Economic Development",

11. International Trade Theory. (2016, Mar 17). Retrieved from https://studymoose.com/international-trade-theory-essay

12. International Trade Theory. (2016, Mar 17). Retrieved from https://studymoose.com/international-trade-theory-essay

13. Bairoch, P. & Kozul-Wright, R. (1996), "Globalization Myths: Some historical reflections on integration, industrialisation and growth in the world economy.

14. Vjollca V. Hasani, (……)"Significance of globalization in economic development", Case of Kosovo.

15. Mesut Savrul, And Ahmet İncekara, (2017). "The Effect of Globalization on Economic Growth: Panel Data Analysis for ASEAN Countries",

16. Muhammad Akram Ch, Muhammad Asim Faheem , et all,( December 2011). "Globalization and its Impacts on the World Economic Development"

17. Susan Robertson, Mario Novelli, et all. (2007). "GLOBALISATION, EDUCATION AND DEVELOPMENT: Ideas, Actors and Dynamics".

18. Kotilainen, M & Kaitila, V, (3/2002). "Economic Globalization in Developing Countries", The journal of Economic in Developing Countries, pp70.

19. Porter, M. (1990), "The Competitive Advantage of Nations", The Free Press, New York.

20. Cantwell, J. (1989), "Technological Innovation and Multinational Corporations", Basil Blackwell, Oxford.

21. Kotilainen, M & Kaitila, V, (3/2002). "Economic Globalization in Developing Countries", The journal of Economic in Developing Countries, pp70.

22. Gundlach, E. & Nunnenkamp, P.(1998), "Some Consequences of Globalization for Developing Countries", in J.H. Dunning (ed.), "Globalization, Trade and Foreign Direct Investment", Elsevier Science Ltd, Oxford.

23. Rasim Abutalibov, Seymur Guliyev, "GLOBALIZATION AND SOCIAL-ECONOMIC DEVELOPMENT: PROGRESS OR REGRESS"

24. Hae S Kim ,(June 04, 2014). "Patterns of Economic Development in the World"

25. Kuepper, Justin,( 2017). "Globalization and its Impact on Economic Growth, http://www.thebalance.com/globalization-and-its-impact-on-economic-growth-1978843

26. Kuepper, Justin, (2017). "Globalization and Its Impact On Economic Growth", http://www.thebalance.com/globalization-and-its-impact-on-economic-growth-1978843.

27. "Globalization: Definition, Benefits, Effects, Examples-What is Globalization?", https://www.justice.gov/file/18791/download,

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

រូបភាពទី១.៤ ដំណាក់កាលបដិវត្តឧស្សាហកម្មទី៤.០




រូបភាពទី១.៤.៣ការវិវត្តនៃបច្ចេកវិទ្យាឌីជីថល




Source: Asian Development Bank and AlphaBeta.

## ១.៤.៣.១ប្រវត្តិនៃបដិវត្តឧស្សាហកម្ម

Figure 1: The four industrial revolutions




Figure 1: Historical timeline of the four industrial revolutions




រូបភាពទី១.៤.២.៣បដិវត្តឧស្សាហកម្មទី៤.០




រូបភាពទី១.៤.២.៣បដិវត្តឧស្សាហកម្មទី៤.០ រោងចក្រស្មាត






រូបភាពទី ២.៣.៣ ឧស្សាហកម្មសំណង់




រូបភាពទី២.៣.៤៖ ការប្រើប្រាស់ដីសហគ្រាស